**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ប្រសិទ្ធភាពនៃការអប់រំ
# ករណីអង្គការដើម្បីភាពញញឹមនៃកុមារ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

| គាត់តែងឡើងដោយ | | សាស្ត្រាចារ្យណែនាំ |
|---|---|---|
| និស្សិតឈ្មោះ | **លីម រិនដើ** | លោក **ទួន ផល្លា** |
| | **រឿន សុភា** | |

| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច | | ឆ្នាំចូលសិក្សា | ២០១៣ |
| ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ជំនាន់ទី ១៦ | ឆ្នាំសរសេរសារណា | ២០១៧ |

# សេចក្តីថ្លែងអំណរគុណ

ក្រុមនាងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី១៦ មានកិត្តិយសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នកមានគុណទាំងអស់ដែលតែងតែជួយជ្រោមជ្រែងក្រុមនាងខ្ញុំតាំងពីដើមឆ្នាំទី១ រហូតមកដល់បញ្ចប់ការសិក្សាបរិញ្ញាបត្រសេដ្ឋកិច្ចឆ្នាំទី៤នេះ។ ក្រុមនាងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងដឹងគុណទៅដល់៖

**លោកឪពុក អ្នកម្តាយ** ដែលតែងតែឈរនៅពីក្រោយខ្នងកូនៗ ជំរុញទឹកចិត្ត ឧបត្ថម្ភទាំងថវិកា កម្លាំងកាយ និងចិត្ត ដើម្បីឲ្យកូនមានឱកាសទទួលបានការសិក្សាតាំងពីថ្នាក់បឋមសិក្សារហូតមកដល់បច្ចុប្បន្ន។

**លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យ** ទាំងអស់ដែលបានជួយបង្ហាត់បង្រៀន បង្ហាញផ្លូវ និងផ្ទេរនូវចំណេះដឹងទាំងអម្បាលម៉ានមកកាន់សិស្ស និស្សិត ក្នុងគោលបំណង ដើម្បីបណ្តុះបណ្តាលធនធានមនុស្សដែលល្អសម្រាប់សង្គមកម្ពុជា និងពិភពលោកទាំងមូល ដោយគ្មានការស្ទាក់ស្ទើរ។

លោកគ្រូសាស្ត្រាចារ្យ **ខួន ផល្លា** ដែលបានណែនាំអំពីការធ្វើនិក្ខេបបទនេះ និងតែងតែបង្ហាត់បង្រៀនដោយយកចិត្តទុកដាក់ ពង្រឹងទាំងវិន័យ ចំណេះដឹង បទពិសោធន៍ក្នុងការរស់នៅ និងក្នុងគ្រួសារ មកកាន់ក្រុមនាងខ្ញុំប៉ុន្មានឆ្នាំកន្លងមកនេះ ដែលជាគំរូដ៏ល្អសម្រាប់ក្រុមនាងខ្ញុំ និងមិត្តភក្តិដទៃទៀតនាពេលបច្ចុប្បន្ន និងអនាគត។

**អង្គការដើម្បីភាពញញឹមនៃកុមារ** ដែលបានជួយយកចិត្តទុកដាក់ ផ្តល់បទសម្ភាសន៍ និងឯកសារដ៏មានតម្លៃសម្រាប់ការសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់ក្រុមនាងខ្ញុំ។

**មិត្តភក្តិ និងអ្នកជុំវិញខ្លួន** ទាំងឡាយដែលតែងតែជាកម្លាំងចិត្ត ក្រើនរំលឹក និងផ្តល់យោបល់ល្អៗក្នុងរយៈពេលកន្លង និងសម្រាប់និក្ខេបបទមួយនេះផងដែរ។

ក្រុមនាងខ្ញុំសូមធ្វើការបួងសួងដល់វត្ថុស័ក្តសិទ្ធទាំងឡាយ សូមឲ្យអ្នកទាំងអស់គ្នា ទទួលបានសេចក្តីសុខ សុភមង្គល និងសំណាងល្អគ្រប់ៗគ្រា។

# អារម្ភកថា

តាមរយៈការសិក្សានូវទ្រឹស្តី រួមទាំងបទពិសោធន៍លើកិច្ចការស្រាវជ្រាវកន្លងមកក្នុងការសិក្សានូវជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ បានធ្វើឲ្យក្រុមនាងខ្ញុំមានចំណាប់អារម្មណ៍កាន់តែខ្លាំងទៅលើវិស័យនានាក្នុងការចូលរួមចំណែកក្នុងសេដ្ឋកិច្ច ជាពិសេសវិស័យអប់រំដែលជាវិស័យមួយដែលសំខាន់បំផុតក្នុងការកសាងធនធានមនុស្ស ជាធនធានដ៏សំខាន់ដោយពុំអាចខ្វះបានឡើយ។ ដោយមើលឃើញថា បណ្តាប្រទេសទាំងអស់ មិនថាប្រទេសដែលកំពុងអភិវឌ្ឍន៍ ឬក៏ប្រទេសដែលមានការអភិវឌ្ឍឡើយ គឺផ្តោតសំខាន់ខ្លាំងទៅលើធនធានមនុស្សជាចម្បង។ ស្របនឹងឱកាសនេះដែលក្រុមនាងខ្ញុំបានសម្រេចជ្រើសរើសប្រធានបទ "ប្រសិទ្ធភាពនៃការអប់រំករណីអង្គការដើម្បីភាពញញឹមនៃកុមារ" ដើម្បីជាប្រធានបទនៃសារណាសម្រាប់ឡើងធ្វើបទបង្ហាញនៅពេលបញ្ចប់ការសិក្សាបរិញ្ញបត្រ។

ចំពោះខ្លឹមសារនៃនិក្ខេបបទ មានគោលបំណងឆ្លុះបញ្ចាំងឲ្យឃើញពីសារៈសំខាន់នៃវិស័យអប់រំ ដែលត្រូវបានចាត់ទុកជាវិស័យអាទិភាព ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការធានាសុខមាលភាពការរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេសគឺកុមារងាយរងគ្រោះដែលជនក្រីក្រជាទំពាំងស្នងឫស្សី និងជាសសរទ្រូងក្នុងការពារ ព្រមទាំងការអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើន។ ការអប់រំ ជាកត្តាមួយដ៏សំខាន់នៅក្នុងសង្គមដែលប្រៀបបានទៅនឹងសរសៃឈាមរបស់មនុស្ស នោះគឺបានឆ្លុះបញ្ចាំងពីដំណើរនៃការកើនឡើងឬថយចុះនៃសេដ្ឋកិច្ចក៏អាចមកពីការអប់រំដែលជាផ្នែកដ៏សំខាន់ ក្នុងការជំរុញសេដ្ឋកិច្ចក្នុងវិស័យជាច្រើនទៀត ដូចជា វិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម សេវាកម្ម ទេសចរណ៍ និងសុខាភិបាលជាដើម។

អង្គការភាពញញឹមនៃកុមារ ជាស្ថាប័នមិនមែនរដ្ឋាភិបាលដែលបានផ្តល់ជំនួយដល់ការអប់រំ ចំពោះកុមារក្រីក្រនៅកម្ពុជាផ្ទាល់។ អង្គការបានផ្តល់នូវការសិក្សាដល់ក្មេងៗ ប្រកបដោយគុណភាព និងប្រសិទ្ធភាពទាំងផ្នែកចំណេះដឹងទូទៅ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលធ្វើឲ្យក្មេងៗទាំងនោះបានចាកចេញពីភាពអវិជ្ជា ទៅភាពមានការងារធ្វើជាអាជីព។ ជាចុងក្រោយ ក្រុមនាងខ្ញុំសូមអភ័យទោសនូវរាល់កំហុសឆ្គងនានាដែលកើតឡើងដោយអចេតនា ទាំងផ្នែកអក្ខរាវិរុទ្ធ និងការប្រើប្រាស់ពាក្យពេចន៍នានា ហើយក្រុមនាងខ្ញុំរង់ចាំទទួលការរិះគន់ទាំងឡាយក្នុងន័យស្ថាបនា ដើម្បីទុកជាបទពិសោធន៍ក្នុងការស្រាវជ្រាវលើកក្រោយ។

# មាតិកា

## សេចក្ដីផ្ដើម

១. លំនាំបញ្ហា ........................................ ២

២. ចំណោទបញ្ហា ........................................ ៣

៣. គោលបំណងនៃការស្រាវជ្រាវ ........................................ ៤

៤. សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ៥

៥. ទំហំ និងដែនកំណត់ ........................................ ៥

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ ៦

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៦

## ជំពូកទី១

## រំលឹកទ្រឹស្ដីពាក់ព័ន្ធ

១.១ សញ្ញាណរួមនៃប្រធានបទ ........................................ ៨

១.២ ស្ថានភាពទូទៅនៃការអប់រំនៅក្នុងប្រទេសកម្ពុជា ........................................ ៩

១.២.១ ប្រវត្តិនៃការអប់រំ ........................................ ៩

១.២.១.១ សម័យអង្គរ (គ.ស ៨០២ – ១៤៣២) ........................................ ៩

១.២.១.២ សម័យលង្វែក និងឧដុង្គ គ.ស ១៤៣២ –១៨៦៣ ........................................ ១១

១.២.១.៣ វិស័យអប់រំក្នុងសម័យអាណានិគមនិយមបារាំង ........................................ ១៣

១.២.១.៤ ចុងសម័យអាណានិគមនិយមបារាំង និងបន្ទាប់ពីទទួលបានឯករាជ្យ ... ១៤

១.២.១.៥ វិស័យអប់រំសម័យសង្គមរាស្ត្រនិមយ ........................................ ១៧

១.២.១.៦ សម័យរបបសាធារណរដ្ឋខ្មែរពីឆ្នាំ ១៩៧០–១៩៧៥ ........................................ ១៧

១.២.១.៧ សម័យកម្ពុជាប្រជាធិតេយ្យពីឆ្នាំ ១៩៧៥–១៩៧៩ ........................................ ១៨

១.២.១.៨ សម័យសាធារណៈប្រជាមានិតកម្ពុជា ឆ្នាំ ៩៧៩–១៩៨៨ ........................................ ១៩

១.២.១.៩ សម័យរដ្ឋកម្ពុជា ឆ្នាំ១៩៨៩–១៩៩៣ ........................................ ២០

១.២.១.១០ ការអប់រំនៅឆ្នាំ ១៩៩៣ ដល់ បច្ចុប្បន្ន ........................................ ២២

១.២.២ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ........................................ ២៥

១.២.២.១ គោលនយោបាយអប់រំ ........................................................................................២៥
១.២.២.២ សូចនាករស្នូល ..................................................................................................២៦
១.២.២.៣ គោលការណ៍របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤ - ២០១៨..២៧
១.២.២.៤ កម្មវិធីអាទិភាព ..............................................................................................២៨

## ជំពូកទី២

## សកម្មភាពរបស់អង្គការដើម្បីភាពញញឹមនៃកុមារក្នុងការអប់រំ

២.១ ស្ថានភាពទូទៅរបស់អង្គការ ....................................................................................២៩
២.១.១ ទីតាំង និងសាខារបស់អង្គការ ..............................................................................២៩
២.១.២ បេសកកម្ម ............................................................................................................ ៣០
២.១.៣ ប្រវត្តិ ................................................................................................................... ៣១
២.១.៤ រចនាសម្ព័ន្ធរបស់អង្គការ...........................................................................................៣៣
២.១.៥ ការឧបត្ថម្ភ និងដៃគូសហការ .................................................................................. ៣៤
២.២ សកម្មភាពក្នុងការអប់រំ និងបណ្តុះបណ្តាលរបស់អង្គការ ................................................ ៣៥
២.២.១ បឋមសិក្សា .......................................................................................................... ៣៦
២.២.២ មធ្យមសិក្សា...........................................................................................................៣៧
២.២.៣ សាលាពន្លឿន .........................................................................................................៣៧
២.២.៤ ការអប់រំជំនាញវិជ្ជាជីវៈ.......................................................................................... ៣៨
២.២.៤.១ ថ្នាក់ស្ពានចម្លង និងថ្នាក់ត្រៀម ........................................................................ ៣៩
២.២.៤.១.១ ប្រព័ន្ធនៃការសិក្សាថ្នាក់ត្រៀម ................................................................ ៣៩
២.២.៤.១.២ ម៉ោងសិក្សាតាមកម្រិតនិមួយៗ...................................................................៤០
២.២.៤.២ សាលាសណ្ឋាគារ និងទេសចរណ៍....................................................................៤២
២.២.៤.៣ សាលាពាណិជ្ជកម្ម........................................................................................ ៤៧
២.២.៤.៤ សាលាបច្ចេកទេស ..........................................................................................៥០
២.៣ យុទ្ធសាស្ត្រក្នុងការជំរុញការអប់រំប្រកបដោយប្រសិទ្ធភាព...............................................៥៤

២.៣.១. ចំណាង់វិធីក្នុងការជ្រើសរើសកុមារ.....................................................................................៥៤
២.៣.២ ការពង្រឹងគុណភាពគ្រូបង្រៀន ....................................................................................................៥៤
២.៣.២.១ ការជ្រើសរើសបុគ្គលិក .....................................................................................៥៤
២.៣.២.២ ការបណ្តុះបណ្តាលបន្ថែម...................................................................................៥៤
២.៣.២.៣ ការវាយតម្លៃគ្រូបង្រៀន ....................................................................................៥៥
២.៣.៣ យុទ្ធសាស្ត្រក្នុងការអប់រំ ..........................................................................................................៥៥
២.៣.៣.១ ការបង្កើតកម្មវិធីសិក្សាសិក្សា .........................................................................៥៥
២.៣.៣.២ ការគ្រប់គ្រងវិន័យ ...........................................................................................៥៥
២.៣.៣.៣ ការអប់រំចំណេះដឹងទូទៅ...................................................................................៥៦
២.៣.៣.៣.១ ការវាយតម្លៃការសិក្សា ................................................................................៥៧
២.៣.៣.៤ ការអប់រំអាកប្បកិរិយា និងផ្លូវចិត្ត .....................................................................៥៨
២.៣.៤ យុទ្ធសាស្ត្រក្នុងការតម្រង់ទិសដៅជ្រើសរើសជំនាញ.......................................................................៥៨
២.៣.៥ សេវាសុខភាព និងសកម្មភាពផ្សេងៗ .........................................................................................៥៩
២.៣.៥.១ សេវាសុខភាព...................................................................................................៥៩
២.៣.៥.២ សកម្មភាពកីឡា និងកម្សាន្ត................................................................................៥៩
២.៤ សមិទ្ធផល...........................................................................................................................................៦១
២.៤.១ សមិទ្ធផលក្នុងការបណ្តុះបណ្តាលអប់រំ........................................................................................៦១
២.៤.២ អត្រាទទួលបានការងារ ប្រាក់បៀវត្សរ៍ និងការពេញចិត្ត...................................................................៦១
២.៤.៣ មតិរបស់សិស្សដែលបានបញ្ចប់ការសិក្សា ...................................................................................៦២
២.៤.៤ ចំនួនកុមារដែលត្រូវបានផ្តល់ការការពារ......................................................................................៦៤
២.៤.៥ ទិន្នន័យសិស្សានុសិស្ស និងនិស្សិត..............................................................................................៦៤
២.៤.៥.១ ចំនួនសិស្សសិក្សានៅផ្នែកអប់រំចំណេះដឹងទូទៅ....................................................៦៤
២.៤.៥.២ ចំនួនសិស្សសិក្សានៅផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ...................................................៦៥
២.៤.៥.៣ ចំនួនសិស្សបញ្ចប់ការសិក្សានៅឆ្នាំ២០១៣-២០១៦...............................................៦៦

២.៤.៥.៤ ចំនួនសិស្សដែលបោះបង់ការសិក្សា ........................................... ៦៧
២.៥ បញ្ហាប្រឈម និងដំណោះស្រាយ ........................................... ៦៧
២.៦ ការចំណាយទៅលើកម្មវិធីផ្សេងៗក្នុងផ្នែកអប់រំ ........................................... ៦៨
២.៧ ការចំណាយទៅលើបុគ្គលិក ........................................... ៦៩
២.៨ យុទ្ធសាស្ត្រ និងគម្រោងទៅថ្ងៃអនាគត ........................................... ៧០

ជំពូកទី៣

ការវិភាគសកម្មភាពរបស់អង្គការធៀបនឹងទ្រឹស្តី

៣.១ សកម្មភាពរបស់អង្គការ ........................................... ៧១
៣.១.១ ចំណុចខ្លាំងរបស់អង្គការ ........................................... ៧១
៣.១.២ ចំណុចខ្សោយរបស់អង្គការ ........................................... ៦១
៣.២ ទ្រឹស្តីនៃប្រសិទ្ធភាពអប់រំ ........................................... ៧៣
៣.៣ សំយោគទ្រឹស្តី និងសកម្មភាព ........................................... ៧៣

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................... ៧៤
២. អនុសាសន៍ ........................................... ៧៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រទេសកម្ពុជាជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ និងជាប្រទេសដែលបានចូលជាសមាជិកសេដ្ឋកិច្ចអាស៊ាន ដូច្នេះហើយបានជារាជរដ្ឋាភិបាល បាននឹងកំពុងខិតខំរកវិធីសាស្ត្រក្នុងការជំរុញឲ្យមានការអភិវឌ្ឍលើគ្រប់វិស័យដើម្បីបង្កើតបាននូវភាពរីកចម្រើនទាំងផ្នែកសង្គម និងសេដ្ឋកិច្ចជាតិទាំងមូល។ ដោយយើងមើលឃើញថា គ្រប់បណ្តាប្រទេសទាំងអស់មានការរីកចម្រើន និងការអភិវឌ្ឍមួយអាចឈានទៅមុខបានលុះត្រាមានធនធានមនុស្ស ដែលជាកត្តាសំខាន់ដោយមិនអាចខ្វះបាន ក្នុងការចូលរួមជាកម្លាំងចលករដើម្បីឆ្ពោះទៅរកភាពរីកចម្រើន។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងខិតខំប្រឹងប្រែងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការអប់រំដែលជាវិស័យស្នូលក្នុងការកសាងធនធានមនុស្ស។ នៅក្នុងប្រទេសមួយ ដែលមានប្រជាជនមានជំនាញ ចំណេះដឹង ឥរិយាបទល្អ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការបង្កើត និងបង្កើនផលិតភាព ដែលជាកត្តាបង្កើតការងារសម្រាប់ផ្គត់ផ្គង់តម្រូវការពលកម្មនៅក្នុងស្រុក និងកាត់បន្ថយចំណាកស្រុកទៅកាន់ បណ្តាប្រទេសជិតខាងជាដើម។ ម្យ៉ាងទៀតការអប់រំមួយអាចដំណើរការទៅបានល្អប្រសើរ តម្រូវឲ្យមានការយកចិត្តទុកដាក់លើ កត្តាសុខភាព អាហាររូបត្ថម្ភ ការលើកទឹកចិត្តពីសំណាក់ក្រុមគ្រួសារ ស្ថេរភាពផ្នែកនយោបាយ ផ្នែកកម្លាំងរាងកាយ និងផ្លូវចិត្ត ដោយចាប់ផ្តើមពីការសិក្សារៀនសូត្រប្រកបដោយប្រសិទ្ធភាព។

ដូច្នេះការអប់រំ គឺមានសារៈសំខាន់ណាស់ចំពោះមនុស្សគ្រប់រូប គ្រប់ជាតិសាសន៍នៅលើពិភពលោកនេះ។ ប្រទេសមួយដែលមានការមានសេដ្ឋកិច្ចរីកចម្រើន និងមានការអភិវឌ្ឍដោយសារប្រទេសទាំងនោះសំបូរទៅដោយធនធានមនុស្សដែលកើតចេញពីការអប់រំ ទោះបីប្រទេសដែលសំបូរទៅដោយសម្បត្តិធម្មជាតិក៏ដោយ តែបើខ្វះនូវធនធានមនុស្សក្នុងការកែច្នៃប្រឌិត ខ្វះជំនាញ ខ្វះបទពិសោធន៍ ខ្វះចំណេះដឹងក្នុងការទាញយកធនធានទាំងយកមកប្រើប្រាស់ឲ្យមានប្រសិទ្ធភាព និងអស់សក្តានុពល នោះប្រទេសក៏គ្មានការរីកចម្រើនដែរ។ បែបនេះហើយបានជាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិឌ្ឍន៍ បាននឹងកំពុងខិតខំប្រឹងប្រែងយកចិត្តទុកដាក់លើការកែសម្រួលប្រព័ន្ធអប់រំរបស់ខ្លួន ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាយើងបានយកចិត្តទុកដាក់យ៉ាងខ្លាំងព្រមទាំងបានដាក់បញ្ចូល នូវផែនការយុទ្ធសាស្ត្រក្នុងការលើកស្ទួយវិស័យអប់រំ នៅក្នុងគោលនយោបាយជាតិផងដែរ។

## ១. លំនាំបញ្ហា

ការអប់រំនៅក្នុងប្រទេសកម្ពុជា បានដើរតួនាទីយ៉ាងសកម្មមិនថានៅក្នុងសម័យកាលណាក៏ដោយ។ បើយើងក្រឡេកមើលទៅការអប់រំ គឺមានតាំងតែសម័យកកើតរដ្ឋដំបូងមកម្ល៉េះ ដូចជានៅសម័យហ្វូណន សម័យចេនឡា សម័យអង្គរ ជាដើម។ ដោយការសិក្សានៅសម័យនោះពុំទាន់មានសាលារៀនដូចសព្វថ្ងៃនេះទេ។ ការសិក្សាបានធ្វើឡើងនៅតាមវត្តអារាម និងមានតែកូនប្រុសទេដែលមានសិទ្ធចូលរៀន ចំណែកកូនស្រីត្រូវនៅផ្ទះជួយកិច្ចការឪពុកម្តាយ។ ការអប់រំនៅសម័យនោះពិតជាមានការរីកចម្រើនណាស់ និងបានធ្វើឲ្យប្រទេសកម្ពុជាមានភាពល្បីល្បាញនៅក្នុងប្រវត្តិសាស្ត្រនៅសម័យក្រោយមកទៀត មកដល់បច្ចុប្បន្ន យើងនៅតែមើលឃើញថាការអប់រំនៅតែដើរតួនាទីយ៉ាងសំខាន់ដដែល។ នៅក្នុងសម័យចតុមុខ សម័យឧដុង្គ សម័យលង្វែក និងសម័យក្រោយៗមក ថ្នាក់ដឹកនាំកម្ពុជានៅតែបន្តការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ចំពោះវិស័យអប់រំ និងធ្វើការកែប្រែយុទ្ធសាស្ត្រដើម្បីឆ្ពោះទៅរកភាពរីកចម្រើន និងការអភិវឌ្ឍ ក្នុងការកសាងធនធានមនុស្ស។

ដោយឡែកក្នុងសម័យកាលមួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលជាសម័យកាល មួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ប្រព័ន្ធនៃការអប់រំក៏ដូចជាសាលារៀន ត្រូវបានបំផ្លាញស្ទើរតែទាំងស្រុងទៅវិញ ហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល សង្គម វប្បធម៌ទាំងអ្នកចេះដឹង បញ្ញវន្ត និងបណ្ឌិតមួយចំនួនធំត្រូវបានសម្លាប់យ៉ាងរង្គាលក្នុងរបបនោះ ជាពិសេសប្រព័ន្ធអប់រំនៅកម្ពុជា គឺត្រូវបានបាត់បង់ទាំងស្រុងតែម្តងក្រោយឆ្នាំ១៩៧០។ សម័យកាលនោះបានធ្វើឲ្យមាននូវកុមារកំព្រា ស្ត្រីម៉េមាយ ជនពិការ ដែលបាត់សមត្ថភាពក្នុងការស្វែងរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ការរស់នៅដោយគ្មានអាហារបរិភោគគ្រប់គ្រាន់ គ្មានជម្រករស់នៅខ្លះរស់នៅលើគំនរសំរាម បណ្តាលឲ្យមាជំងឺដង្កាត់ផ្សេងៗ។ ដោយសារតែបញ្ហាជីវភាពខ្វះខាតខ្លាំងដែលជាហេតុធ្វើឲ្យពួកគាត់ទាំងនោះ សម្រេចចិត្តទៅរើសសំរាម ឬអេតចាយ អ្នកខ្លះទៀតបានសម្រេចចិត្តឲ្យកូនឈប់ពីការសិក្សា ដើម្បីជួយការងារក្នុងផ្ទះ ឬក៏ជួយរកប្រាក់ចំណូល និងអ្នកខ្លះទៀតបានដើរសុំទាន យកមកដោះស្រាយបញ្ហា ឬដូរយកអាហារបំពេញក្រពះ។ ដូចដែលបានមើលឃើញជាក់ស្តែង សព្វថ្ងៃចំនួនកុមារកំព្រា កុមារដែលមិនបានចូលរៀន និងកុមារដែលបានបោះបង់ការសិក្សា កុមារខ្លះទៀតពុំបានទទួលការយកចិត្តទុកដាក់ពីសំណាក់ក្រុមគ្រួសារ ឬកុមារស្ថិតនៅក្នុងគ្រួសារដែលមានតែអំពើហិង្សាបានធ្វើឲ្យពួកគេបាត់បង់សិទ្ធទទួលបានការអប់រំដូចកុមារដទៃ។

ជាក់ស្តែងនាពេលបច្ចុប្បន្ន បានបង្ហាញឲ្យឃើញថាមានគ្រឹះស្ថានជាច្រើន មិនថាគ្រឹះស្ថានរដ្ឋ គ្រឹះស្ថានឯកជន និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន បានចូលរួមចំណែកក្នុងការស្តារ និងកសាងសាលារៀន បណ្ណាល័យ ការយកចិត្តសម្រាប់ការសិក្សាតាមបែបបទផ្សេងៗ ដើម្បីជំរុញវិស័យអប់រំ ឲ្យទទួលបានគុណភាព និងប្រសិទ្ធភាពក្នុងការទទួលយកចំណេះដឹង ជំនាញ បច្ចេកវិទ្យាជាដើម។ ប្រទេសកម្ពុជាជាប្រទេសមួយដែលសំបូរទៅដោយអង្គការក្រៅរដ្ឋាភិបាល ដែលចូលរួមទាំងផ្នែកសុខាភិបាល ផ្នែកសង្គម ជាពិសេសផ្នែកអប់រំ។ តួយ៉ាងដូចជា អង្គការដើម្បីភាពញញឹមនៃកុមារ បានខិតខំប្រឹងប្រែង និងចូលរួមយ៉ាងសកម្មក្នុងការពង្រីកនូវវិសាលភាពនៃការអប់រំ ព្រមទាំងបំពេញនូវចន្លោះប្រហោងពីមុនមកនៅក្នុងសកម្មភាពនៃការអប់រំផងដែរ។ ដោយសព្វថ្ងៃអង្គការកំពុងបំពេញបេសកកម្មរបស់ខ្លួនដោយការជួយកុមារកំព្រា កុមារខ្វះទីជម្រក កុមារខ្វះអាហារ កុមាររងាយរងគ្រោះដែលមានអំពើហិង្សាក្នុងគ្រួសារ និងពុំទទួលបាននូវការអប់រំជាច្រើនពាន់នាក់ក្នុងមួយឆ្នាំៗ។ ជាងនេះទៅទៀតយើងឃើញថា ចំនួនសិស្សនៅក្នុងអង្គការដែលទទួលបានការអប់រំសុទ្ធសឹងមានជំនាញច្បាស់លាស់ មានចំណេះដឹង និងមានបទពិសោធន៍ជាក់ស្តែងអំឡុងពេលសិក្សា។ អត្រាសិស្ស៩៥% ដែលបានបញ្ចប់ការសិក្សានឹងទទួលបានការងារធ្វើផងដែរ។ ហេតុដូចនេះហើយ បានជាក្រុមយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវលើសកម្មភាពនៃការអប់រំរបស់អង្គការមួយ ឈ្មោះថា "អង្គការដើម្បីភាពញញឹមនៃកុមារ" ក្នុងគោលបំណងជួយដល់កុមារក្រីក្រមិនថាជិត ឬឆ្ងាយឲ្យទទួលបានព័ត៌មាននៃការអប់រំ និងជួយលើកកម្ពស់កុមារឲ្យមានលទ្ធភាពចូលរៀនតាមរយៈអង្គការក្នុងទិសដៅបង្កើនគុណភាព និងប្រសិទ្ធនៃការអប់រំដើម្បីរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជាយើងឲ្យសំបូរទៅដោយធនធានមនុស្សដែលជាធនធានសំខាន់ក្នុងការធ្វើឲ្យប្រទេសជាតិរីកចម្រើន។

## ២. ចំណោទបញ្ហា

សព្វថ្ងៃនេះ កំពុងតែមានការជួយជ្រោមជ្រែង និងយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់រាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ដើម្បីរួមគ្នាជួយជំរុញអត្រាការចូលរៀនរបស់សិស្សនិស្សិតជាពិសេសគឺ កុមារក្រីក្រដែលងាយរងគ្រោះ។ ជារៀងរាល់ឆ្នាំ ចំនួនកុមារក្រីក្រជាច្រើននៅកម្ពុជាដែលមិនបានចូលរៀនបានត្រឹមត្រូវ និងចំនួននៃការបោះបង់ការសិក្សានៅតែមានកំណើនដែលកុមារទាំងនោះភាគច្រើនមានបញ្ហាប្រឈមផ្សេងៗដូចជា លំនៅឋានស្ថិតនៅតំបន់ដាច់ស្រយាលខ្លាំង កំព្រាឪពុកឬម្តាយ ឬកំព្រាទាំងឪពុកម្តាយ ជីវភាពខ្វះខាត គ្មានលំនៅឋានសមរម្យ ខ្វះសម្លៀកបំពាក់ អំពើហិង្សាក្នុងគ្រួសារ និងការចំណាកស្រុក ម្យ៉ាងទៀតកុមារខ្លះត្រូវជួយរកប្រាក់

សម្រាប់ដោះស្រាយបញ្ហាជីវភាពប្រចាំថ្ងៃរបស់គ្រួសារ។ល។ តួយ៉ាង បើក្រឡេកមើលកន្លែងចាក់សំរាមនៅស្ទឹងមានជ័យដែលមានប្រជាជនក្រីក្រជាច្រើន កំពុងយកការរើសសំរាមជាមុខរបររបស់ពួកគេ។ ដោយមូលហេតុពួកគេមិនដឹងថាទៅធ្វើការអ្វី ព្រោះអ្នកខ្លះពុំបានទទួលការសិក្សាអប់រំសូម្បីបន្តិចបន្តួច ហើយសមត្ថភាពនៅមានកម្រិត។ ជាពិសេសឃើញមានក្មេងៗជាច្រើនដែលប្រមូលគ្នានៅរើសសំរាមនៅទីនោះជារៀងរាល់ថ្ងៃ។ ដោយឃើញដូច្នេះអង្គការដើម្បីភាព ញញឹមនៃកុមារ បានប្រមូលផ្តុំកុមារទាំងនោះ ដោយផ្តល់នូវការស្នាក់នៅ ចំណីអាហារ សម្លៀកបំពាក់ ការយកចិត្តទុកដាក់ រៀបចំផ្នែកអនាម័យ ជាពិសេសគឺការផ្តល់នូវការអប់រំទាំងចំណេះដឹងទូទៅ និងចំណេះដឹងផ្នែកបច្ចេកទេស ជំនាញយ៉ាងល្អប្រសើរសម្រាប់កែប្រែខ្លួនឯងពីទុក្ខវេទនា ទៅកាន់ការងារអាជីព ឬការធ្វើការងារដើម្បីរកប្រាក់ចំណូលក្នុងការផ្គត់ផ្គង់ជីវភាព ព្រមទាំងដើម្បីក្លាយខ្លួនទៅធនធានមនុស្ស ក្នុងការចូលរួមកសាងសង្គម និងប្រទេសជាតិទាំងមូល។ កត្តាដែលធ្វើឲ្យក្រុមនាងខ្ញុំធ្វើការសិក្សា ស្រាវជ្រាវលើ ប្រធានបទប្រសិទ្ធភាពនៃការអប់រំរបស់អង្គការមានដូចខាងក្រោម ៖

- តើអង្គការដើម្បីភាពញញឹមនៃកុមារ ចូលរួមចំណែកផ្តល់ការអប់រំដល់កុមារក្រីក្រយ៉ាងមានប្រសិទ្ធភាពកម្រិតណាក្នុងការជួយជំរុញសេដ្ឋកិច្ចគ្រួសារ និងសង្គម?
- តើអង្គការមានផែនការយុទ្ធសាស្ត្រ និងវិធីសាស្ត្របែបណាខ្លះក្នុងការអប់រំ និងផ្លាស់ប្តូរជីវិតរបស់កុមារទាំងនោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ ប្រសិទ្ធភាពនៃការអប់រំករណីអង្គការដើម្បីភាពញញឹមនៃកុមារ ក្នុងទិសដៅស្វែងរកលទ្ធផលស្រាវជ្រាវ និងរបកគំហើញដែលមានប្រសិទ្ធភាពក្នុងការអប់រំរបស់អង្គការ មានគោលបំណងដូតទៅៈ

- ស្វែងយល់អំពីដំណើរការនៃការជ្រើសរើសសិស្ស និស្សិត និងបុគ្គលិក ក្នុងការបណ្តុះបណ្តាល
- សិក្សាអំពីសកម្មភាពដែលជំរុញឲ្យសិស្សទទួលបានគុណភាពនៃការអប់រំ
- សិក្សាអំពីទំនាក់ទំនងរវាងអង្គការ និងស្ថាប័នដទៃដែលជួយសិស្សពេលកំពុងសិក្សា និងក្រោយបញ្ចប់ការសិក្សា
- បង្ហាញចំនួនធនធានមនុស្សក្រោយពេលបញ្ចប់ការសិក្សានៅក្នុងអង្គការ ២០១៣ - ២០១៦

- ស្វែងយល់ពីសារៈសំខាន់នៃការទទួលបានការអប់រំដែលមានប្រសិទ្ធភាព។

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាអប់រំ គឺមានសារៈសំខាន់ណាស់ក្នុងការកសាងធនធានមនុស្សមិនថាប្រទេសណា ក៏ដូចជាប្រទេសណា ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដោយនៅខ្វះខាតផ្នែកធនធានមនុស្សជាសំខាន់ ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ចជាតិទាំងមូល។ សារៈសំខាន់មានដូចជាៈ

- បង្ហាញពីតួនាទី និងដំណើរនៃការអប់រំរបស់សម័យកាលនីមួយៗនៃប្រទេសកម្ពុជា
- បង្ហាញពីតួនាទី និងសារៈសំខាន់នៃការអប់រំដែលមានប្រសិទ្ធភាព
- បង្ហាញអំពីយុទ្ធសាស្ត្រ និងផែនការក្នុងការជួយលើកកម្ពស់ការអប់រំរបស់រាជរដ្ឋាភិបាល ក៏ដូចជាអង្គការ
- យល់ដឹងអំពីតួនាទីរបស់អង្គការក្នុងការរួមចំណែកកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស
- យល់ដឹងអំពីស្ថានភាពនៃការអប់រំ និងបណ្តុះបណ្តាលរបស់អង្គការ
- យល់ដឹងបន្ថែមអំពីបញ្ហាប្រឈមនានា និងដំណោះស្រាយរបស់អង្គការ
- យល់ដឹងពីការវិវត្តន៍ខ្លួនរបស់កុមារក្រីក្រនៅក្នុងសង្គម
- បទពិសោធន៍នៃការចុះស្រាវជ្រាវ និងការសម្ភាសន៍
- បង្ហាញពីភាពជាដៃគូរក្នុងការផ្តល់ជំនួយនានា
- ជាឯកសារសម្រាប់យកទៅប្រើប្រាស់ក្នុងការសិក្សា និងជំរុញក្នុងការអភិវឌ្ឍធនធានមនុស្សឲ្យមានប្រសិទ្ធភាពទៅថ្ងៃអនាគត។

## ៥. ទំហំ និងដែនកំណត់

ក្រុមនាងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារទាំងនេះដោយផ្តោតសំខាន់ទៅ លើប្រសិទ្ធភាពនៃការអប់រំរបស់អង្គការ ដោយបានសិក្សា និងដកស្រង់តែឯកសារដែលទាក់ទងនឹងសកម្មភាពរបស់អង្គការ ដែលចូលរួមចំណែកក្នុងការអប់រំដល់កុមារក្រីក្រឲ្យទទួលបានការសិក្សានូវចំណេះដឹងទូទៅ ជំនាញវិជ្ជាជីវៈ និងបច្ចេកទេសផ្សេងៗ ក្នុងការរំដោះខ្លួនចេញពីភាពក្រីក្រ និងអនក្ខរភាព ជាពិសេសការកសាងខ្លួនឲ្យក្លាយជាធនធានដ៏ប្រពៃរបស់គ្រួសារ សហគមន៍ និងសង្គមជាតិផងដែរ។ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងនៅអង្គការដើម្បីភាពញញឹមនៃកុមារនៅការិយាល័យកណ្តាលស្ថិតនៅផ្លូវលេខ ៩០២ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ចន្លោះឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៦។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើតម្រូវការព័ត៌មានក្នុងការវិភាគដូចខាងក្រោម៖

❖ ទិន្នន័យបឋម (Primary Data)

- បទសម្ភាសន៍ :- លោកគ្រូនៅអង្គការដើម្បីភាពញញឹមនៃកុមារ
  - សិស្សដែលបានបញ្ចប់ការសិក្សា
  - សិស្សដែលកំពុងសិក្សា

❖ ទិន្នន័យទី២ (Secondary Data) :

- ទិន្នន័យទាំងឡាយដែលទទួលបានពីអង្គការ និងគេហទំព័ររបស់អង្គការ
- ឯកសារទ្រឹស្តីដែលពាក់ព័ន្ធនឹងប្រធានបទ តាមគេហទំព័រនានាក្នុងអ៊ីនធើណេត និងសៀវភៅផ្សេងៗនៅក្នុងបណ្ណាល័យនានា
- សារណា និងរបាយការណ៍កម្មសិក្សារបស់សិស្សច្បង

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវក្រោមប្រធានបទ "ប្រសិទ្ធភាពនៃការអប់រំករណីអង្គការដើម្បីភាពញញឹមនៃកុមារ" ត្រូវបានបែងចែកជារចនាសម្ព័ន្ធដូចខាងក្រោម ៖

សេចក្តីផ្តើម

- លំនាំបញ្ហា
- ចំណោទបញ្ហា
- គោលបំណងនៃការស្រាវជ្រាវ
- សារៈសំខាន់នៃការស្រាវជ្រាវ
- ទំហំ និងដែនកំណត់
- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដែលក្នុងនោះផងដែរយើងមាន ៣ជំពូកធំៗទៀតដូចជា ៖

- នៅក្នុង**ជំពូកទី១** ជាជំពូកដែលរំលឹកទ្រឹស្តីផ្សេងៗ ដែលជួយគ្រាំទ្រប្រធានបទ។ ជំពូកនេះពិតជាមានសារៈសំខាន់ ដែលបានធ្វើការពិពណ៌នាអំពី ប្រវត្តិនៃការអប់រំរបស់ប្រទេសកម្ពុជា និងគោលនយោបាយផ្សេងៗ
- នៅក្នុង**ជំពូក២** បានបង្ហាញពីស្ថានភាពទូទៅរបស់អង្គការ និងសកម្មភាពផ្សេងៗនៃការអប់រំ និងបណ្តុះបណ្តាល ភាពជាដៃគូរក្នុងការជួយសិស្សានុសិស្ស ព្រមទាំងទិន្នន័យផ្សេងៗ

- នៅក្នុង**ជំពូក៣** ធ្វើការវិភាគលើសកម្មភាពរបស់អង្គការដោយធៀបនឹងទ្រឹស្តី បន្ទាប់មកធ្វើការងារបញ្ចេញមតិយោបល់។
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ដែលធ្វើការបង្រួបបង្រួម

# ជំពូកទី១

# រំលឹកទ្រឹស្តីពាក់ព័ន្ធ

# ជំពូកទី១

# រំលឹកទ្រឹស្តីពាក់ព័ន្ធ

## ១.១ សញ្ញាណរួមនៃប្រធានបទ

**និយមន័យ ៖** ប្រសិទ្ធភាព គឺបានមកពីពាក្យ ប្រសិទ្ធ + ភាព ដែលពាក្យថា **ប្រសិទ្ធ** ថ្នាក់ពាក្យជាកិរិយាស័ព្ទ និងគុណនាមមានន័យថា "ដែលតាក់តែង ដែលធ្វើឲ្យសម្រេចបាន ធ្វើឲ្យពូកែ ធ្វើឲ្យមានសិរីសួស្តីជោគជ័យ" ចំណែងពាក្យថា **ភាព** វិញ មានថ្នាក់ពាក្យជានាមមានន័យថា "បែបលំនាំ ទម្រង់ សណ្ឋាន ទ្រង់ទ្រាយ"។[1]

ការអប់រំ គឺជាវិធីចាត់ចែងបណ្តុះបណ្តាល និងបង្រៀនអ្នករៀនសូត្រ និងការអនុវត្តនៃវិធីគរុកោលស្យមួយនៃការស្រាវជ្រាវទ្រឹស្តី និងជាក់ស្តែងទាក់ទងនឹងការបង្រៀន និងការរៀន ដោយប្រើប្រាស់លើមុខវិជ្ជាផ្សេងៗដូចជាចិត្តវិទ្យា ទស្សនៈវិទ្យា វិទ្យាសាស្ត្រ កុំព្យូទ័រ ភាសាវិទ្យា ប្រសាទវិទ្យា សង្គមវិទ្យា និងមនុស្សវិទ្យា[2]។

ការអប់រំក្នុងច្បាប់ស្តីពីការអប់រំ សំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬការបណ្តុះបណ្តាលកាយសម្បទា សតិបញ្ញានិងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឲ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឲ្យក្លាយខ្លួនជាបុគ្គលដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក[3]។

ការអប់រំ គឺជាការហាត់ចិត្ត បង្វឹកចិត្ត ជួសជុលចំពោះវិជ្ជា ឬកិរិយាមារយាទ ហ្វឹកហ្វាត់ឲ្យស្ទាត់ជំនាញជាងមុន កែឲ្យបានល្អប្រពៃជាងមុនជាលំដាប់ ខំប្រឹងបំពេញនិស្ស័យឲ្យបរិបូរណ៍ ខំសាងសន្សំបុណ្យកុសលរក្សាទុកពុំឲ្យមានថ្នាំងថ្នាក់[4]។

ដូចនេះពាក្យថាប្រសិទ្ធភាពនៃការអប់រំ គឺមានន័យថាដំណើរការ ឬជាបែបលំនាំនៃការបណ្តុះបណ្តាល ការបង្រៀននិងការរៀន ដោយប្រើប្រាស់លើមុខវិជ្ជាផ្សេងៗ ព្រមទាំងការបណ្តុះបណ្តាលកាយសម្បទា សតិបញ្ញានិងសីលធម៌ ការហាត់ចិត្ត បង្វឹកចិត្ត កិរិយាមាយាទ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឲ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃឲ្យសម្រេចបាន ឲ្យពូកែ ដើម្បីក្លាយខ្លួនជាបុគ្គលដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

---

[1] វចនានុក្រមខ្មែរភាគទី១, ទំព័រទី ៥១៨ និង៥១១, ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧

[2] http:bit.ly/1IG6AqN ដកស្រង់ថ្ងៃទី ១០ មិថុនា ឆ្នាំ ២០១៤

[3] ច្បាប់ស្តីពីការអប់រំ រាជកិច្ច ទំព័រ ៩៨០២

[4] ដងស្រង់ចេញពីវចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ ព.ស ២៥១១, គ.ស ១៩៦៧

# ១.២ ស្ថានភាពទូទៅនៃការអប់រំនៅក្នុងប្រទេសកម្ពុជា

## ១.២.១ ប្រវត្តិនៃការអប់រំ

ក្នុងសម័យហ្វូណន ចេនឡា អង្គរ និងសម័យលង្វែក ការអប់រំខ្មែរមិនទាន់មានកម្មវិធី និងគោលដៅប្រាកដប្រជាឡើយ។ គោលបំណងនៃការអប់រំនាសម័យនោះមានសភាពស្រពិចស្រពិលណាស់។ ឯកសារ និងកម្មវិធីសិក្សាគ្មានបន្សល់ទុកជាភស្តុតាងក្នុងការស្រាវជ្រាវឲ្យសំបូរបែបបានឡើយ។

### ១.២.១.១ សម័យអង្គរ (គ.ស ៨០២ – ១៤៣២)

គេមិនបានដឹងច្បាស់ពីគោលការណ៍អប់រំក្នុងសម័យនេះបានឡើយ ប៉ុន្តែសិលាចារឹកលើជញ្ជាំងប្រាសាទនានា ដែលជាប្រាសាទដ៏ស្កឹមស្កៃធ្វើឲ្យវិស្វករ ស្ថាបត្យករនាសម័យនោះ កោតស្ញប់ស្ញែងអាចបញ្ជាក់បានថា មធ្យោបាយអប់រំខ្មែរមានតាំងពីពេលនោះមក។ គេអាចសន្និដ្ឋានបានថា ការអប់រំខ្មែរក្នុងសម័យនោះមានច្រើនវិស័យ អក្សរសាស្ត្រ សិល្បវិជ្ជា សាសនា សិប្បកម្ម សង្គមកិច្ច។ នេះជាស្នាដៃដ៏ថ្លៃថ្លារបស់បុព្វបុរសខ្មែរ ទុកជាកេរដំណែលឲ្យកុលបុត្តកុលធីតាខ្មែរជំនាន់ក្រោយ និងធ្វើឲ្យពិភពលោកកោតស្ញប់ស្ញែងរហូតដល់សព្វថ្ងៃនេះ។ ប៉ុន្តែគេនៅមិនទាន់ដឹងច្បាស់លាស់ថា តើបុព្វបុរសខ្មែរសម័យនោះ អប់រំកូនចៅនៅក្នុងសាលារៀន ឬ ក្នុងគ្រួសារ? ឬមានមជ្ឈមណ្ឌលឬទេ? ព្រះសង្ឃខាងព្រហ្មញ្ញសាសនា ជាអ្នកអប់រំឬ?

នៅក្នុងសម័យអង្គរមានមហាវិទ្យាល័យ និងសាកលវិទ្យាល័យដែលជាថ្នាក់សម្រាប់បណ្តុះបណ្តាលចំណេះវិជ្ជាសព្វសារពើ។ យោងតាមចំនួន និងទំហំនៃប្រាង្គប្រាសាទជាច្រើន និងក្បាច់ចម្លាក់ទាំងឡាយឃើញថា ក្នុងសម័យអង្គរសំបូរទៅដោយអ្នកប្រាជ្ញជាច្រើនមាន ស្ថាបត្យករ វិស្វករ ជាងចម្លាក់ និងសិល្បៈករ។ ទន្ទឹមនឹងនេះដែរ គេជឿថា មានអ្នកចេះដឹងជាច្រើនតាមមុខជំនាញបន្ទាប់បន្សំដ៏ចាំបាច់ថែមទៀតនៅក្នុងមជ្ឈដ្ឋានប្រជារាស្ត្រដូចជា គណិតវិទ្យា អក្សរសាស្ត្រ តារាវិទ្យា ហោរាសាស្ត្រ គ្រូពេទ្យជាដើម។ ដូច្នេះដើម្បីផ្ទេរចំណេះដឹងពីជំនាន់មួយទៅជំនាន់មួយទៀត លុះត្រាតែមានការអប់រំ និងការបង្ហាត់បង្រៀនសិស្សទៅតាមជំនាន់តៗគ្នា ហើយទន្ទឹមនឹងនេះ ពិតជាមានសាលារៀន រោងជាង តាមបែបណាមួយជាមិនខាន។ សម័យអង្គរពិតជាមានសាលារៀនរហូតដល់កម្រិតឧត្តមសិក្សា ព្រោះការកសាងបដិមាករ ចម្លាក់ ក្បាច់ក្រឡោទាប សិលាចារឹក សុទ្ធតែចេញពីវិស្វករ ស្ថាបត្យករ បណ្ឌិត អ្នកប្រាជ្ញ ដែលមានកម្រិតយល់ដឹងខ្ពស់ទើបអាចកសាងជាប្រាសាទដ៏ស្កឹមស្កៃបាន។ម្យ៉ាងទៀតគួរចាប់អារម្មណ៍ថា សិលាចារឹកសម័យនោះសុទ្ធតែអួតសរសើរពីគុណសម្បត្តិខាងផ្លូវបញ្ញាញាណ ចំណេះដឹង ចំណេះធ្វើ បទពិសោធន៍

និងផ្នែកសីលធម៌ របស់តួអង្គនានា ជាអ្នកប្រាជ្ញបណ្ឌិត ជានាម៉ឺនសព្វមុខមន្ត្រី ជាអ្នកមានស្តុកស្តម្ភ ជាព្រះមហាក្សត្រ ឬជារាស្ត្រ។ ហើយទន្ទឹមនឹងនេះដែរ គេអាចសន្និដ្ឋានបានថា ខ្មែរសម័យអង្គរពិតជាចេះឲ្យតម្លៃទៅលើ បញ្ញវន្ត អ្នកប្រាជ្ញបណ្ឌិត សាស្ត្រាចារ្យ ស្ថាបត្យករ វិស្វករ ចិត្តគំនិត សីលធម៌ បុណ្យសក្តិ និងសម្ភារៈ ពិតប្រាកដមែន។ ទាំងនោះសុទ្ធតែកើតចេញពីប្រព័ន្ធនៃការអប់រំនាសម័យអង្គរ។

អ្នកប្រាជ្ញ និងអ្នកកវីដ៏ល្បីឈ្មោះនៅសម័យនោះមានដូចជា៖

- ព្រឹទ្ធឥន្ទ្រវរ្ម័ន : ជាអ្នកប្រាជ្ញផង ជាមេទ័ពដ៏ខ្លាំងពូកែផង
- សិវកតវលិយៈ : ជាអ្នកប្រាជ្ញខាងចំណេះដឹងទូទៅ និងនយោបាយ ហើយជាទីប្រឹក្សាជំនិតរបស់ព្រះប្រាទវរ្ម័នទី២
- ព្រះហិរនីយធម្មៈ ជាអក្កប្រាជ្ញខាងគម្ពីរព្រះឥសូរ និងពិធីបូជាទេវរាជ និងជាទីព្រឹក្សាជំនិតរបស់ព្រះបាទជ័យវរ្ម័នទី២
- ព្រាហ្មណ៍សិវសោម និងព្រាហ្មណ៍សិវៈ : អ្នកប្រាជ្ញខាងសាសនាព្រាហ្មណ៍ក្នុងការជ្រើសរើសព្រះមហាក្សត្រឲ្យឡើងគ្រងរាជសម្បត្តិ
- ព្រះបាទយសោវរ្ម័នទី១ និងព្រះអគ្គមហេសីព្រះនាងឥន្ទ្រទេវី : ជាអ្នកប្រាជ្ញខាងស្ថាបត្យកម្ម និងអ្នកប្រាជ្ញដ៏កំពូលដែលកសាងនគរធំមុនគេបង្អស់
- បណ្ឌិតសិវសោម : ជាអ្នកសិលាចារឹកនៅប្រាសាទកណ្តោដើម និងសិលាចារឹកពស់កេងកងនាភ្នំគូលេន
- ព្រះនាងឥន្ទ្រទេវី : ជាអ្នកប្រាជ្ញខាងអក្សរសាស្ត្រ និងជាសកលវិទ្យាធិកានៃមហាវិទ្យាល័យជាន់ខ្ពស់នៅវត្តជ័យស្រី
- បណ្ឌិតសិវាចារ្យៈ ជាអ្នកប្រាជ្ញនិងជាអធិការត្រួតត្រាខាងផ្នែកសីលធម៌ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ និងព្រះបាទសុរិយាវរ្ម័នទី១។

ការសិក្សាពីសម័យកាលមួយទៅសម័យកាលមួយទៀត ជាការអនុវត្តវិធីសាស្ត្រប្រហាក់ប្រហែលគ្នា ចាប់តាំងពីសម័យនគរភ្នំមកដល់សម័យអង្គរ ពួកព្រាហ្មណ៍ ជាអ្នកដើរតួសំខាន់ណាស់នៅក្នុងវិស័យអប់រំ រីឯខាងព្រះពុទ្ធសាសនាវិញ ព្រះសង្ឃជាអ្នកដើរតួសំខាន់។[5]

[5] ម៉ុញ សារី ដើម្បីយល់កាន់តែច្បាស់អំពីអង្គរ ១៩៩៩ Georges Coedes-194

### ១.២.១.២ សម័យលង្វែក និងឧដុង្គ គ.ស ១៤៣២ -១៨៦៣

ក្នុងសម័យលង្វែក ការសិក្សាមិនសូវមានដំណើរការរីកចម្រើនទេ ដោយប្រទេសខ្មែរកើតមានចម្បាំងរាំងជល់ជាមួយសៀម និងយួនជាច្រើនលើកច្រើនសារ។ ការបែកក្រុងលង្វែកនាឆ្នាំ ១៥៩៣ ធ្វើឲ្យវប្បធម៌អប់រំខ្មែរត្រូវចុះខ្សោយយ៉ាងខ្លាំង ព្រោះកងទ័ពសៀមបានដុតបំផ្លាញ និងប្លន់យកគម្ពីរសិក្សាខាងផ្លូវលោក និងខាងផ្លូវធម៌ពីប្រទេសខ្មែរ យកទៅតម្កល់ទុកក្នុងប្រទេសសៀម។ សាសនា ជាគោលការណ៍មួយយ៉ាងសំខាន់ ក្នុងប្រវត្តិសាស្ត្រនៃការអប់រំខ្មែរ។ វត្តអារាមជានិមិត្តរូប និងជាកន្លែងនៃព្រះពុទ្ធសាសនាផង និងជាកន្លែងអប់រំកូនខ្មែរផង។ ហេតុនេះហើយ បានជាប្រជាពលរដ្ឋខ្មែរនាសម័យលង្វែក មួយភាគយ៉ាងហោចណាស់ក៏ចេះអាន ចេះសរសេរ ចេះលេខបន្តិចបន្តួចដែលចាត់ទុកជាប្រជាជាតិមួយ មានអ្នកល្ងង់ខ្លៅភាគតិច។ មិនតែប៉ុណ្ណោះសោតក្នុងជំនាន់នោះព្រះសង្ឃមានលទ្ធភាពផ្តល់តម្រិះវិជ្ជាខាងផ្នែកប្រតិបត្តិបានខ្លះដែរដូចជា ជាងឈើ ជាងចម្លាក់ ជាងមាស ជាងទង ជាងសង់ផ្ទះ។ល។ ខាងផ្នែកនេះ ក្មេងអាចរៀនបានតែមួយពេលទេ គឺពេលរសៀល ពីព្រោះពេលព្រឹក ក្មេងជាប់រវល់តាមព្រះសង្ឃនិមន្តទៅបិណ្ឌបាត្រ។

**វិធីសាស្ត្រអប់រំ**

វិធីសាស្ត្រអប់រំ គឺការច្រកតម្រិះទាំងអម្បាលមាណ ទៅក្នុងខួរក្បាលក្មេងតែម្តងដោយគ្រូគ្មានឲ្យក្មេងមានការត្រិះរិះគិតពិចារណាតាមបញ្ញាញាណរបស់ក្មេងឡើយ។ គេបង្ខំឲ្យក្មេងទន្ទេញចាំមាត់ ទាំងងឹតងងល់ ជួនកាលក្មេងគ្មានយល់ពីអ្វីៗ ដែលវាសូត្រទន្ទេញចាំស្ទាត់ផ្ទាល់មាត់ផង។ អត្ថន័យ អត្ថរូប អត្ថរសនៃអត្ថបទ រឿងព្រេង អក្សរសាស្ត្រ ច្បាប់ផ្សេងៗ។ល។ ក្មេងគ្មានបានទាញយកឧត្តមគតិ ពិចារណាឲ្យបានច្បាស់លាស់ឡើយ។

- ខាងផ្នែកវិន័យ គេបង្ខំឲ្យមានការគោរព ការបំបាក់ស្បាត រហូតទាល់តែក្មេងលេងចង់ហ៊ានមើលមុខគ្រូ ជួនកាលរហូតដល់មានការដាក់ទណ្ឌកម្មផ្ទាល់ខ្លួនផងក៏មាន។
- ក្មេងប្រុសខ្លះត្រូវស្នាក់អាស្រ័យនៅក្នុងវត្តប្រហែលពី ៦ ទៅ ១០ឆ្នាំ។ ក្រោយពីបានទទួលការអប់រំដូចជាបានរៀបរាប់ខាងលើ ក្មេងចាកចេញពីវត្ត ទៅរស់នៅក្នុងគ្រួសាររបស់ខ្លួនវិញដើម្បីប្រកបការងារចិញ្ចឹមជីវិត។ ក្មេងខ្លះទៀតចូលសាងផ្នួស ក្នុងព្រះពុទ្ធសាសនាអស់រយៈពេលច្រើនឆ្នាំ។ លុះលាចាកផ្នួសមកវិញ គេឲ្យនាមថា បណ្ឌិត ឬអន្ទិតនេះឯង ហើយបានរៀបអាពាហ៍ពិពាហ៍ ប្រកបរបររស់នៅជាពលរដ្ឋខ្មែរតរៀងទៅ។

**សម្ភារៈសិក្សារបស់សិស្សសម័យបុរាណ**

ក្នុងសម័យបុរាណ បុព្វបុរសយើងបានប្រើប្រាស់សម្ភារៈសិក្សាជាច្រើនបែបយ៉ាងដើម្បីនឹងរៀន

អក្សរសាស្ត្រ ឬសរសេរ គឺក្តារខៀនសរសេរ ក្តារខៀនច្បាប់ ក្តារឆ្នួន ដីសថ្ម ស្លឹករឹត ដែកចារ ដងប្រកៃ ឬដងប៉ាកកៃ និងទឹកខ្មៅចិន។ល។ ប្រដាប់ប្រដាទាំងនេះមានទ្រង់ទ្រាយប្លែកៗគ្នា ហើយរៀបចំឡើងដោយវត្ថុធាតុផ្សេងៗទៀតផង។[6]

ជាទូទៅការសិក្សានៅសម័យលង្វែក និងសម័យឧដុង្គមានបួនជាន់៖

**ជាន់ទី១**: *គឺរៀនសរសេរ* កាលណាកុមារដឹងក្តីហើយមានអាយុរវាងពី ៧ទៅ១០ឆ្នាំ មាតាបិតាតែងនាំកូនឲ្យទៅសិក្សានៅវត្ត រៀបចំខោអាវ និងខ្លួនប្រាណកូន ហើយរើសរកថ្ងៃល្អដើម្បីយកកូនឲ្យទៅនៅវត្ត។ ដោយជាន់ទី១ គឺកុមារត្រូវរៀនសរសេរ រៀនអាន និងទន្ទេញ ឲ្យបានចាំច្បាស់លាស់ពិតប្រាកដ។

**ជាន់ទី២**: *គឺរៀនមើលសាស្ត្រាច្បាប់* សុទ្ធតែជាពាក្យកាព្យ ដូចជាសាស្ត្រាច្បាប់កេរកាល ច្បាប់ប្រុស ច្បាប់ស្រី រាជនេតិ(ច្បាប់ព្រះរាជសម្ភារ)។ លោកគ្រូនាំសិស្សឲ្យរៀនអាន ចេះអានត្រឹមត្រូវច្បាស់លាស់តាមតួអក្សរ។ បន្ទាប់មកត្រូវអានដោយខ្លួនឯងឲ្យទាល់តែចាំមាត់ដោយមិនចាំបាច់មើលអក្សរទៀត និងលោកគ្រូពន្យល់សេចក្តីក្នុងសាស្ត្រាច្បាប់នោះថែមទៀតព្រោះច្បាប់មានអាថ៌កំបាំងជ្រៅជ្រះណាស់។

**ជាន់ទី៣** : *រៀនមើលសាស្ត្រាល្បែង* មានច្រើនយ៉ាង គឺវាជាអត្ថបទកំណាព្យ ដែលលោកគ្រូតម្រូវឲ្យសិស្សអានធ្វើបទផ្សេងៗដូចជា បទកាកគតិ បទព្រហ្មគិត បទភុជង្គលីលា បទពំនោល។ល។ សាស្ត្រាល្បែងមានច្រើនច្បាប់ ដូចសាស្ត្រាច្បាប់ដែរគឺ សាស្ត្រាជុចនិងត្រី សុបិន្តកុមារ ហង្សយន្តវិមានចន្ទ សង្ខសិល្ប៍ជ័យ ជ័យទត្ត សព្វសិទ្ធី ។ល។ បើលោកគ្រូឃើញថា សិស្សចេះអានធ្វើបទបានល្អហើយត្រឹមត្រូវហើយ លោកឲ្យសិស្សនោះឡើងជាន់ទី៤។

**ជាន់ទី៤**: *រៀនមើលសាស្ត្រទេសន៍* អាចមានលក្ខណៈផ្សេងពីសាស្ត្រាល្បែង ជាបទ ឬជាពាក្យធម្មតា ជាសេចក្តីមួយបែបក្នុងកាព្យរាយដែរ។ ប៉ុន្តែមិនមែនជាពាក្យរាយធម្មតាទេ ជាពាក្យរាយជូនគ្នា ជូនរណ្តំគ្នា រដឹកទៅ ហៅថាកម្រងកែវ។ លោកគ្រូបង្រៀនសិស្ស អោយរៀនអានតាមបែបទេសន៍ គេហៅថា រៀនទេសន៍។ សាស្ត្រាទេសន៍មានដូចជា សាស្ត្រាអានិសង្ស អានិសង្សចម្លងបុណ្យ អានិសង្សខ្មោច។ល។ [7]

អ្នកប្រាជ្ញ និងអ្នកនិពន្ធដែលមានស្នាដៃដ៏ល្បីល្បាញមានដូចជា៖

- បណ្ឌិតជ័យនន្ទ៖ ស្នាដៃសិលាចារឹកអង្គរ

[6] ប្រវត្តិនៃការអប់រំនៅកម្ពុជា របស់លោក យ៉ង ធី ១៩៩៧

[7] ដងស្រង់ពីទស្សនាវដ្តីខេមយានកម្ម លេខ៧ ឆ្នាំទី១

- អ្នកប៉ាង៖ ល្បើកអង្គរវត្ត
- ព្រះរាជសម្ភារ៖ កាព្យនិរាស ច្បាប់ព្រះរាជសម្ភារ
- ឧកញ៉ាកោសិធិបតីកៅ៖ រឿងក្រុងសុភមិត្រ
- ឧកញ៉ាព្រះឃ្លាំងនង៖ ច្បាប់សុភាសិត លោកនេយ្យជាតក រឿងបុញ្ញាសារសិរសា រឿងភាគកុមារ រឿងវរនេត្រវរនុជ
- ព្រះបាទអង្គឌួង៖ និពន្ធរឿងកាកី ច្បាប់ស្រីអង្គឌួង
- ព្រះបទុមបារមីពេជ្រ៖ របាក្សត្រស្រុកខ្មែរ
- ឧកញ៉ាចក្រីកែវ៖ រឿងដាវរឿង
- ឧកញ៉ាធិបតី យ៉ែម៖ និពន្ធរឿងវិមានចន្ទ
- ឧកញ៉ាសុន្ទរវោហារ ម៉ុកៈ៖និពន្ធរឿងទេវន្ទ។

**១.២.១.៣ វិស័យអប់រំក្នុងសម័យអាណានិគមនិយមបារាំង**

ក្រោយយប់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ រាជធានីភ្នំពេញត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់ទេសាភិបាលជាន់ខ្ពស់បារាំង។ ទេសាភិបាល ជាប្រធានក្រុមប្រឹក្សារាជធានីដែលមានសមាសភាព ១២រូប ក្នុងនោះជនជាតិបារាំង៦រូប ខ្មែរ៣រូប និងយួន៣រូប។

មកដល់ឆ្នាំ១៨៩៧ បារាំងទាមទារឲ្យព្រះមហាក្សត្រចុះព្រះហត្ថលេខាលើរាជកិច្ចមួយមានន័យថា ព្រះមហាក្សត្រសោយរាជ្យ ប៉ុន្តែមិនត្រួតត្រាទេ។

ដើម្បីងាយស្រួលក្នុងការកសាងមនុស្សសម្រាប់បម្រើរដ្ឋ អាណាព្យាបាលបារាំងបានបង្កើតគ្រឹះស្ថានសិក្សាខ្លះៗដូចជា ៖

- សាលាបឋមសិក្សា ៖ ឆ្នាំ១៩១១ មានសាលា៣០ ហើយនៅឆ្នាំ១៩៣៧ មានសាលា៨១៣។
- សាលាមធ្យមសិក្សា ៖ ឆ្នាំ១៩១១ មានអនុវិទ្យាល័យព្រះស៊ីសុវត្ថិមួយ។ ឆ្នាំ១៩៣៥ អនុវិទ្យាល័យនេះ ត្រូវបានបង្កើតឲ្យទៅជាវិទ្យាល័យស៊ីសុវត្ថិ។
- សាលាបច្ចេកទេស ៖ ឆ្នាំ១៩១៧ មានសាលាអប់រំបច្ចេកទេសសិល្បៈ និងសិប្បកម្មមួយគឺសាលារចនា។

នៅឆ្នាំ ១៩៣៧ ក្នុងចំណោមនិស្សិតមហាវិទ្យាល័យឥណ្ឌូនៅហាណូយ ៦៣១នាក់ មាន ខ្មែរ ៣ នាក់។ ឆ្នាំ១៩៣៩ បុគ្គលិកសុខាភិបាលនៅក្នុងប្រទេសកម្ពុជាទាំងមូលមានគ្រូពេទ្យ ថ្នាក់មធ្យមជាជនជាតិបារាំងចំនួន៥នាក់ និងខ្មែរ៨នាក់ ហើយនិងបុគ្គលិកពេទ្យចំនួន១៥០នាក់។

### ១.២.១.៤ ចុងសម័យអាណានិគមនិយមបារាំង និងបន្ទាប់ពីទទួលបានឯករាជ្យ

នៅចុងសម័យអាណានិគមនិយម ពួកបារាំងបានកសាងសាលារៀនមួយចំនួនសម្រាប់ផលិតបុគ្គលិក បម្រើរបបការិយាល័យអាណានិគមនិយមរបស់ខ្លួន។ នោះជាឱកាសដ៏ស្តួចស្តើងមួយសម្រាប់ពលរដ្ឋកម្ពុជា មួយភាគតូចឈានទៅស្គាល់ពន្លឺចំណេះដឹង វិទ្យាសាស្ត្របច្ចេកទេសនៃពិភពលោក។

មកដល់ឆ្នាំ១៩៥២ នៅព្រះរាជាណាចក្រកម្ពុជា មានសាលាមធ្យមសិក្សាទុតិយភូមិមួយកន្លែង គឺវិទ្យាល័យស៊ីសុវត្ថិ និងអនុវិទ្យាល័យ៣កន្លែងគឺ អនុវិទ្យាល័យនារី (ព្រះនរោត្តម) អនុវិទ្យាល័យកំពង់ចាម (ព្រះសីហនុ) អនុវិទ្យាល័យបាត់ដំបង (ព្រះមុនីវង្ស) និងសាលាគរុវិជ្ជាមួយនៅទីរាជធានីភ្នំពេញ។ ពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៣ មានបើកអនុវិទ្យាល័យបន្ថែមទៀតនៅខេត្តសៀមរាប កំពត និងស្វាយរៀងហើយនៅឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៥៤ ក៏មានបើកអនុវិទ្យាល័យមួយទៀតនៅ ខេត្តតាកែវ។

តារាងបង្ហាញចំនួនសិស្សសរុបនៅមធ្យមសិក្សា

| ឆ្នាំសិក្សា | ចំនួនសិស្សសរុបក្នុងគ្រឹះស្ថានមធ្យមសិក្សា |
|---|---|
| ១៩៥២ | ១៩៥២នាក់ |
| ១៩៥៣ | ២២០៣នាក់ |
| ១៩៥៤ | ២៩៤២នាក់ |

ផ្នែកបឋមសិក្សានៃគ្រឹះស្ថានសិក្សាខ្មែរ

| ឆ្នាំសិក្សា | ចំនួនសាលា | ចំនួនសិស្ស |
|---|---|---|
| ១៩៥២ | ១៩៧២ | ៧៨០៩៥ |
| ១៩៥៣ | ១៩៣១ | ៧៦៣០៧ |
| ១៩៥៤ | ១៩៣៣ | ៧៥៥២១ |

ការថយចុះចំនួនសាលាក្នុងឆ្នាំ១៩៥៤ បណ្តាលមកពីសាលាខ្លះបានប្រែទៅជាសាលាបឋមសិក្សាជាន់ដំបូងបារាំង–ខ្មែរ។ ក្នុងរយៈពេល៣ឆ្នាំ សាលាបឋមសិក្សាជាន់ដំបូងដែលបានកែប្រែប្រមាណ១៩៦ សាលាថ្មីដែលបង្កើតនៅចុងកាត់មាត់ញកមាន៩៨។ សាលាបឋមសិក្សបារាំង–ខ្មែរនាពេលនោះមាន៖

| ឆ្នាំសិក្សា | ចំនួនសាលា | ចំនួនសិស្ស |
|---|---|---|
| ១៩៥២ | ៧៥១ | ១១៩៨១១ |
| ១៩៥៣ | ៧៨០ | ១៣៦២៤៤ |
| ១៩៥៤ | ៧៨២ | ១៧៦៥២១ |

ក្នុងរយៈពេលព្រះរាជាបូជនីយកិច្ច (ចំនួន៣ឆ្នាំ) បឋមសិក្សា បារាំង–ខ្មែរ កើនចំនួនដល់ទៅ ១៩៦ និងសិស្ស ៥៣.៥៥៨នាក់។ នៅឆ្នាំ១៩៥៦ នៅព្រះរាជាណាចក្រកម្ពុជាមានសាលាជំនួយស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋៈ

- សាលាធ្វើពីឥដ្ឋ និងស៊ីម៉ង់មានចំនួន១៧៩ និងមានថ្នាក់ចំនួន៩៤៧
- សាលាធ្វើពីគ្រឿងឈើ ប្រក់ក្បឿងមានចំនួន២៣៩ មានថ្នាក់ចំនួន ១០៧២
- សាលាប្រក់ស្លឹកមានចំនួន៥២៩ មានថ្នាក់ចំនួន១២៣៩

ការធ្វើឲ្យកម្រិតបឋមសិក្សា មានសភាពទាន់សម័យៈ នៅបវេសនកាលឆ្នាំសិក្សា១៩៥៣ គម្រោងការក្រសួងអប់រំជាតិបានរៀបចំឲ្យមានការសិក្សាជាក្រុម និងមានមជ្ឈមណ្ឌលសិក្សាល្អ ត្រកាលនិងសុខដុម។ សាលារៀនមានរបងពទ្ធ័ជុំវិញ មានដាំដើមឈើម្លប់ត្រឈឹងត្រឈៃ និងមានប្លង់ធ្វើសួនច្បារ ឬសួនបន្លែ ហើយសាលាខ្លះទៀតមានអន្តេវាសិកដ្ឋាន មានទីធ្លាកីឡា មានអណ្តូងទឹក ប្រកបដោយអនាម័យ–ល–។

ការកើនឡើងចំនួនសិស្សនាំឲ្យមានបញ្ហាខ្វះគ្រូ ពេលនោះរាជរដ្ឋាភិបាលមានការដោះស្រាយៈ

សម្រាប់សាលាបឋមសិក្សាខ្មែរ និងបារាំង–ខ្មែរ រាជរដ្ឋាភិបាលបានធ្វើពលីកម្មយ៉ាងធំ ដោយជ្រើសរើសគ្រូយកមកអប់រំ និងចំណាយបៀវត្សជូន។ តាមលំដាប់ឆ្នាំការជ្រើសរើសគ្រូយកមកបម្រើការបានៈ

| ឆ្នាំ | ចំនួន |
|---|---|
| ១៩៥២ | ៧៣០នាក់ |
| ១៩៥៣ | ៦៨៥នាក់ |
| ១៩៥៤ | ១០៣៥នាក់ |

គោលនយោបាយពេលនោះបង្ហាញៈ

- សម្រាប់មធ្យមសិក្សាៈ រាជរដ្ឋាភិបាលមានវិធានការផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនជូនគ្រូ ដើម្បីលើកទឹកចិត្ត សាស្ត្រចារ្យបារាំងល្អៗ ដែលបានមកបម្រើការនៅប្រទេស

- មានការទាក់ទងផ្ទាល់ រវាងផ្នែកវប្បធម៌ជាមួយប្រទេសបារាំងដោយមិនបាច់សួរនាំបេសកកម្មវប្បធម៌បារាំង នៅស្រុកយួន។
- ឲ្យវង្វាន់សាស្រ្តាចារ្យ ដែលផ្លាស់មកបម្រើការងារនៅស្រុកយើង
- ឲ្យផ្ទះនៅដោយឥតយកថ្លៃឈ្នួល
- រៀបចំគ្រឿងសង្ហារឹមឲ្យប្រើប្រាស់
- ចេញថ្លៃទឹក ថ្លៃភ្លើង
- រៀបចំវិធីសាស្រ្តថ្មីៗនៅក្នុងសាលា និងក្នុងរបៀបរៀបចំការសិក្សាចេញផ្សាយសៀវភៅសិក្សាថ្មីៗ រៀបចំបណ្ណាល័យ បបញ្ចាំងភាពយន្តនៅតាមសាលាបន្ថែមរៀន ភាសាបរទេស នៅថ្នាក់មធ្យមសិក្សា គ្រោងបើកថ្នាក់មត្តេយ្យសិក្សា និងថ្នាក់អប់រំមនុស្សចាស់។

ចំពោះការអប់រំមូលដ្ឋាន តាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់នៃព្រះករុណានរោត្តមសីហនុ និងតាមសេចក្តីរាយការណ៍របស់អង្គការ UNESCO ដែលមានលោកGeorges Hilodeau និងEaymond ជាសមាជិករាជរដ្ឋាភិបាលបានរៀបចំឲ្យមានអង្គការអប់រំមូលដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមនេះមានមុខងារដូចខាងក្រោមៈ

១. **សុខភាព** គឺរៀបចំសុខភាពប្រជារាស្រ្តនៅតាមជនបទ។

២.**កសិកម្ម** គឺណែនាំប្រជាពលរដ្ឋឲ្យស្គាល់ វិធីប្រើបច្ចេកទេសកសិកម្មផ្នែកដំណាំ ពីរបៀបថែរក្សា វិធីផ្តល់ទឹក វិធីប្រើជី ការចិញ្ចឹមសត្វ កិច្ចបង្ការ សត្វល្អិតចង្រៃ និងបសុពេទ្យ។

៣. **សិប្បិយការ** គឺណែនាំឲ្យប៉ិនប្រសប់ និងឲ្យបង្កើតឧស្សាហកម្មជំនាញដូចជាតំបាញ ធ្វើក្អម ឆ្នាំង និងជំនាងលើ។

៤.**សេដ្ឋកិច្ច** គឺណែនាំប្រជាពលរដ្ឋឲ្យស្គាល់របស់ចាំចាច់ក្នុងម្ហូបអាហារ ឲ្យចេះសន្សំសំចៃ ឲ្យចេះរៀបចំ ភូមិម្ករ ផ្ទះសំបែង គ្រឿងតុបតែងផ្ទះ គ្រឿងដាំស្លម្ហូបអាហារ គ្រឿងស្លៀកពាក់–ល–។

៥. **វប្បធម៌ និងទំនៀមទម្លាប់ប្រទេស** គឺណែនាំឲ្យស្គាល់ទំនៀមទម្លាប់ល្អរបស់ខ្មែរ ដូចជាពិធីការក្នុងវត្ត ជីវភាពក្នុងភូមិ ក្នុងទីក្រុងឲ្យស្គាល់ប្រវត្តិសិល្បៈខ្មែរ ប្រវត្តិនៃការលូតលាស់ ល្ខោនប្រជាប្រិយ ភ្លេង របាំ និងសំលៀកបំពាក់ជាតិ។

៦. **ផលិតឧបករណ៍ និងប្រើប្រាស់សំភ្ភារៈអប់រំ** គឺណែនាំឲ្យប្រជាពលរដ្ឋនិយម បែបផែនការ និងអនុវត្តប្រើ ដោយវិធីតាំងរូបថត បញ្ចាំងកុន ថតសម្លេងចាក់ឲ្យស្តាប់ បង្រៀនប្រើគ្រឿងភ្លើង (អគ្គិសនី) មានធុងអាគុយ ចង្កៀង–ល–។

បណ្តាការងារខាងក្រោមបានសម្រេចដោយៈ

- ការបង្កើតមជ្ឈមណ្ឌលអប់រំគ្រូមូលដ្ឋាន
- ការពិសោធវិធីអប់រំដោយបង្រៀន វិធីរបៀបអនុវត្ត។[8]

**១.២.១.៥ វិស័យអប់រំសម័យសង្គមរាស្ត្រនិយម**

មកដល់សម័យសង្គមរាស្ត្រនិយម ប្រទេសកម្ពុជាបានអភិវឌ្ឍលើគ្រប់វិស័យជាពិសេស វិស័យអប់រំ។ សមិទ្ធផលលើវិស័យអប់រំពីឆ្នាំ ១៩៥៥ ដល់ ១៩៦៩ បានបង្ហាញ៖

| ប្រភេទសាលា | | ចំនួនអគារ | | ចំនួនសិស្ស | |
|---|---|---|---|---|---|
| | | ១៩៥៥ | ១៩៦៩ | ១៩៥៥ | ១៩៦៩ |
| ១ | សាលាបឋមសិក្សា | ២៧៣១ | ៥៨៥៧ | ៣១១.០០០នាក់ | ១.០២៥.០០០នាក់ |
| ២ | សាលាមធ្យមសិក្សា | ១២ | ១៨០ | ៥.៣០០០នាក់ | ១១៧.០០០នាក់ |
| ៣ | សាលាបច្ចេកទេស និងវិជ្ជាជីវៈ | ៥ | ៩៩ | ៣៣៤នាក់ | ៧.៤០០០នាក់ |
| ៤ | សកលវិទ្យាល័យ មហាវិទ្យាល័យក្នុងសកលវិទ្យាល័យទាំង៩ | ០ | ៩ | ៣៤៧នាក់ | ១០.៨០០នាក់ ក្នុងមហាវិទ្យាល័យទាំង៤៨ |

បញ្ហាអ្នកឥតការងារធ្វើ បានចោទឡើងមុនឆ្នាំ១៩៧០ ការសិក្សាបានចោទធ្ងន់លើគ្រួសារក្រីក្រ ដែលមានជីវភាពដុនដាប។ ពួកគេពុំអាចបញ្ជូនកូនចៅឲ្យចូលរៀនបាន ដោយហេតុសាលារៀនមានតិចតួចនៅឆ្ងាយ គ្មានមធ្យោបាយធ្វើដំណើរ។ សាលាខ្លះចំណុះទីវត្តអារាម ផ្តល់អាទិភាពដល់សិស្សប្រុសច្រើនជាងសិស្សស្រី។ សិស្សានុសិស្ស ជួបការលំបាកគ្រប់បែបយ៉ាង ពិសេសសិស្សស្រី។ ប្រពៃណីរួមរឹតផងគួបផ្សំនឹងកត្តាអស់ទាំងនេះផង កុមារីបោះបង់ចោល ការសិក្សាពុំមានលទ្ធភាពបន្តវិជ្ជាទៅថ្នាក់លើៗបានច្រើនឡើយ។[9]

**១.២.១.៦ សម័យសាធារណរដ្ឋខ្មែរពីឆ្នាំ ១៩៧០-១៩៧៥**

ប្រទេសកម្ពុជាបានសន្តិភាព រួចផុតពីសង្គ្រាមបានតែ១៧ឆ្នាំប៉ុណ្ណោះអតីតកាលក៏វិលត្រឡប់មកវិញ។ ប្រជាជនរងភាពជូរចត់នៃសង្គ្រាមបន្ត។

[8] ប្រវត្តិសាស្ត្រនៃព្រះរាជាណាក្រកម្ពុជា របស់លោកបណ្ឌិត ឥន្ទ ឌឹមសាម៉េង ទំព័រ ៣៥០-៣៥៦

[9] ប្រវត្តសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា របស់បណ្ឌិត ឥន្ទ ឌឹមសាម៉េង ទំព័រ ៣៥៦ ដល់ ៣៥៧

សង្គ្រាមដែលបានឆាបឆេះពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥ បានសម្លាប់ប្រជាជនជាង ១.០០០.០០០នាក់ ព្រមទាំងធ្វើឲ្យអន្តរាយផ្លូវថ្នល់ និងស្ពានពី៧០% ទៅ៨០%។ វាលស្រែចំការក្លាយជាចំការមីន និងរណ្តៅគ្រាប់បែកបេ៥២។ រោងចក្រឧស្សាហកម្ម ៧៥% ត្រូវបានបំផ្លិចបំផ្លាញ ចំការកៅស៊ូត្រូវបានបង់។ គ្រឹះស្ថានសិក្សានៅតំបន់រំដោះ និងតំបន់ប្រទ្រង់ប្រទាញទាំងអស់ត្រូវបិទទ្វារ។ គ្រូ និងសិស្ស ត្រូវជំលៀសមករៀននៅតាមបណ្តាខេត្ត-ក្រុង។ ប្រការដែលធ្ងន់ធ្ងរបំផុតនោះ គឺអំពើពុករលួយ។ ការសូកប៉ាន់ និងការស៊ីសំណូក រីកដុះដាលរហូតដល់វិស័យសិក្សាធិការជាតិ។ សិស្ស និស្សិតធ្វើគ្រប់យ៉ាងដើម្បីបានសញ្ញាបត្រ មានលទ្ធភាពរៀនបន្ត និងអាចគេចផុតពីការចាប់បង្ខំឲ្យចូលទាហាន។

សង្គ្រាមបង្ហូរឈាម១៩៧០-១៩៧៥ ក្រៅពីសម្លាប់ប្រជាជនកម្ពុជាគ្រប់ភាគីជម្លោះបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គម ថែមទាំងបានបំផ្លាញឬគល់ប្រព័ន្ធអប់រំខ្ទេចខ្ទី ដូចជាសាលារៀនទាំងតាមទីប្រជុំជនទាំងតាមវត្តអារាម និងធនធានមនុស្ស-ល- ធ្វើឲ្យសង្គមជាតិទាំងមូលស្ថិតនៅក្នុងកលិយុគ។ ប្រជារាស្ត្រគិតតែភៀសខ្លួន និងពនេចរ។ កុមារា កុមារី សិស្សានុសិស្សខានទៅសាលារៀន ដោយគេចវេសពីសង្គ្រាម។ បញ្ហាគម្លាតយេនឌ័រ កាន់តែរីករលើងៗ។ សង្គមដែលរកទិសដៅពិតប្រាកដមិនឃើញ បានឈានទៅដល់ក្តីវិនាសនាចុងឆ្នាំ ១៩៧៥ ដោយក្រុមមនោគមន៍វិជ្ជាខ្មែរក្រហមមួយក្តាប់តូចឡើងកាន់អំណាច។

**១.២.១.៧ សម័យកម្ពុជាប្រជាធិតេយ្យពីឆ្នាំ ១៩៧៥-១៩៧៩**

ក្រោយពេលបញ្ចប់សង្គ្រាម៥ឆ្នាំ ១ខែ និង២០ថ្ងៃ ក្រុមប៉ុល-ពត បានរៀបចំប្រទេសឲ្យទៅជារដ្ឋរបស់កសិករ។ ពួកគេជំលៀសប្រជាជនចេញពីទីក្រុងឲ្យទៅនៅជនបទហើយបង្ខំឲ្យធ្វើការលើវាលស្រែ។ ពួកប៉ុល-ពត បង្កើតពាក្យស្លោកថា "មានស្រូវគឺមានអ្វីៗទាំងអស់"។ ពួកគេបែងចែកប្រជាជនជាបីប្រភេទគឺៈ

១.ប្រជាជនចាស់ (ពេញសិទ្ធ) គឺប្រជាកសិករទាំងអស់ដែលរស់នៅក្នុងតំបន់រំដោះ មិនបានរត់ចូលទីក្រុងកាលពីពេលសង្គ្រាម។

២.ប្រជាជនថ្មី (ត្រៀម) គឺពួកអ្នកទីក្រុង និងពួកអ្នកដែលបានភៀសខ្លួនរត់គេចពីការទម្លាក់គ្រាប់បែក និងសង្គ្រាម។

៣.ប្រជាជនផ្ញើរ គឺប្រជាជននៅខាងរដ្ឋការ លន់-នល់ មានទាហាន មន្ត្រី ព្រះសង្ឃ និងបញ្ញវន្ត។

ក្រុមប៉ុល-ពត ធ្វើការបោសសម្អាតពួកប្រភេទទី៣ ដោយចាប់យកទៅសម្លាប់ទាំងគ្រួសារ។

តាមពាក្យស្លោក "ជីកស្មៅ ជីកទាំងឫស"។ បន្ទាប់មកក៏រាលដាលដល់ប្រជាជនប្រភេទទី២ទៀត ព្រោះអ្នកទាំងនោះមានជាប់កំអែលសង្គម និងអនុធន។ លុះដល់ឆ្នាំ ១៩៧៧ ពួកប៉ុល–ពត ចាប់ផ្តើម ធ្វើទុក្ខបុកម្នេញពួកប្រភេទទី១។ ពួកប៉ុត–ពត បង្កើតជំរំឃុំឃាំងទូទាំងប្រទេស។ គេបិទទ្វារ គ្រឹះស្ថានសិក្សា ហើយកែប្រែទៅជាពន្ធនាគារ ជាបន្ទាយឬជាជង្រុកដាក់លាមកសត្វ បំផ្លាញ សម្ភារៈទាំងអស់របស់ប្រជាជន។ ពួកគេកំទេចប្រពៃណី ទំនៀមទម្លាប់ សិល្បៈវប្បធម៌ ប្រាក់កាស –ល– ចោលទាំងស្រុង។

នៅក្នុងកម្ពុជាទាំងមូល គ្មានគ្រួសារណាមួយគេចផុតពីនយោបាយប្រល័យពូជសាសន៍ របស់របបកម្ពុជាប្រជាធិបតេយ្យឡើយ។ កម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យប្រទេសជាតិធ្លាក់ក្នុង មហន្តរាយយ៉ាងជ្រៅ។ ក្រៅពីសម្លាប់ប្រជាជនគេបំផ្លាញខឿនអប់រំទុកពីររបបចាស់ទៀត។ ពេលនោះ សង្គមកម្ពុជាទាំងមូលគ្មានអ្វីជាថ្នាលបណ្តុះបណ្តាលចំណេះដឹង ដែលជាធនធានសម្រាប់មនុស្ស ជាតិឡើយ ព្រោះពួកគេមិនត្រូវការអ្នកចេះដឹង។ សង្គមពួកគេជាសង្គមគិតតែពីពលកម្ម បង្អត់ អាហារ គេមិនដែលគិតគូរបញ្ហាគម្លាតយេនឌ័រសោះឡើយ។

### ១.២.១.៨ សម័យសាធារណៈប្រជាមានិតកម្ពុជា ឆ្នាំ ៩៧៩–១៩៨៨

ក្រោយឆ្នាំ១៩៧៩ វិស័យសិក្សាអប់រំ ត្រូវបានរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា។ រដ្ឋបានរៀបចំឡើងវិញនូវប្រព័ន្ធអប់រំ យ៉ាងទូលំលាយ ពីទីក្រុងរហូតដល់ជនបទដាច់ស្រយាល។ នៅឆ្នាំ១៩៨២–១៩៨៣ យើងពិនិត្យឃើញថា ចំនួនសិស្សថ្នាក់មត្តេយ្យសិក្សា និងបឋមសិក្សាមាន ចំនួនប្រមាណ១,៥០០.០០០នាក់ សិក្សាអនុវិទ្យាល័យមានចំនួនប្រហែល ៥០.០០០នាក់ និង សិស្សថ្នាក់វិទ្យាល័យចំនួនប្រហែល២.០០០នាក់។ គ្រូបង្រៀនសម្រាប់ភូមិសិក្សាខាងលើនេះ មាន ចំនួនប្រហែល៤០.០០០នាក់។ សាលាថ្នាក់ឧត្តមសិក្សានិងមធ្យមសិក្សាបច្ចេកទេស ក៏បានបើក ទ្វារទទួលនិស្សិតឲ្យចូលរៀនជាច្រើនអ្នកផងដែរ ដូចជាសាលាគរុវិជ្ជាជាន់ខ្ពស់ វិទ្យាស្ថាន បច្ចេកទេសជាន់ខ្ពស់ មហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ និងផ្សេងៗទៀត។[10]

វិស័យអប់រំនៅសម័យនោះ មានសន្ទុះរីកចម្រើនយ៉ាងខ្លាំងក្លាពីមួយឆ្នាំទៅមួយឆ្នាំទាំង ចំណេះទូទៅ ទាំងឧត្តមសិក្សា និងទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំនួនសិស្សានុសិស្សដែល បានចូលរៀនមានកម្រិតខ្ពស់ជាងសម័យមុន។ ក្នុងឆ្នាំសិក្សា១៩៨៨–១៩៨៩ សិស្សានុសិស្សចំណេះ ទូទៅមានចំនួនរហូតដល់ ១,៧១២.៤៤០ នាក់។ ប្រព័ន្ធអប់រំចំណេះដឹងទូទៅ ត្រូវបានកែលម្អឡើង វិញ។ ការរៀនសូត្រតាមសាលាបំពេញវិជ្ជា និងក្រៅម៉ោងធ្វើការ ត្រូវបានរដ្ឋយកចិត្តទុកដាក់យ៉ាង

[10] ឥន្ទ ឪមសាម៉េង ប្រវិត្តសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ភ្នំពេញ,ឆ្នាំ២០១២ ទំពរ័ ៣៦២

ខ្លាំងក្នុងទិសដៅលើកកម្ពស់កម្រិតវប្បធម៌ជូនមន្ត្រីរាជការ បុគ្គលិកម្មករ និងកងទ័ព។ ការរៀនសូត្ររបស់ជនជាតិភាគតិចនៅភូមិភាគឥសាន្ត ក៏ត្រូវបានយកចិត្តទុកដាក់ដែរ។ ភាគអនក្ខកម្មបានធ្លងផុតជាស្ថាពរ។

គ្រឹះស្ថានឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេស មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានស្តារឡើងវិញ ហើយការទទួលសិស្សឲ្យចូលរៀនបានចំនួន ២៩.១០០នាក់ ក្នុងឆ្នាំ ១៩៨៨–១៩៨៩។ ការបណ្តុះបណ្តាលគ្រូបង្រៀន ក៏បានពង្រឹងទាំងបរិមាណ និងគុណភាព នៅគ្រប់សាលាគរុកោសល្យនៅទូទាំងប្រទេស។ ការបណ្តុះបណ្តាលក្របខណ្ឌបច្ចេកទេស ក្នុងនោះមានការបែងចែកលើ មុខជំនាញឯកទេសមួយចំនួនសម្រាប់បណ្តាក្រសួង ខេត្ត–ក្រុង ក៏ត្រូវបានដំណើរការជំហានៗ។ ការបញ្ជូនសិស្ស និស្សិតនៅក្នុងប្រទេសឲ្យទៅរៀនសូត្រនៅបរទេស ក៏មានដំណើរការល្អដំណើរល្អ។ ក្នុងរយៈពេល១០ឆ្នាំកន្លងមក ប្រទេសកម្ពុជាបានបណ្តុះបណ្តាលនិស្សិតថ្នាក់ឧត្តមបានចំនួនប្រមាណ ៨.៩៧០ នាក់ ក្នុងនោះការបណ្តុះបណ្តាលក្នុងប្រទេសបានប្រមាណ ៦.៦៤០នាក់ និងទៅសិក្សានៅបរទេសបានប្រមាណ ២.៣៣០នាក់។

តាមការស្រាវជ្រាវបង្ហាញថា ទន្ទឹមនឹងការស្តារឡើងវិញយ៉ាងរហ័សលើវិស័យអប់រំ ការបណ្តុះបណ្តាលធនធានមនុស្សនាសម័យនោះ បានជួបប្រទះការលំបាកជាច្រើនដូចជា៖

- ការវិនិយោគទុនក្នុងវិស័យអប់រំមានកម្រិតស្តួចស្តើង
- ការពង្រឹងផ្នែកបរិមាណ និងគុណភាពពុំទាន់បានសមស្រប
- កម្រិតយល់ដឹងលើមុខជំនាញរបស់គ្រូបង្រៀន និងមន្ត្រីរាជការគឺនៅមិនទាន់ឆ្លើយនឹងសំណូមពរអប់រំរបស់ប្រទេសជាតិឡើយ
- របបគោលនយោបាយចំពោះបុគ្គលិកសិក្សា ពុំទាន់ធានាបានជីវភាពសមរម្យ និងពុំទាន់អាចអូសទាញសិស្សពូកែៗ ឲ្យចូលធ្វើជាគ្រូបង្រៀនឡើយ។[11]

### ១.២.១.៩ សម័យរដ្ឋកម្ពុជា ឆ្នាំ១៩៨៩–១៩៩៣

នៅសម័យរដ្ឋកម្ពុជា យោងតាមទិន្នន័យមួយចំនួនបានបង្ហាញថា វិស័យសិក្សាអប់រំនាដំណាក់កាលនោះដំណើរការឡើងមិនទាន់បានល្អប្រសើរនៅឡើយទេ។ គ្រូបង្រៀននៅថ្នាក់បឋមសិក្សាប្រហែលជា១០% មានកម្រិតហួសពីកម្រិតបឋមសិក្សា និង២៥%មានកម្រិតវិជ្ជាមិនពេញថ្នាក់អនុវិទ្យាល័យ ហើយមានតែ ៦០% ប៉ុណ្ណោះ ដែលមានកម្រិតវិជ្ជាថ្នាក់អនុវិទ្យាល័យ។

[11] ប្រវត្តសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ដើមសតវត្សទី១ រហូតដល់ចុងសតវត្សទី២០ របស់បណ្ឌិត ឈុន ពហុ និងអនុបណ្ឌិត ងួន ហេង បោះពុម្ពលើទី១ ឆ្នា ២០១៥

ដោយឡែកអត្រាកុមារដល់វ័យមត្តេយ្យសិក្សាបានចូលរៀនប្រមាណតែ ៨%ប៉ុណ្ណោះ។ អត្រាកុមារដល់វ័យសិក្សាបានចូលរៀនថ្នាក់បឋមសិក្សាមានប្រមាណ ៨២% ក្នុងនោះនៅរាជធានីភ្នំពេញ និងនៅទីប្រជុំជនមានចំនួន៩០% និងតំបន់ដាច់ស្រយាល និងតំបន់ភូមិភាគជនជាតិភាគតិច គឺមានចំនួនប្រមាណពី ៥០% ទៅ៦០%។ ចំពោះបញ្ហាការបោះបង់ការសិក្សា និងការសិក្សាត្រួតថ្នាក់របស់កុមារ នៅកម្រិតបឋមសិក្សាមានប្រមាណ៣០% ឯណោះ។ មានកុមារមួយចំនួនបានប្រើរយៈពេលរហូតដល់ ១០ឆ្នាំ ដើម្បីបញ្ចប់ការសិក្សាកម្រិតបឋមសិក្សា។ ម្យ៉ាងទៀត ការបោះបង់ការសិក្សា និងការរៀនត្រួតថ្នាក់ភាគច្រើន គឺជាកុមារដែលស្ថិតនៅតំបន់ដាច់ស្រយាល និងតំបន់ព្រៃភ្នំ។ ចំណេះដឹងរបស់កុមារខាងផ្នែកគណិតវិទ្យា និងអក្សរសាស្ត្រខ្មែរនៅមានកម្រិតទាប។ សិស្សានុសិស្សនៅថ្នាក់បឋមសិក្សាមិនទាន់បានរៀនសូត្រឲ្យគ្រប់ពីរពេល(ព្រឹក និងល្ងាច) នៅឡើយ។

រហូតមកដល់ឆ្នាំ១៩៩២ នៅប្រទេសកម្ពុជា គិតជាមធ្យមអត្រាប្រឡងជាប់សញ្ញាបត្រ បឋមសិក្សាមានចំនួន៧០% អត្រាប្រឡងជាប់អនុវិទ្យាល័យមានចំនួន៧១% និងអត្រាប្រឡងជាប់ថ្នាក់ទុតិយភូមិមានចំនួន៧៧%។ ដូច្នេះយើងឃើញថា ការប្រឡងជាប់របស់សិស្សនុសិស្សសម័យនោះមានអត្រាខ្ពស់ជាងសម័យមុនសង្គ្រាម។ នៅសម័យនោះ សិស្សភាគច្រើនពុំសូវយកចិត្តទុកដាក់ក្នុងការសិក្សា និងមានភាពអសកម្មច្រើនក្នុងការសិក្សាក៏ដូចជាក្នុងពេលប្រឡង ដែលជះឥទ្ធិពលជាអវិជ្ជមាន ដល់សតិអារម្មណ៍របស់សិស្សដែលយកចិត្តទុកដាក់ក្នុងការសិក្សា និងសិស្សពូកែដែលស្ថិតនៅក្នុងគ្រួសារក្រីក្រ។

ការបណ្តុះបណ្តាលធនធានមនុស្ស នៅតាមគ្រឹះស្ថានសិក្សាថ្នាក់ឧត្តមសិក្សា និងថ្នាក់វិទ្យាល័យបានជួបប្រទះនូវការលំបាកស្មុគស្មាញច្រើន ដែលបណ្តាលមកពីខ្វះខាតចំនួនសាស្រាចារ្យ និងគ្រូបង្រៀនដែលមានសមត្ថភាព និងចេះភាសាបរទេសព្រមទាំងខ្វះខាតសៀវភៅសិក្សានិងសម្ភារៈបរិក្ខារសម្រាប់មន្ទីពិសោធន៍។ល។ ជាមួយគ្នានេះដែរ ការបណ្តុះបណ្តាលធនធានមនុស្សនៅតាមបណ្តាអតីតប្រទេសសង្គមនិយម ក៏បានជួបប្រទះនូវការលំបាកគ្រប់បែបយ៉ាងដែលទាក់ទងនឹងរដ្ឋាភិបាល បានខិតខំប្រឹងប្រែងដោះស្រាយយ៉ាងណាក៏ដោយ ក៏សិស្សនិស្សិតមួយចំនួនធំបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ មុនបញ្ចប់ការសិក្សារបស់ខ្លួន។ ចំពោះសិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សានៅបរទេសនាសម័យនោះ គិតជាសរុបមានប្រមាណ៣.៩២១នាក់ ក្នុងនោះក្រោយឧត្តមសិក្សាមានប្រមាណ៤៨នាក់ ថ្នាក់ឧត្តមសិក្សាមាន១.០៤១នាក់ និងមធ្យមសិក្សាបច្ចេកទេសមាន ១.០៦៣នាក់ និងថ្នាក់កម្មករជំនាញមានចំនួន ១.៧៣៣នាក់។

ចំពោះស្ថានភាពអក្ខរកម្មនៅក្នុងប្រទេសកម្ពុជានាសម័យនោះបើពិនិត្យជារួមឃើញថា មាន

ការលំបាកស្មុគស្មាញច្រើនដូចជា៖ អក្ខរជនគឺនៅមានច្រើន ក្នុងនោះភាគច្រើនជានារីភេទ ហើយចំនួននេះចេះកើនឡើងជាលំដាប់ជារៀងរាល់ឆ្នាំ តាមរយៈអ្នកភ្លេចអក្សរ តាមរយៈកុមារដល់វ័យសិក្សាហើយមិនបានចូលរៀន ឬបោះបង់ចោលការសិក្សា ដែលបណ្តាលមកពីការខ្វះខាតផ្នែកជីវភាព។ រីឯចំនួនសិស្សថ្នាក់បឋមសិក្សានាឆ្នាំសិក្សា ១៩៩២–១៩៩៣ គឺមានចំនួន ១.៥៦៨.៩៥៨ នាក់ ចំនួនសិស្សថ្នាក់អនុវិទ្យាល័យ មានចំនួនប្រមាណ ១៣១.១៣៦នាក់ និងចំនួនសិស្សថ្នាក់វិទ្យាល័យ មានចំនួន១០៨.២២៧នាក់។ ទាក់ទងទៅនឹងចំនួនសាលារៀន បើធៀបទៅនឹងឆ្នាំសិក្សា ១៩៩១–១៩៩២ យើងឃើញថា ចំនួនអនុវិទ្យាល័យបានថយចុះប៉ុន្តែចំនួនសិស្សបានកើនឡើងដោយសារ អនុវិទ្យាល័យមួយចំនួនបានប្រែក្លាយទៅជាវិទ្យាល័យ។[12]

### ១.២.១.១០ ការអប់រំនៅឆ្នាំ ១៩៩៣ ដល់ បច្ចុប្បន្ន

ប្រព័ន្ធអប់រំរបស់កម្ពុជា ត្រូវបានស្ថាបនាឡើងវិញទាំងស្រុងក្នុងឆ្នាំ១៩៧៩ ជាមួយនឹងការបង្កើតឡើងនូវក្រសួងសិក្សាធិការជាតិ។ សាលាបឋមសិក្សាដំបូងគេ ត្រូវបានបើកឡើងវិញក្នុងរាជធានីភ្នំពេញនៅខែកញ្ញា ឆ្នាំ១៩៧៩ បន្ទាប់មកគឺការបើកឡើងវិញនូវវិទ្យាល័យស៊ីសុវត្ថិ។ នៅឧត្តមសិក្សា មហាវិទ្យាល័យឱសថសាស្ត្រ គឺជាមហាវិទ្យាល័យដំបូងគេ ត្រូវបានបើកឡើងវិញដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រាប់ការស្តារឡើងវិញរបស់ប្រទេសកម្ពុជា។

គោលនយោបាយអប់រំរបស់រាជរដ្ឋាភិបាល មានគោលបំណងជំរុញការចូលរៀនកាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា (សិស្សដែលចាកចេញពីសាលារៀន ដោយសារគ្មានលទ្ធភាពបង់ថ្លៃសិក្សា) តាមរយៈការបង្កើនប្រាក់ខែគ្រូបង្រៀន ការផ្តល់សម្ភារៈនិងបរិក្ខារសាលារៀន ការកសាងសាលារៀន ការលុបបំបាត់ចំណាយទាំងផ្លូវការ និងមិនផ្លូវការពីឪពុកម្តាយសិស្ស ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងការកសាងអន្តេវាសិដ្ឋានសម្រាប់កុមារី។ ក្រសួងអប់រំ យុវជន និងកីឡា មានក្តីបារម្ភអំពីការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន និងអធិការអប់រំឲ្យបានគ្រប់គ្រាន់ និងកសាងកម្មវិធីសិក្សាសិក្សា និងផ្តល់សម្ភារៈសិក្សាឲ្យបានពេញលេញដែលនឹងលើកកម្ពស់គុណភាពនៃការអប់រំ។ ទោះជាយ៉ាងណា ប្រាក់ខែគ្រូបង្រៀនដែលមានកម្រិតទាបដែលស្ថិតក្នុងថវិកាត្បិតត្បៀតខ្លាំងនោះ ធ្វើឲ្យគុណភាពនៃការបង្រៀន និងការបន្តនិរន្តភាពនៃសេវាអប់រំចុះខ្សោយ។ ចំណាយក្រៅផ្លូវការរបស់គ្រួសារចំពោះគ្រូបង្រៀនគឺជាបន្ទុកមួយទៀតសម្រាប់អ្នកក្រីក្រ។ បញ្ហាសំខាន់នេះកំពុងត្រូវបានលើកយកមកដោះស្រាយ។

[12] ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជាដើម សតវត្សទី១ រហូតដល់ចុងសតវត្សទី២០ របស់បណ្ឌិត ឈុន ពហុ និងអនុបណ្ឌិត នួន ហេង បោះពុម្ពលើកទី១ ២០១៥

❖ **ការអប់រំកម្រិតមូលដ្ឋាន**

ការអប់រំកម្រិតមូលដ្ឋាន សម្រាប់ទាំងអស់គ្នា រួមបញ្ចូលទាំងអក្ខរកម្មសម្រាប់យុវជន និងជនពេញវ័យ គឺជាកម្មវិធីសំខាន់បំផុតក្នុងវិស័យអប់រំ។ ការអប់រំកម្រិតមូលដ្ឋាន រួមបញ្ចូលទាំងមត្តេយ្យសិក្សា បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ។ ការអប់រំកម្រិតមូលដ្ឋាន មានពីរផ្នែក គឺការអប់រំបឋមសិក្សា ៦ឆ្នាំ និងមធ្យមសិក្សាបឋមភូមិ ៣ឆ្នាំ។ កម្មវិធីអប់រំកម្រិតនេះ នឹងត្រូវបញ្ចប់នៅពេលសិស្សបានចូលរៀនរយៈពេល៩ឆ្នាំ។ កំណែទម្រង់អប់រំ កំពុងដោះស្រាយបញ្ហាសមធម៌ និងប្រសិទ្ធភាព តាមរយៈការបង្កើនម៉ោងសិក្សាក្នុង១ថ្ងៃ ការង្កើនការផ្គត់ផ្គត់សម្ភារៈបង្រៀន និងការបង្កើនប្រាក់ខែគ្រូបង្រៀន។ ការលុបបំបាត់វិភាគទានពីឪពុកម្តាយ ការបង្កើនថវិការដំណើរការសាលារៀន និងការបង្រៀនថ្នាក់បំប៉នបន្ថែមសុទ្ធតែជាសកម្មភាពមានសារៈប្រយោជន៍។

❖ **ការអប់រំកម្រិតមធ្យមសិក្សា**

នៅកម្រិតមធ្យមសិក្សារួមមាន ការអប់រំមធ្យមសិក្សាចំណេះដឹងទូទៅ និងការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ។ អាទិភាពរបស់រដ្ឋាភិបាលចំពោះការអប់រំសិក្សាចំណេះទូទៅមានដូចជាៈ

ក. ការលើកកម្ពស់ការពង្រីកសម្ភារៈបរិក្ខារ តាមរយៈការផ្តល់ហិរញ្ញវត្ថុក្នុងការកសាងអគារសិក្សាថ្មីនៅតាមស្រុកទាំងអស់ ការពង្រីក ឬការស្តារឡើងវិញសម្ភារៈបរិក្ខាររឧបទេសដែលមានស្រាប់ និងការអនុវត្តអភិក្រមនានាដូចជា ការបង្រៀនពីរវេន ដើម្បីបង្កើនចំនួនសិស្សចំនួនរៀន។

ខ. ការផ្តល់ធនធានសាធារណៈឲ្យបានគ្រប់គ្រាន់ចំពោះ សម្ភារៈបរិក្ខាររនៅតាមសាលារៀន

គ. ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំ តាមរយៈការពង្រឹងការបណ្តុះបណ្តាល និងវិក្រិតការគ្រូបង្រៀន និងការផ្តល់សម្ភារៈបង្រៀនគ្រប់គ្រាន់ (សៀវភៅសិក្សាគោល និងឧបករណ៍។ល។)

អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី១៥% នៅឆ្នាំ១៩៩៧ ដល់១៩% នៅឆ្នាំ២០០១ និងកើនដល់៣១% នៅឆ្នាំ២០០៥។ គោលបំណងរបស់រដ្ឋាភិបាលគឺ បង្កើនអត្រាពិតនៃការសិក្សានៅមធ្យមសិក្សា បឋមភូមិ យ៉ាងហោចឲ្យដល់ ៦៥% នៅឆ្នាំ ២០១៥។

ឧបសគ្គចម្បង ចំពោះការចូលរៀនរបស់សិស្សស្រីរួមមានៈ កង្វះអនុវិទ្យាល័យ និងវិទ្យាល័យក្នុងស្រុក ឃុំ និងសង្កាត់ក្រីក្រ និងកម្រិតនៃភាពក្រីក្រដែលរារាំងក្មេងស្រីពីការចូលរៀនពីព្រោះពួកគេត្រូវជួយទទួលខុសត្រូវក្នុងគ្រួសារនៅឯផ្ទះ។ ដូច្នេះ រដ្ឋាភិបាលកំពុងផ្តល់អាទិភាព

ចំពោះការសាងអាគារសិក្សាថ្មីៗក្នុងស្រុកទាំងអស់ និងផ្តល់អាហារូបករណ៍បន្ថែមទៀត ឲ្យចំគោលដៅសិស្សក្រីក្រ ជាពិសេសកុមារី។

❖ ការអប់រំបច្ចេកទេស និងការបណ្តុះបណ្តាលវិជ្ជាជីវៈ

នៅកម្ពុជា ការអប់រំបច្ចេកទេសនិងការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈត្រូវបានចាត់ទុកថាអនុវិស័យមួយនៃការអប់រំ។ ការអប់រំនេះរួមបញ្ចូលទាំង "ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈជាន់ខ្ពស់ និងការអប់រំបច្ចេកទេស និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ថ្នាក់មធ្យមសិក្សានិងកណ្តាល"។ ក្នុងអាណត្តិទីបីនៃរាជរដ្ឋាភិបាលកម្ពុជា (២០០៣ ដល់ ២០០៨) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានបង្កើតឡើង ដែលទទួលបន្ទុកលើការបង្កើតការងារ និងបណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈ។ ផែនការអភិវឌ្ឍការបណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈថ្នាក់ជាតិសម្រាប់ឆ្នាំ ២០០៨ ត្រូវបានពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពនៅដើមឆ្នាំ ២០០៨ និងត្រូវបានតម្រឹមយ៉ាងល្អជាមួយផែនការយុទ្ធសាស្ត្ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (២០០៩–២០១០)។

❖ ការអប់រំឧត្តមសិក្សា

កម្ពុជាបានប្រឈមមុខ ជាមួយនឹងបញ្ហាប្រឈមខាងការអភិវឌ្ឍថ្មីៗមួយចំនួនដូចជា សកលភាវូបនីយកម្មសេដ្ឋកិច្ច និងការកើនឡើងនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាពិសេសវិទ្យាសាស្ត្រកុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មាននៅក្នុងជីវិតរស់នៅ។ ដើម្បីរក្សាប្រព័ន្ធអប់រំរបស់កម្ពុជាដែលមានភាពប្រកួតប្រជែង រួមបញ្ចូលទាំងការអប់រំបច្ចេកទេស និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការយកចិត្តទុកដាក់ទៅលើការផ្តល់ចំណេះដឹង ទៅដល់ប្រជាជននៅគ្រប់ផ្នែកសម្រាប់ការរស់រាន នៅក្នុងពិភពសម័យទំនើបក៏ដូចជា ការលើកកម្ពស់គុណភាពអប់រំ។ ស្ថាប័នឧត្តមសិក្សាក៏ត្រូវតែស្វែងរកតុល្យភាពត្រឹមត្រូវរវាងគោលបំណង៣គឺ៖ ការស្រាយការសិក្សានៅឧត្តមសិក្សា លទ្ធភាពហិរញ្ញវត្ថុ និងការថែរក្សាគុណភាពតម្លៃខាងប្រពៃណី។

ដើម្បីបំពេញតាមតម្រូវការ របស់អ្នកបញ្ចប់ការសិក្សានៅឧត្តមសិក្សា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយលើកទឹកចិត្តដល់គ្រឹះស្ថានអប់រំឧត្តមសិក្សាឯកជន។ ជាលទ្ធផល ចំនួនសាកលវិទ្យាល័យ និងវិទ្យាស្ថានថ្នាក់ឧត្តមសិក្សាបានកើនឡើងយ៉ាងឆាប់រហ័ស។ ទោះយ៉ាងណា គុណភាពសិក្សារបស់និស្សិតឧត្តមសិក្សានៅកម្រិតទាប ហើយមិនត្រូវបានទទួលការពេញចិត្តច្រើនពីទីផ្សារការងារទេ។ ឆ្លើយតបទៅនឹងបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា (ACC) ដែលទទួលខុសត្រូវវាយតម្លៃពីខាងក្រៅ លើ

គុណភាពរបស់គ្រឹះស្ថានឧត្តមសិក្សា។ កិច្ចការជាច្រើនដែលត្រូវបន្តការអនុវត្ត ដើម្បីបង្កើនមធ្យមភាគរបស់សាកលវិទ្យាល័យ វិទ្យាស្ថាន ថ្នាក់ឧត្តមសិក្សាឲ្យឡើងដល់កម្រិតតំបន់។[13]

### ១.២.២ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ

"រាជរដ្ឋាភិបាលកម្ពុជាមានមហិច្ឆតា ក្នុងការផ្លាស់ប្តូរពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ ហើយបន្តក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។" [14] កំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែងនាពេលបច្ចុប្បន្ន និងពេលអនាគត។ ដើម្បីសម្រេចបានមហិច្ឆតានេះ គឺពឹងផ្អែកទៅលើសមត្ថភាពរបស់ប្រជាជនក្នុងការក្រេបយកចំណេះដឹងសមស្រប និងជំនាញពាក់ព័ន្ធដែលអាចឆ្លុះបញ្ចាំងពីមរតកវប្បធម៌ និងសីលធម៌របស់ប្រទេសជាតិ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំត្រូវបានរៀបចំឡើងតាមអនុវិស័យសំខាន់ៗចំនួន៧ ដែលរួមមាន៖

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា
- ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស
- ការអប់រំឧត្តមសិក្សា
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយកីឡា

#### ១.២.២.១ គោលនយោបាយអប់រំ

**គោលនយោបាយទី១៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌**

កុមារគ្រប់រូប បានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត។ សម្រាប់កុមារដែលពុំមានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធ ជម្រើសផ្សេងទៀតនឹងត្រូវបានផ្តល់លទ្ធភាពអោយអ្នកទាំងនោះទទួលបានការអប់រំ។ ការបង្កើនចំនួនកុមារ និងយុវជនអោយទទួលបានការអប់រំនៅគ្រប់កម្រិត ដោយផ្តោតលើសមធម៌ និងតំបន់ និងក្រុមកុមារជួបការលំបាក។ ការបង្កើនឱកាសដល់សិស្សដែលបញ្ចប់ការសិក្សានៅ

[13] សេដ្ឋកិច្ចកម្ពុជា មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត របស់បណ្ឌិត ហង់ ជួនណារ៉ុង ២០១៥ ទំពរ័ ៣៧៧ ដល់ ៣៨៨

[14] ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤ - ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា ទំព័រ១៣

ថ្នាក់ទី១២ អោយទទួលបាននូវចំណេះដឹង និងជំនាញក្នុងការគិត និងហេតុផល និងអាចជាមូលដ្ឋានសម្រាប់បន្តការសិក្សានៅក្នុងបណ្តុះបណ្តាលបច្ចេកទេស និងឧត្តមសិក្សាតទៅទៀត។

**គោលនយោបាយទី២៖ លើកកម្ពស់គុណភាព និងភាពឆ្លើយតប**

កុមារ និងយុវជនគ្រប់រូប មានបទពិសោធន៍ក្នុងការសិក្សា ប្រកបដោយគុណភាពនិងភាពឆ្លើយតបដែលអាចអោយពួកគេអាចចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។ ការធានាថាការអប់រំប្រកបដោយគុណភាព និងមានទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សា មាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រង ជាមួយនឹងស្តង់ដារនៃផលសម្រេច ការពិនិត្យតាមដាននិងរបាយការណ៍។

**គោលនយោបាយទី៣៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

ការផ្តល់សេវាអប់រំ នឹងត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព និងទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈ និងផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ពេលវេលាការពិនិត្យតាមដាន និងរបាយការណ៍នូវលទ្ធផល យោបល់ត្រឡប់ វិធានការប្រកបដោយគណនេយ្យភាព និងយន្តការសសម្រាប់កែលម្អគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការជាក់ស្តែងនៅកម្រិតសាលារៀន។

**១.២.២.២ សូចនាករស្នូល**

| សូចនាករស្នូល | ស្ថានភាពបច្ចុប្បន្ន ២០១២-២០១៣ | ចំណុចដៅ ២០១៧-២០១៨ |
|---|---|---|
| គោលនយោបាយទី១៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | | |
| ១. ភាគរយកុមារអាយុ៥ឆ្នាំ ក្នុងការអប់រំកុមារតូចគ្រប់រូបភាព | ៥៦.៥% | ៨០% |
| ២.ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច៨០ភាគរយ | ១៩៩ | ១៩៤ |
| ៣.ចំនួនខេត្តដែលបានបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ភាគរយ | ៧ | ១៧ |
| គោលនយោបាយទី២៖ លើកកម្ពស់គុណភាព និងភាពឆ្លើយតប | | |
| ៤. អត្រាអក្ខរកម្មយុវជន (អាយុ ១៥ ២៤) | ៩១.៥% | ៩៧.៥% |

| | | |
|---|---|---|
| ៥. អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥ ៤៥) | ៨៧.០៥% | ៩០.៥% |
| ៦.ការវាយតម្លៃថ្នាក់ជាតិលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣ ទី៦ និងទី៨ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | កំពុងអនុវត្តថ្នាក់ទី៣ | អនុវត្តថ្នាក់ទី៨ |
| ៧.ចំនួនគ្រូបង្រៀនឧត្តមសិក្សា មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ | ៦៣១១នាក់ | ៧៣១១ នាក់ |
| ៨. ចំនួនគ្រូបង្រៀនឧត្តមសិក្សាមានសញ្ញាបត្របណ្ឌិត | ៨០៨នាក់ | ១០៥៨នាក់ |
| គោលនយោបាយទី៣៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | |
| ៩. ភាគរយថវិកាកម្មវិធីធៀបនឹងថវិកាសរុបក្រសួងអប់រំ យុវជន និងកីឡា | ១៣.៦៩% (នៅឆ្នាំ២០១៣) | ១០០% |
| ១០. ភាគរយការទូទាត់ចំណាយថវិកាកម្មវិធី | ៨៦.៧% | ១០០% |

### ១.២.២.៣ គោលការណ៍របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤ - ២០១៨

ក្របខណ្ឌយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ នឹងផ្តោតលើការបន្តសកម្មភាព ការពង្រីក និងការបន្តនិរន្តរភាពនៃសមិទ្ធផលដែលបានសម្រេចកន្លងមក ទាក់ទងនឹងការចូលរៀន ការលើកកម្ពស់សមធម៌ ការបង្កើនគុណភាព និងភាពឆ្លើយតបសម្រាប់កុមារ និងយុវជន តាមរយៈការផ្តល់សេវាអប់រំប្រកបដោយវិជ្ជាជីវៈ តម្លាភាព និងគណនេយ្យភាព។

ដើម្បីសម្រេចបានវត្ថុបំណងគោលនយោយបាយ និងកម្មវីធីនានា ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- ផ្សារភ្ជាប់ទៅនឹងកម្មវិធីជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងចូលរួមក្នុងដំណើរការបង្កើតរដ្ឋបាលឯកភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមការណែនាំពីគណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍនតាមបែបប្រជាធិបតេយ្យ។
- រៀបចំយន្តការប្រតិបត្តិទាំងក្នុងទាំងក្រៅ និងប្រព័ន្ធការងារទាំងខ្សែទទឹង និងបណ្តោយ ប្រព័ន្ធព័ត៌មាន និងមុខងារប្រតិបត្តិ ដែលឆ្លុះបញ្ចាំងពីការគ្រប់គ្រងតាមបែបអនុវិស័យ និងស្របតាមវត្ថុបំណងគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង។
- ឆ្លើយតបនឹងក្របខណ្ឌនៃការកសាងផែនការ ការគ្រោងថវិកា ការពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល។

- ផ្អែកលើគោលការសិទ្ធិ និងសមធម៌
- ផ្តល់ជាក្របខណ្ឌគុណភាពទូលំទូលាយមួយ ដែលរួមបញ្ចូលទាំងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (ផ្សារភ្ជាប់នឹងការវាយតម្លៃនៅថ្នាក់តំបន់និងអន្តរជាតិ) កម្មវិធីសិក្សា និងសម្ភារៈសិក្សា ជំនាញនិងចំណេះដឹងក្នុងការបង្រៀន សម្ភារៈ ការគ្រប់គ្រង និងស្តង់ដាររបស់សេវាអប់រំ។
- លើកកម្ពស់និរន្តភាពផ្នែកហិរញ្ញវត្ថុ តាមរយៈការធ្វើចំណោលផ្អែកតាមតម្រូវការ
- កៀរគរការចូលរួមពីអ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ។

**១.២.២.៤ កម្មវិធីអាទិភាព**

- កម្មវិធីពង្រីកការគាំពារ និងអប់រំកុមារតូច
- កម្មវិធីអភិវឌ្ឍ និងសាងសង់សាលារៀន
- កម្មវិធីអភិវឌ្ឍប្រព័ន្ធធានាគុណភាពអប់រំ និងគុណភាពសាលារៀន
- កម្មវិធីពង្រឹងប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ និងអន្តរជាតិ
- កម្មវិធីអាហារូបករណ៍
- កម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ
- កម្មវិធីគ្រប់គ្រង និងវាយតម្លៃការបំពេញការងាររបស់បុគ្គលិក
- កម្មវិធីអភិវឌ្ឍឧត្តមសិក្សា
- កម្មវិធីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល
- កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំ និងហិរញ្ញប្បទាន
- កម្មវិធីអក្ខរកម្ម និងរៀនពេញមួយជីវិត
- កម្មវិធីសម្រប់សម្រួលក្នុងវិស័យ និងអន្តរវិស័យ
- បញ្ហាឆ្លងវិស័យ (បញ្ហាយេនឌ័រ ការកាត់បន្ថយគ្រោះមហន្តរាយ ការថែរក្សាបរិស្ថាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ)

# ជំពូកទី២

# សកម្មភាពរបស់អង្គការដើម្បីភាពញញឹមនៃកុមារក្នុងការអប់រំ

# ជំពូកទី២

# សកម្មភាពរបស់អង្គការដើម្បីភាពញញឹមនៃកុមារក្នុងការអប់រំ

## ២.១ ស្ថានភាពទូទៅរបស់អង្គការ

### ២.១.១ ទីតាំង និងសាខារបស់អង្គការ

អង្គការដើម្បីភាពញញឹមនៃកុមារមានសាខានៅ ៨ប្រទេស ដែលគោលបំណងសំខាន់ ២នៃការបង្កើតសាខានេះគឺដើម្បី៖

- បង្កើនការយល់ដឹងពី PSE ដល់ប្រជាពលរដ្ឋនៅតាមតំបន់តាមរយៈខ្សែភាពយន្តខ្លីៗដែលបានចាក់បញ្ចាំងនៅសាលារៀន
- រៃអង្គាសថវិកា រៀបចំកម្មវិធីផ្សេងៗ ការប្រគុំតន្ត្រី ការលក់វត្ថុអនុស្សាវរីយ៍ធ្វើដោយដៃរបស់កុមារ និងស្ត្រីមេម៉ាយផ្សេងៗ ក្នុងគោលបំណងឧបត្ថម្ភដល់អង្គការធំនៅកម្ពុជា។

សាខាទាំងនោះ រួមមាននៅប្រទេសដូចខាងក្រោម៖

- ប្រទេស អាឡឺម៉ង់
- ប្រទេស ប៊ែលហ្សិក
- ប្រទេស អេស្ប៉ាញ
- ចក្រភពអង់គ្លេស
- ទីក្រុង ហុងកុង
- ប្រទេស លុចហ្សំបួ
- ប្រទេស ស្វីស
- ប្រទេស អាមេរិក
- ប្រទេសកម្ពុជា

សម្រាប់ទីតាំងនៅប្រទេសកម្ពុជា គឺជាកន្លែងសម្រាប់ទទួល និងអប់រំកុមាររួមទាំងយុវជនក្រីក្រ ដើម្បីឲ្យមានឱកាសទទួលបានចំណេះដឹង និងជំនាញសម្រាប់ប្រកបរបរទៅថ្ងៃអនាគត។

នៅប្រទេសកម្ពុជាមាន៣សាខារួមមាន៖

- **ភ្នំពេញ៖** រួមមានទាំងសាលាចំណេះដឹងទូទៅ សាលាចំនេះជំនាញ កន្លែងស្នាក់នៅ ភោជនីយដ្ឋាន និងសណ្ឋាគារសម្រាប់សិស្សានុសិស្សហ្វឹកហាត់ កន្លែងលក់វត្ថុអនុស្សាវរីយ៍ ហើយក៏ជាទីស្នាក់ការកណ្តាលផងដែរ។

អាសយដ្ឋាន៖ ផ្ទះលេខ៤០២ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

- **សៀមរាប៖** ជាកន្លែងសម្រាប់សិស្សានុសិស្សស្នាក់នៅ ពេលដែលពួកគាត់ចុះទៅហ្វឹកហាត់ការងារនៅតាមតំបន់នោះ។

  អាសយដ្ឋាន៖ តាមដងផ្លូវជាតិលេខ៦ ភូមិកសិកម្ម ឃុំផ្សារញ៉ែរ ខេត្តសៀមរាប

- **ខេត្តព្រះសីហនុ៖** ក៏ជាកន្លែងសម្រាប់សិស្សានុសិស្សស្នាក់នៅ ពេលដែលពួកគាត់ចុះទៅហ្វឹកហាត់ការងារផងដែរ។

  អាសយដ្ឋាន៖ ក្រុមទី១៧ មណ្ឌលទី២ សង្កាត់៣ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ។

### ២.១.២ បេសកកម្ម

"បេសកកម្មរបស់អង្គការដើម្បីភាពញញឹមនៃកុមារ គឺដើម្បីជួយកុមារឲ្យគេចផុតពីភាពទុរគត និងដឹកនាំពួកគេឲ្យទទួលបានការរស់នៅឯករាជ្យ មានជំនាញ និងការងារដែលទទួលបានកម្រៃសមរម្យ។"[15]

ដើម្បីសម្រេចឲ្យបានបេសកកម្មនេះ អង្គការបានផ្តោតទៅលើគម្រោង ៦ ដែលសំខាន់សម្រាប់ក្មេងៗគឺ៖

- អាហារ៖ កុមារមកពីគ្រួសារក្រីក្រទាំងអស់របស់អង្គការមានសិទ្ធទទួលបានអាហារយ៉ាងតិចមួយពេលគឺនៅពេលព្រឹកសម្រាប់កុមារ ដែលសិក្សានៅសាលារដ្ឋ និងអាហារ៣ពេលសម្រាប់កុមារ និងយុវជនដែលកំពុងសិក្សាជំនាញនៅអង្គការ។ អង្គការត្រូវរៀបចំអាហារ៨៥០០ចានជារៀងរាល់ថ្ងៃ សម្រាប់ពួកគាត់ដើម្បីធានាថាពួកគាត់ទទួលបានអាហាររូបត្ថម្ភគ្រប់គ្រាន់ក្នុងការរស់នៅ។
- សុខភាព៖ មានគ្រូពេទ្យជំនាញជាង៣០នាក់ រួមទាំងទន្តពេទ្យ និងគ្រូពេទ្យចិត្តវិទ្យា ទាំងក្នុងគិលានដ្ឋានសាលា និងគិលានដ្ឋានចល័តដោយការព្យាបាល និងពិភាក្សាដោយមិនគិតប្រាក់។
- ការការពារ៖ កុមារមួយចំនួនគឺស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដោយសារការប្រើប្រាស់អំពើហិង្សាពីឪពុកម្តាយ ដូច្នេះអង្គការបានទទួលយកពួកគាត់មករស់នៅក្នុងមណ្ឌល ឬតាមរយៈឪពុកម្តាយចិញ្ចឹម។
- ការអប់រំចំណេះដឹងទូទៅ៖ ការអប់រំចំណេះដឹងទូទៅត្រូវបានបែងចែកជា២ គឺការអប់រំនៅ

[15] http://www.pse.ong/en/our-mission 11/Jun/2017, 14:30

សាលារដ្ឋ និងការអប់រំនៅថ្នាក់ពន្លឿនរបស់អង្គការ។ កុមារក្រីក្រ ពិសេសកុមារដែលលើសអាយុចូលរៀនទាំងអស់ មានឱកាសបញ្ចប់យ៉ាងហោចណាស់ថ្នាក់បឋមសិក្សាដោយមិនមានការរើសអើងពីក្មេងៗដទៃ។

- ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ៖ សម្រាប់កុមារដែលបញ្ចប់ថ្នាក់បឋមសិក្សា ឬទើបចាប់ផ្តើមថ្នាក់អនុវិទ្យាល័យ អាចទទួលបានការបណ្តុះបណ្តាលជំនាញ តាមចំនង់ចំណូលចិត្តរបស់ខ្លួន ដោយមានការទទួលស្គាល់ដោយក្រសួងអប់រំយុវជន និងកីឡា ក៏ដូចជាក្រសួងការងារផងដែរ។ ប៉ុន្តែការបណ្តុះបណ្តាលនេះ ក៏តម្រូវឲ្យយុវជនទាំងនោះចូលរៀនថ្នាក់ស្ពានចម្លង ឬ ថ្នាក់ត្រៀម មុននឹងអាចជ្រើសរើសជំនាញ។
- ការជួយដល់គ្រួសាររបស់ពួកគេ៖ ដើម្បីឲ្យក្រុមគ្រួសាររបស់ពួកគេអនុញ្ញាត ឲ្យកូនៗបានទទួលការអប់រំ យើងបានសម្រួលដោយការចែកអង្ករ ក្នុងន័យចូលរួមចំណែកកាត់បន្ថយចំណាយ ឬបំពេញចំណែកដែលកូនៗរបស់ពួកគាត់មិនបានទៅជួយរកលុយអោយពួកគាត់។ ក្រៅពីនេះ អង្គការក៏មានវគ្គបណ្តុះបណ្តាលជំនាញខ្លីៗដល់ពួកគាត់សម្រាប់សម្រួលដល់ជីវភាពរបស់ខ្លួនផងដែរ។

## ២.១.៣ ប្រវត្តិ

អង្គការដើម្បីភាពញញឹមនៃកុមារត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៦ ដែលមានស្ថាបនិកពីររូបគឺលោក Christian និងអ្នកស្រី Marie-France des Pallieres និងក្រុមការងារដែលជាជនជាតិខ្មែរដែលមានសមត្ថភាពជាច្រើនរូបទៀត។ លោកទាំងពីរ ចាប់ផ្តើមបង្កើតអង្គការនេះឡើងដោយសង្កេតឃើញមានក្មេងៗជាច្រើននៅលើគំនរសំរាម កំពុងតែរស់នៅ និងស្វែងរកអាហារនៅទីនោះនៅកំឡុងពេលដែលលោកទាំងពីរកំពុងបំពេញបេសកកម្មមនុស្សធម៌នៅប្រទេសកម្ពុជានា ខែតុលាឆ្នាំ១៩៩៥។ ក្រោយពីសង្គ្រាមរយៈពេលជាច្រើនឆ្នាំ ប្រទេសកម្ពុជាបានបាត់បង់អ្វីៗទាំងអស់ រួមទាំងប្រព័ន្ធទំនាក់ទំនងផ្សេងៗ និងការរស់នៅជាមូលដ្ឋាន។ ចំណែកអនាគតក្មេងៗ ក៏មានកម្រិតកំណត់ និងមានសភាពគ្រោះថ្នាក់ដោយសារតែពួកគាត់រស់នៅក្នុងតំបន់មិនល្អ និងគ្មានការរស់នៅសមរម្យ។

ចាប់ផ្តើមពីការជួលអគារសម្រាប់ប្រតិបត្តិការសកម្មភាពមនុស្សធម៌នេះ ជាមួយចំនួនសិស្សជាង២០នាក់ មកដល់ពេលនេះមានចំនួន៦៥០០នាក់ ដែលក្នុងនោះស្រីមានចំនួន ៥៧ភាគរយ។ មកដល់ពេលនេះ អង្គការមានទីតាំងផ្ទាល់ខ្លួន និងបានផ្តល់លំនៅឋាន អាហារ ការអប់រំចំណេះដឹងទូទៅ និងវិជ្ជាជីវៈ ដែលស្របតាមស្តង់ដារ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងទីផ្សារការងារបច្ចុប្បន្ន និងថ្ងៃអនាគតទៅដល់ក្មេងៗទាំងនោះ។






## ២.១.៤ រចនាសម្ព័ន្ធរបស់អង្គការ

រចនាសម្ព័ន្ធសាលាដើម្បីស្នាមញញឹមនៃកុមារ



រចនាសម្ព័ន្ធផ្នែករដ្ឋាបាល




## ២.១.៥ ការឧបត្ថម្ភ និងដៃគូសហការ

ចាប់តាំងពីគ្រាដំបូងនៃការចាប់ផ្ដើម រហូតមកដល់បច្ចុប្បន្ន អង្គការបានស្វះស្វែងរកដៃគូសហការសម្រាប់ឲ្យសិស្ស និស្សិត អាចមានឱកាសចុះទៅហ្វឹកហាត់ការងារផ្ទាល់ និងអនុវត្តន៍ទ្រឹស្ដីដែលបានសិក្សាកន្លងមក។ "*ការស្វែងរកដៃគូសហការក្នុងការអនុញ្ញាតឲ្យសិស្សធ្វើការហ្វឹកហាត់ការងារគឺមានការលំបាកខ្លាំង ប៉ុន្តែអ្វីដែលពិសេស និងអាចជំរុញឲ្យបណ្ដាក្រុមហ៊ុនទាំងឡាយព្រមទទួលយកសិស្សានុសិស្សរបស់ពួកយើងនោះគឺ ការអញ្ជើញពួកគាត់ឲ្យចុះមកផ្ទាល់ដល់ទីតាំងរបស់អង្គការ ដើម្បីឲ្យគាត់បានឃើញពីកម្លាំង សមត្ថភាព និងឆន្ទៈរបស់ក្មេងៗ*

*ទាំងនោះ។ នៅពេលដែលគាត់អញ្ជើញមកដល់ហើយ គឺគ្មានអ្វីពិបាកក្នុងការជំរុញទៀតឡាយ។"* លោកគ្រូសំណាង មានប្រសាសន៍។

ការឧបត្ថម្ភ ត្រូវបានប្រព្រឹត្តឡើងតាមរយៈ ការធ្វើសកម្មភាពរៃអង្គាសនៅតាមបណ្ដាប្រទេសដែលមានសាខារបស់អង្គការតាមរយៈកម្មវិធីរៃអង្គាស ការលក់វត្ថុអនុស្សាវរីយ៍ធ្វើពីដៃ និងការចាក់បញ្ចាំងរឿងខ្លីៗរបស់អង្គការ ក្នុងគោលបំណងបណ្ដុះគំនិតរបស់សប្បុរសជនឲ្យយល់ពីសកម្មភាពរបស់អង្គការនៅកម្ពុជា និងសង្គមកម្ពុជាផងដែរ។ ការឧបត្ថម្ភត្រូវបានធ្វើឡើងតាមវិធីខុសៗគ្នា ដោយអ្នកខ្លះអាចចូលរួមជំនួយជាប្រចាំខែ ដែលអង្គការបានកំណត់ជាគោលត្រឹម ៥២ដុល្លារ/ខែ។ ប៉ុន្តែសប្បុរសជនក៏អាចឧបត្ថម្ភតិច ឬ ច្រើនជាងនេះផងដែរ។ លើសពីនេះទៅទៀត សប្បុរសជនទាំងអស់អាចផ្ដល់ជំនួយផ្សេងៗតាមសន្ដានចិត្ត ដែលមានដូចជា ផ្ដល់ជាស្បៀងអាហារ សំលៀកបំពាក់ សម្ភារសិក្សា។ល។

ដៃគូសហការ និងឧបត្ថម្ភធំៗមានដូចជា៖

- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត Manulife
- ក្រុមហ៊ុនថ្នាំពណ៌ជាតិ Campaint
- ក្រុមហ៊ុនភេសជ្ជៈលំដាប់ថ្នាក់ពិភពលោក Coca Cola
- ក្រុមហ៊ុនវិស្វកម្ម CominKhmere
- ក្រុមហ៊ុនទូរស័ព្ទចល័តលំដាប់ថ្នាក់លេខមួយនៅកម្ពុជា Cellcard
- ក្រុមហ៊ុនរថយន្តជប៉ុន Toyata ជាដើម

## ២.២ សកម្មភាពក្នុងការអប់រំ និងបណ្ដុះបណ្ដាលរបស់អង្គការ

តាមរបាយការណ៍សកម្មភាពប្រចាំឆ្នាំ២០១៥ - ២០១៦ របស់អង្គការដើម្បីភាពញញឹមនៃកុមារបានបង្ហាញថា មានសិស្សច្រើនជាង ៣៧០០នាក់ ដែលបានទទួលបានការសិក្សានៅសាលារដ្ឋក្រោមជំនួយរបស់អង្គការ និងសិស្សចំនួន ៦៥៩នាក់ ដែលទទួលបានការសិក្សានៅសាលារបស់អង្គការផ្ទាល់ ដោយការចូលរៀនក្នុងសាលាពន្លឿន។[16]

សាលារៀនរដ្ឋដែលអង្គការបានបញ្ជូនសិស្សទៅឲ្យសិក្សា គឺមានចំនួន១៦៥សាលា ដែលក្នុងនោះសាលារៀននៅរាជធានីភ្នំពេញមាន ១៣៦សាលារៀន។ សិស្សចំនួន ៧១ភាគរយគឺកំពុងសិក្សានៅថ្នាក់បឋម ២០ភាគរយកំពុងសិក្សានៅថ្នាក់អនុវិទ្យាល័យ និង៩ភាគរយនៅក្នុងទម្រង់ទី៦។[17]

[16] Annaul Activity Report Septermber 2015- August 2016, PSE Pour Un Sourire D'enfant, Page7
[17] Annaul Activity Report Septermber 2015- August 2016, PSE Pour Un Sourire D'enfant, Page8

## ២.២.១ បឋមសិក្សា



កុមារា កុមារី ដែលកំពុងសិក្សានៅថ្នាក់បឋមសិក្សា ដែលទទួលជំនួយពីអង្គការមានប្រមាណ ២.៦២៧នាក់ ស្មើនឹង ៧១ភាគរយ។ កុមារទាំងនោះ ត្រូវបានបញ្ជូនឲ្យទៅសិក្សានៅតាមសាលារដ្ឋដែលនៅជិតផ្ទះ ដើម្បីសម្រួលដល់ការធ្វើដំណើរ។ ទោះបីជាកុមារទាំងនោះ ត្រូវបានបញ្ជូលឲ្យទៅសិក្សានៅតាមសាលារដ្ឋក៏ដោយ អង្គការបានរៀបចំបុគ្គលិកសម្រាប់តាមដានការសិក្សាយ៉ាងជាប់លាប់។ នៅតាមថ្នាក់នីមួយៗតម្រូវឲ្យមានបុគ្គលិករបស់អង្គការមួយនាក់ ក្នុងការតាមដានការសិក្សា ក៏ដូចជាយកវត្តមានរបស់កុមារយ៉ាងទៀងទាត់។

លើសពីនេះបុគ្គលិកទាំងនោះ មានភារៈកិច្ចដោះស្រាយ និងសម្របសម្រួលនូវរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងការបង្អាក់ការសិក្សារបស់ក្មេងៗ ដែលមានដូចជា ផលលំបាកនៃការធ្វើដំណើរ ភាពខ្វះខាតសម្ភារសិក្សា ការសិក្សាមិនទាន់កុមារដទៃ ការគាបសង្កត់ពីគ្រូនៅសាលារដ្ឋ (ការយកលុយពីកុមារ) និងបញ្ហាផ្សេងៗទៀត។ ដើម្បីស្វែងរកបញ្ហាទាំងអស់នេះ បុគ្គលិកនៅតាមតំបន់គោលដៅនីមួយៗ តែងមានការប្រជុំជាមួយអាណាព្យាបាលរបស់កុមារ និងកុមារផ្ទាល់ផងដែរ។ ក្នុងករណីដែលខ្វះខាតសម្ភារសិក្សា អង្គការនឹងធ្វើការជួយឧបត្ថម្ភភ្លាមៗដើម្បីលើកទឹកចិត្តក្នុងការរៀនសូត្រ។ ទោះជាយ៉ាងនេះក្តី ការអប់រំកុមារតូចៗមានការលំបាក ដោយសារពួកគាត់ស្ថិតក្នុងបរិយាកាសគ្មានការលើកទឹកចិត្តឲ្យស្រលាញ់ការសិក្សាពីសំណាក់អ្នកនៅជុំវិញ ម្យ៉ាងកុមារខ្លះពុំសូវចូលចិត្តសិក្សាផងនោះ។ ដូច្នេះអង្គការ ក៏បានធ្វើការលើកទឹកចិត្តទៅកាន់អាណាព្យាបាលដោយផ្តល់ការឧបត្ថម្ភអង្ករជារៀងរាល់ថ្ងៃអាស្រ័យតាមវត្តមាន និងលទ្ធផលសិក្សានៃកូនតូចៗរបស់គាត់។ ការធ្វើបែបនេះក្នុងគោលបំណងឲ្យអាណាព្យាបាល ព្យាយាមជំរុញ និងលើកទឹកចិត្តកុមារទាំងនោះ ឲ្យស្រលាញ់ការសិក្សា និងទទួលបានលទ្ធផលល្អ។

### ២.២.២ មធ្យមសិក្សា

កុមារដែលស្ថិតក្នុងកម្រិតមធ្យមសិក្សា ត្រូវបានតាមដានការសិក្សាតាមរយៈ លទ្ធផលប្រឡងប្រចាំខែ និងសៀវភៅតាមដានដែលចារដោយគ្រូបន្ទុកថ្នាក់។ ក្រៅពីការឧបត្ថម្ភសម្ភារសិក្សាទៅតាមកម្រិតសិក្សានៃសិស្សនីមួយៗ អង្គការក៏មានវគ្គជំនួយផ្សេងៗ សម្រាប់កុមារដែលមានការសិក្សាខ្សោយ ដែលមានដូចជា វគ្គសិក្សាកំព្យូទ័រ ភាសាអង់គ្លេស និងបារាំងជាដើម។ នៅត្រឹមឆ្នាំ២០១៦ សិស្សដែលស្ថិតក្នុងកម្រិតមធ្យមសិក្សាមានចំនួន៧៥០នាក់ ស្មើនឹង២០ភាគរយ។




### ២.២.៣ សាលាពន្លឿន

សាលាពន្លឿន គឺជាប្រព័ន្ធសិក្សាដែលបង្កើតឡើងដោយអង្គការដើម្បីភាពញញឹមនៃកុមារ ក្នុងគោលបំណង ជួយដល់កុមារដែលមិនបានចូលរៀន ឬបោះបង់ចោលការសិក្សា ឲ្យទទួលបានឱកាសសិក្សាវិញ។ សាលានេះគឺសម្រាប់កុមារដែលមានអាយុចាប់ពី ១០ឆ្នាំ ដល់១៨ឆ្នាំ ដោយប្រព័ន្ធនេះត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំយុវជន និងកីឡា។ ប្រព័ន្ធសិក្សានេះគឺសិស្សអាចទទួលបានការសិក្សា២ថ្នាក់ ក្នុងរយៈពេល១ឆ្នាំ ខណៈដែលការអប់រំទូទៅគឺសិស្សអាចទទួលការអប់រំតែ១ថ្នាក់ក្នុងរយៈពេលមួយឆ្នាំតែប៉ុណ្ណោះ។

នៅក្នុងសាលាពន្លឿន យើងមានសិស្សចំនួន៦៥៩នាក់ ដោយបែងចែកជា២១ថ្នាក់ និងក្នុងមួយថ្នាក់ជាមធ្យមមានសិស្សចំនួន ៣១នាក់។[18] ចំពោះកុមារដែលកំពុងទទួលការសិក្សានៅតាមសាលារៀនរដ្ឋ ក៏មានសិទ្ធទទួលបានការអប់រំនៅថ្នាក់ពន្លឿននេះផងដែរ ដោយអង្គការអនុញ្ញាត

[18] Annaul Activity Report Septermber 2015- August 2016, PSE Pour Un Sourire D´enfant, Page9

ឲ្យក្មេងៗទាំងនោះចូលរៀននៅអង្គការនៅពេលព្រឹក ឬ ថ្ងៃត្រង់អាស្រ័យតាមកាលវិភាគសិក្សារបស់កុមារនៅសាលារដ្ឋ។ នៅឆ្នាំ២០១៦ មានកុមារចំនួន ៥៦០នាក់ដែលសិក្សានៅសាលារដ្ឋបានចូលរៀនក្នុងកម្មវិធីនេះផងដែរ។

កុមារី សុភាព អាយុ១០ឆ្នាំ ដែលបានចូលរៀននៅក្នុងកម្មវិធីនេះបានបញ្ចេញអារម្មណ៍ថា *"សម្រាប់ខ្ញុំ អ្វីដែលកម្មវិធីនេះបានជួយដល់ខ្ញុំនោះគឺ ខ្ញុំអាចអាន និងសរសេរបាន ហើយយើងអាចចំណេញពេលរៀន ព្រោះរយៈពេលមួយឆ្នាំសិក្សាបានដល់តែ២ថ្នាក់ឯណោះ។ ហើយនេះពិតជាបានជួយជំរុញទឹកចិត្តខ្ញុំឲ្យខិតខំប្រឹងប្រែងរៀនសូត្រដោយគ្មានការខ្មាសអៀនផងដែរ។"*

| កម្រិតសិក្សា | ឆ្នាំសិក្សា | កម្មវិធីសិក្សា | ប្រព័ន្ធសិក្សា |
|---|---|---|---|
| បឋមសិក្សា | ឆ្នាំទី១ (ថ្នាក់ទី១ - ២) | ២កម្រិត/១ឆ្នាំ | ប្រព័ន្ធសិក្សាពន្លឿន |
| | ឆ្នាំទី២ (ថ្នាក់ទី៣ - ៤) | ២កម្រិត/១ឆ្នាំ | |
| | ឆ្នាំទី៣ (ថ្នាក់ទី៥ - ៦) | ២កម្រិត/១ឆ្នាំ | |
| អនុវិទ្យាល័យ | ឆ្នាំទី៤ (ថ្នាក់ទី៧ - ៨) | ២កម្រិត/១ឆ្នាំ | |
| | ថ្នាក់ទី៩ | ១កម្រិត/១ឆ្នាំ | ប្រព័ន្ធសិក្សាក្រសួងអប់រំ |
| ប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | | |
| វិទ្យាល័យ | ថ្នាក់ទី១០ | ១កម្រិត/១ឆ្នាំ | ប្រព័ន្ធសិក្សាក្រសួងអប់រំ |
| | ថ្នាក់ទី១១ | ១កម្រិត/១ឆ្នាំ | |
| | ថ្នាក់ទី១២ | ១កម្រិត/១ឆ្នាំ | |
| ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតយភូមិ | | | |

### ២.២.៤ ការអប់រំជំនាញវិជ្ជាជីវៈ

អង្គការក៏បានបង្កើតវិទ្យាស្ថានអប់រំវិជ្ជាជីវៈផ្ទាល់ខ្លួន ដែលជាសាលាសម្រាប់ផ្តល់ជំនាញសម្រាប់សិស្សានុសិស្សយកទៅប្រើប្រាស់សម្រាប់ប្រកបរបរទៅថ្ងៃអនាគត ដែលមានស្តង់ដារ និងទទួលស្គាល់ដោយក្រសួងការងារនៃព្រះរាជាណាចក្រកម្ពុជា។

សាលានេះមានសិស្សានុសិស្សចំនួន១៥០០នាក់ ដែលកំពុងសិក្សាជំនាញផ្សេងៗគ្នា។ អង្គការបានបែងចែកជា៣សាលា ដែលមានជាង ២០ជំនាញ។ សាលាសណ្ឋាគារ និងទេសចរណ៍ (School of Hospitality and Tourism) សាលាពាណិជ្ជកម្ម (School of Business) និងសាលាបច្ចេកវិទ្យា (School of Technology)។ ការសិក្សាជំនាញវិជ្ជាជីវៈបែបនេះ ត្រូវការចំនាយរយៈពេលសិក្សាចំនួន២ ទៅ ៤

ឆ្នាំ អាស្រ័យតាមប្រភេទនៃជំនាញ និងលក្ខខណ្ឌនៃចំណេះដឹងទូទៅផ្សេងៗគ្នា។

**២.២.៤.១ ថ្នាក់ស្ពានចម្លង និងថ្នាក់ត្រៀម**

ថ្នាក់ស្ពានចម្លងគឺត្រូវបានបង្កើតឡើងដោយ អ្នកជំនាញខាងផ្នែករៀបចំកម្មវិធីសិក្សារបស់អង្គការដើម្បីភាពញញឹមនៃកុមារ ជាមួយក្រសួងអប់រំយុវជន និងកីឡា ក៏ដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃកម្ពុជា។ កម្មវិធីសិក្សានេះ ត្រូវបានរៀបចំឡើងដើម្បីផ្តោតលើកុមារដែលមានអាយុចន្លោះ ១៤ ទៅ ១៦ឆ្នាំ ដែលមិនបានបញ្ចប់ការសិក្សានៅថ្នាក់អនុវិទ្យាល័យ ដើម្បីបន្តការសិក្សានៅសាលាជំនាញវិជ្ជាជីវៈ នៅវិទ្យាស្ថានរបស់អង្គការបន្ថែមទៀត។ ថ្នាក់នេះគឺមានរយៈពេល ១ទៅ២ឆ្នាំ អាស្រ័យទៅលើកម្រិតស្ថានភាពសិក្សានៅថ្នាក់វិទ្យាល័យរបស់ពួកគាត់។ នៅឆ្នាំ២០១៥ ក្រសួងអប់រំយុវជន និងកីឡា ក៏បានទទួលស្គាល់ជាផ្លូវការនូវការប្រឡងថ្នាក់ស្ពានចម្លងនេះជា ការប្រឡងថ្នាក់ជាតិមួយផងដែរ។ លទ្ធផលនៃការប្រឡងរបស់សិស្សនៅថ្នាក់នេះគឺជោគជ័យរហូតដល់ទៅ ៩៤ភាគរយ។

ថ្នាក់ត្រៀម គឺសម្រាប់ក្មេងៗ ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់មហាវិទ្យាល័យឆ្នាំទី១។ ពួកគាត់ត្រូវរៀនបន្ថែម ដើម្បីត្រៀមចូលរៀនវគ្គដែលខ្លួនបានជ្រើសរើស នៅក្នុងនោះមាន ភាសាខ្មែរ គណិតវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា និងកំព្យូទ័រ រួមទាំងទទួលបានការអប់រំទាក់ទងនឹងការត្រៀមខ្លួនសម្រាប់ចូលក្នុងសង្គមការងារ និងការទំនួលខុសត្រូវ ។

**២.៤.១.១. ប្រព័ន្ធនៃការសិក្សាថ្នាក់ត្រៀម**

- **P1៖** - មានអាយុតិចជាង ១៧ឆ្នាំ
  - កុមារចន្លោះថ្នាក់ទី១ ដល់ ទី៤

1. **ផ្នែកកសិកម្ម**

   ជំនាញ៖ - រៀបចំ និងថែទាំសួនច្បារ

- **P2៖** - មានអាយុតិចជាង ១៧ឆ្នាំ
  - កុមារចន្លោះថ្នាក់ទី៥ ដល់ ទី៨

2. **ផ្នែកសំណង់**

   ជំនាញ៖ - តំឡើងអគ្គិសនី
   - តំឡើងម៉ាស៊ីនត្រជាក់
   - បណ្តាញទឹក
   - ជាងកំបោរ រៀបការ៉ូ លាបពណ៌ និងតុបតែង

3. **ផ្នែកកាត់សក់ កែសម្ផស្ស និងស្ប៉ា**

ជំនាញ៖ - កាត់សក់ និងស្ប៉ា

4. **ផ្នែកមេកានិច**

ជំនាញ៖ - ជុសជុលរថយន្ត និងថែទាំរថយន្ត

5. **សណ្ឋាគារ**

ជំនាញ៖ - ចុងភៅ

- សេវាកម្មអាហារ និងភេសជ្ជៈ
- បោកគក់
- បដិសណ្ឋារកិច្ច
- គ្រប់គ្រងម្ហូបអាហារ និងភេសជ្ជៈ
- មគ្គុទេសទេសចរណ៍

- **P3៖** - មានអាយុតិចជាង ១៧ឆ្នាំ
  - កុមារចន្លោះថ្នាក់ទី៩ ដល់ ទី១១

6. **បច្ចេកវិជ្ជាព័ត៌មានវិទ្យា**

ជំនាញ៖ - សរសេរកម្មវិធី

7. **ពាណិជ្ជកម្ម**

ជំនាញ៖ - រដ្ឋបាល និងគណនេយ្យ

- អ្នកលក់

- **P4៖** - យ៉ាងតិចចប់ថ្នាក់ទី១២

8. **ពាណិជ្ជកម្ម**

ជំនាញ៖ - គ្រប់គ្រងរដ្ឋបាល

- គ្រប់គ្រងទីផ្សារ និងការលក់

### ២.២.៤.១.២ ម៉ោងសិក្សាតាមកម្រិតនីមួយៗ

| ថ្នាក់ P1 | | | | |
|---|---|---|---|---|
| ល.រ | មុខវិជ្ជា | ម៉ោងសិក្សា/សប្ដាហ៍ (១ម៉ោង=៥០នាទី) | សប្ដាហ៍/ឆ្នាំ | ម៉ោងសរុប/ឆ្នាំ |
| ១ | ភាសាខ្មែរ | ៨ | ២៧ | ២១៦ |

| | | | | |
|---|---|---|---|---|
| ២ | គណិតវិទ្យា | ៨ | ២៧ | ២១៦ |
| ៣ | ភូមិវិទ្យា | ០ | ២៧ | ០ |
| ៤ | ប្រវត្តិវិទ្យា | ០ | ២៧ | ០ |
| ថ្នាក់ P2 | | | | |
| ល.រ | មុខវិជ្ជា | ម៉ោងសិក្សា/សប្តាហ៍ (១ម៉ោង=៥០នាទី) | សប្តាហ៍/ឆ្នាំ | ម៉ោងសរុប/ឆ្នាំ |
| ១ | ភាសាខ្មែរ | ៦ | ២៧ | ១៦២ |
| ២ | គណិតវិទ្យា | ៦ | ២៧ | ១៦២ |
| ៣ | ភូមិវិទ្យា | ១ | ២៧ | ២៧ |
| ៤ | ប្រវត្តិវិទ្យា | ១ | ២៧ | ២៧ |
| ៥ | កំព្យូទ័រ | ៤ | ២៧ | ១០៨ |
| ថ្នាក់ P3 | | | | |
| ល.រ | មុខវិជ្ជា | ម៉ោងសិក្សា/សប្តាហ៍ (១ម៉ោង=៥០នាទី) | សប្តាហ៍/ឆ្នាំ | ម៉ោងសរុប/ឆ្នាំ |
| ១ | ភាសាខ្មែរ | ៤ | ២៧ | ១០៨ |
| ២ | គណិតវិទ្យា | ៤ | ២៧ | ១០៨ |
| ៣ | ភូមិវិទ្យា | ១ | ២៧ | ២៧ |
| ៤ | ប្រវត្តិវិទ្យា | ១ | ២៧ | ២៧ |
| ៥ | កំព្យូទ័រ | ៤ | ២៧ | ១០៨ |
| ថ្នាក់ P4 | | | | |
| ល.រ | មុខវិជ្ជា | ម៉ោងសិក្សា/សប្តាហ៍ (១ម៉ោង=៥០នាទី) | សប្តាហ៍/ឆ្នាំ | ម៉ោងសរុប/ឆ្នាំ |
| ១ | ភាសាខ្មែរ | ០ | ២៧ | ០ |
| ២ | គណិតវិទ្យា | ៤ | ២៧ | ១០៨ |
| ៣ | ភូមិវិទ្យា | ១ | ២៧ | ២៧ |
| ៤ | ប្រវត្តិវិទ្យា | ០ | ២៧ | ០ |
| ៥ | កំព្យូទ័រ | ៤ | ២៧ | ១០៨ |

### ២.២.៤.២ សាលាសណ្ឋាគារ និងទេសចរណ៍

សាលានេះ មានជំនាញសម្រាប់ឲ្យសិស្សជ្រើសរើសទៅតាមចំនង់ចំណូលចិត្តចំនួន៦ជំនាញ។ ការសិក្សានៅក្នុងសាលានេះ គឺមានរយៈពេល២ឆ្នាំ ហើយកុមារអាចចូលរៀនគ្រប់កម្រិត ទោះជាមិនទាន់បានបញ្ចប់ការសិក្សាថ្នាក់ឧត្តមក៏ដោយ។ សិស្សភាគច្រើន ជាសិស្សដែលមានកម្រិត ថ្នាក់ទី៧ ឬ ទី៨ ដោយគាត់ត្រូវឆ្លងកាត់ថ្នាក់ស្ពានចម្លងរួចរាល់ ទើបអាចចូលសាលានេះបាន។

- ផ្នែកផលិតអាហារ (Food Production and Pastry)
- ផ្នែកអ្នកទទួលភ្ញៀវ (Front Office)
- ផ្នែកសេវាអាហារ និងភេសជ្ជៈ (Food and Beverage Service)
- ផ្នែកមើលថែទាំផ្ទះ និងបោកគក់ (Housekeeping and Laundry)
- ផ្នែកជាត់មុខ និងម៉ាស្សា (Beauty Spa and Massage)
- ផ្នែកអ្នកនាំភ្ញៀវ (Tour Guides)

ចំពោះផ្នែកសណ្ឋាគារ ចាប់តាំងពីឆ្នាំ២០១៣ អង្គការបានអភិវឌ្ឍន៍ និងពង្រឹងកម្រិតអប់រំរបស់ខ្លួនឲ្យត្រូវនឹងស្តង់ដារអាស៊ាន ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងទីផ្សារការងាររបស់សិស្ស ដោយគាត់អាចទទួលបានសញ្ញាបត្រដែលទទួលស្គាល់ដោយអាស៊ាន ហើយអាចទទួលបានការងារក្នុងប្រទេសអាស៊ានដទៃដោយងាយស្រួល។ មាតិកានៃការសិក្សា ត្រូវបានបង្ហាត់បង្រៀនទៅកាន់លោកគ្រូ អ្នកគ្រូយ៉ាងល្អិតល្អន់ និងមានការប្រឡង៣លើក ដែលទទួលស្គាល់ជាផ្លូវការផងដែរ។ ទន្ទឹមនឹងការសិក្សាទ្រឹស្តី សិស្សានុសិស្សទាំងអស់ក៏តម្រូវឲ្យមានការអនុវត្តន៍ផ្ទាល់នៅក្នុងសណ្ឋាគារ និងភោជនីយដ្ឋានដែលមានស្រាប់នៅក្នុងសាលាផងដែរ។



| |
|---|
| *ផ្នែកផលិតអាហារ* |
| **រយៈពេលសិក្សា** |
| ២ឆ្នាំ<br>ឆ្នាំទី១៖ ចាប់ផ្តើមពីខែកញ្ញា ដល់ ខែកក្កដា<br>ឆ្នាំទី២៖ ចុះកម្មសិក្សារយៈពេល ៦ខែ (ខែកញ្ញា ដល់ខែកុម្ភៈ) និងចូលរៀនវិញ ខែមីនា |
| **កម្មវិធីសិក្សា** |
| សិស្សត្រូវបានបែងចែកជា២ក្រុម ថ្នាក់អនុវត្តន៍ និងថ្នាក់ទ្រឹស្តី។ ដោយកន្លែងអនុវត្តន៍មានផ្ទាល់នៅក្នុងអង្គការ "ភោជនីយដ្ឋាន Lotus Blance" បញ្ជីមុខម្ហូបត្រូវបានផ្លាស់ប្តូរជារៀងរាល់២សប្តាហ៍<br>**ការបណ្តុះបណ្តាលនេះមានរយៈពេល ១៣ម៉ោងក្នុងមួយសប្តាហ៍៖**<br>• ចំណេះដឹងទូទៅផ្នែកសណ្ឋាគារ<br>• អាហាររូបត្ថម្ភ<br>• អនាម័យ<br>• បញ្ជីមុខម្ហូប<br>**ការបណ្តុះបណ្តាលទូទៅមានរយៈពេល ២៨ម៉ោងក្នុងមួយសប្តាហ៍៖**<br>• សិក្សាពីក្រមសីលធម៌ និងជំនាញវិជ្ជាជីវៈ<br>• កីឡា<br>• ភាសាខ្មែរ<br>• ភាសាអង់គ្លេស<br>• គណិតវិទ្យា |
| **សមត្ថភាព កម្មសិក្សា និងការងារ** |
| ទទួលបានសញ្ញាបត្រមួយប្រកបដោយជំនាញដល្អទាក់ទងនឹងការចម្អិនម្ហូបលោកខាងលិច និងអាស៊ី |
| • ភោជនីយដ្ឋាន<br>• សណ្ឋាគារ<br>• អាហារដ្ឋាន និងអាហារសម្រន់ |

| *ផ្នែកអ្នកទទួលភ្ញៀវ (Front Office)* |
|---|
| **រយៈពេលសិក្សា** |
| ២ឆ្នាំ<br>ឆ្នាំទី១៖ ចាប់ពីខែកញ្ញា ដល់ ខែកក្កដា<br>កម្មសិក្សា៖ រយៈពេល២ខែ (កក្កដា ដល់ សីហា)<br>ឆ្នាំទី២៖ ចាប់ពីខែកញ្ញា ដល់ ខែមិថុនា<br>កម្មសិក្សា: រយៈពេល៣ខែ (កក្កដា ដល់ កញ្ញា) |
| **កម្មវិធីសិក្សា** |
| **បណ្តុះបណ្តាលវិជ្ជាជីវៈ ១៥ម៉ោង/សប្តាហ៍៖**<br>• ចំណេះដឹងទូទៅផ្នែកសណ្ឋាគារ<br>• ទំនាក់ទំនងអតិថជន<br>• ចំណេះដឹងទាក់ទងនឹងការងារអ្នកទទួលភ្ញៀវ(Front Office) ជាពិសេសផ្នែក Solfware<br>**បណ្តុះបណ្តាលចំណេះដឹងទូទៅ ២៧ម៉ោង/សប្តាហ៍៖**<br>• សិក្សាពីក្រមសីលធម៌ និងជំនាញវិជ្ជាជីវៈ<br>• កីឡា<br>• ភាសាខ្មែរ<br>• ភាសាអង់គ្លេស<br>• គណិតវិទ្យា |
| **សមត្ថភាព កម្មសិក្សា និងការងារ** |
| ទទួលបានសញ្ញាបត្រប្រកបដោយគុណភាព |
| • ភោជនីយដ្ឋាន<br>• សណ្ឋាគារ<br>• ក្រុមហ៊ុន<br>• អង្គការក្រៅរដ្ឋាភិបាល |

| |
|---|
| ***ផ្នែកសេវាអាហារ និងភេសជ្ជៈ*** |
| **រយៈពេលសិក្សា** |
| ២ឆ្នាំ<br>ឆ្នាំទី១៖ ចាប់ផ្តើមពីខែកញ្ញា ដល់ ខែកក្កដា<br>ឆ្នាំទី២៖ ចុះកម្មសិក្សារយៈពេល ៦ខែ (ខែកញ្ញា ដល់ខែកុម្ភៈ) និងចូលរៀនវិញ ខែមីនា |
| **កម្មវិធីសិក្សា** |
| សិស្សត្រូវបានបែងចែកជា២ក្រុម ថ្នាក់អនុវត្តន៍ និងថ្នាក់ទ្រឹស្តី។ ដោយកន្លែងអនុវត្តន៍មានផ្ទាល់នៅក្នុងអង្គការ "ភោជនីយដ្ឋាន Lotus Blance" ដោយត្រូវបានផ្លាស់ប្តូរបញ្ជីមុខម្ហូបជារៀងរាល់២សប្តាហ៍ផងដែរ<br>**ការបណ្តុះបណ្តាលនេះមានរយៈពេល ១៦ម៉ោងក្នុងមួយសប្តាហ៍៖**<br>• ចំណេះដឹងទូទៅផ្នែកសណ្ឋាគារ<br>• ជំនាញសេវាកម្មភោជនីយដ្ឋាន<br>• ចំណេះដឹងអំពីស្រា<br>• បច្ចេកទេសសេវាកម្មបារ<br>• អនាម័យអាហារ<br>• បញ្ជីមុខម្ហូប<br>**ការបណ្តុះបណ្តាលទូទៅមានរយៈពេល ២៨ម៉ោងក្នុងមួយសប្តាហ៍៖**<br>• សិក្សាពីក្រមសីលធម៌ និងជំនាញវិជ្ជាជីវៈ<br>• កីឡា<br>• ភាសាខ្មែរ<br>• ភាសាអង់គ្លេស<br>• គណិតវិទ្យា |
| **សមត្ថភាព កម្មសិក្សា និងការងារ** |
| ទទួលបានសញ្ញាបត្រប្រកបដោយគុណភាព។<br>• សេវាកម្មភោជនីយដ្ឋាន<br>• ផ្នែកការកក់ ឬ កម្មង់ |

| |
|---|
| • ផ្នែកវិក័យបត្រ និងសាច់ប្រាក់<br>• ការស្វាគមន៍អតិថជន |
| • ភោជនីយដ្ឋាន<br>• សណ្ឋាគារ |

| |
|---|
| *ផ្នែកសេវាកម្មបោកគក់ និងរៀបចំបន្ទប់* |
| **រយៈពេលសិក្សា** |
| រយៈពេល១៥ខែ<br>- ចាប់ពីខែកញ្ញា ដល់ ខែកក្កដា<br>កម្មសិក្សា: រយៈពេល៣ខែ (កញ្ញា ដល់ វិច្ឆិកា) |
| **កម្មវិធីសិក្សា** |
| **បណ្តុះបណ្តាលវិជ្ជាជីវៈ ១៥ម៉ោង/សប្តាហ៍៖**<br>• ចំណេះដឹងទូទៅផ្នែកសណ្ឋាគារ<br>• សេវាកម្មរៀបចំបន្ទប់<br>• បោកគក់<br>**បណ្តុះបណ្តាលចំណេះដឹងទូទៅ ២៧ម៉ោង/សប្តាហ៍៖**<br>• សិក្សាពីក្រមសីលធម៌ និងជំនាញវិជ្ជាជីវៈ<br>• កីឡា<br>• ភាសាខ្មែរ<br>• ភាសាអង់គ្លេស<br>• គណិតវិទ្យា |
| **សមត្ថភាព កម្មសិក្សា និងការងារ** |
| ទទួលបានសញ្ញាបត្រប្រកបដោយគុណភាព<br>- សេវារៀបចំបន្ទប់នៅក្នុងសណ្ឋាគារ<br>- គ្រប់គ្រងការបោកគក់<br>- ការថែរក្សាផ្ទះ |
| • សណ្ឋាគារ<br>• បោកគក់ និងរៀបចំផ្ទះឯកជន |

ចំពោះផ្នែកទេសចរណ៍(អ្នកនាំភ្ញៀវ) គឺអង្គការបានសហការជាមួយសាលាដែលជាដៃគូនៅប្រទេសវៀតណាម ដូច្នេះសិស្សានុសិស្សដែលជ្រើសរើសជំនាញនេះ នឹងទទួលបានអាហារូបករណ៍ទៅសិក្សានៅទីនោះរយៈពេល២ឆ្នាំកន្លះ។

**២.២.៤.៣ សាលាពាណិជ្ជកម្ម**

ដោយមានការជួយជ្រោមជ្រែងពីក្រុមការងារទាំងក្នុង និងក្រៅប្រទេស សាលានេះមានសិស្សចំនួន ៣៥២នាក់ ទទួលបានការបង្រៀនពីគ្រូដែលមានបទពិសោធន៍ជាច្រើន ទាំងគ្រូនៅក្នុងសាលាយើងផ្ទាល់ និងគ្រូដែលមានពីខាងក្រៅផងដែរ។ លើសពីនេះ យើងក៏មានរៀបចំការប្រកួតផ្សេងៗ ដូចជា ករណីសិក្សា និងការសាកល្បងការងារ ដែលជាសកម្មភាពបន្ថែមសម្រាប់ការសិក្សា។ អ្នកគ្រប់គ្រងកម្មវិធី ក៏បានធ្វើការផ្លាស់ប្តូរម៉ោងសិក្សាក្នុងគោលបំណង បន្ថែមម៉ោងសម្រាប់សិស្សនិស្សិតធ្វើការស្វ័យសិក្សា ដោយមិនបានកាត់បន្ថយពេលវេលាសិក្សាក្នុងថ្នាក់ឡើយ។

នៅក្នុងសាលានេះត្រូវបានបែងចែកជា៣កម្រិត៖

**កម្រិតបរិញ្ញបត្រ៖** តម្រូវឲ្យរៀនចប់ថ្នាក់ទី១២ ឬធ្លាក់ថ្នាក់ទី១២ក្នុងការចូលរៀន។ មានជំនាញ២គឺ៖

- ផ្នែករដ្ឋបាលសាធារណៈ និងគណនេយ្យ គ្រប់គ្រង
- ផ្នែកលក់ និងទីផ្សារ

**កម្រិតសញ្ញបត្រវិជ្ជាជីវៈជាន់ខ្ពស់**

- ផ្នែកលក់រាយ

**កម្រិតសញ្ញបត្រវិជ្ជាជីវៈ**

- ផ្នែករដ្ឋបាលសាធារណៈ និងគណនេយ្យ
- ផ្នែកលក់រាយ

អាស្រ័យទៅតាមផ្នែកនីមួយៗ រយៈពេលនៃការសិក្សាគឺមានរយៈពេលពី ២ទៅ៣ឆ្នាំ ដោយមិនរៀបបញ្ចូលការសិក្សាត្រៀមរយៈពេលមួយឆ្នាំឡើយ។

| *ផ្នែកគណនេយ្យ រដ្ឋបាល និងផ្នែកលក់* |
|---|
| **រយៈពេលសិក្សា** |
| ២ឆ្នាំ<br>ឆ្នាំទី១៖ ចាប់ពីខែកញ្ញា ដល់ ខែមិថុនា<br>កម្មសិក្សា៖ រយៈពេល២ខែ (កក្កដា ដល់ សីហា) |

ឆ្នាំទី២៖ ចាប់ពីខែកញ្ញា ដល់ ខែមិថុនា

កម្មសិក្សា៖ រយៈពេល៣ខែ (កក្កដា ដល់ កញ្ញា)

**កម្មវិធីសិក្សា**

**ឆ្នាំទី១**

- ការគ្រប់គ្រងពេលវេលា
- ការកំណត់អាទិភាព
- ការធ្វើផែនការ
- ការរៀបចំសម្រាប់ការពិភាក្សាការងារ
- មុខងារសេវាកម្ម
- មុខងារនៃសេវាកម្មលក់
- ទូរស័ព្ទ
- ការគ្រប់គ្រងកិច្ចប្រជុំ

**ឆ្នាំទី២**

- ការដោះស្រាយបញ្ហា
- អាកប្បកិរិយាក្នុងការិយាល័យ
- ការគ្រប់គ្រងស្តុក
- គណនេយ្យ ឬ ការលក់ដែលយោងទៅតាមផ្នែក

**ការបណ្តុះបណ្តាលទូទៅ**

**ឆ្នាំទី១**

- លេខាធិការ (ទាំងទ្រឹស្តី និងការអនុវត្តន៍)
- ជំនាញកំព្យូទ័រ
- គណនេយ្យទូទៅ
- ភាសាខ្មែរ
- គណិតវិទ្យា VAT ការប្រាក់
- កីឡា
- សិក្សាពីសង្គម និងជំនាញវិជ្ជាជីវៈ
- ភាសាបារាំង

| |
|---|
| **ឆ្នាំទី២**<br>• ភាសាអង់គ្លេស<br>• ការគ្រប់គ្រងអាជីវកម្ម<br>• ជំនាញកំព្យូទ័រ<br>• កីឡា<br>• សិក្សាពីសង្គម និងជំនាញវិជ្ជាជីវៈ<br>• ភាសាបារាំង |
| **សមត្ថភាព កម្មសិក្សា និងការងារ** |
| - ចេះជំនាញគ្រប់គ្រង<br>- ភារកិច្ចក្នុងផ្នែកលេខាធិការ និងរដ្ឋបាល<br>- ការងារអ្នកលក់ក្នុងហាង<br>- ភាសាអង់គ្លេស<br>- ភាសាបារាំង |
| • អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ<br>• អ្នកគ្រប់គ្រោង<br>• ហាងលក់សម្ភារទំនើប |

| |
|---|
| ***ផ្នែកគ្រប់គ្រង*** |
| **រយៈពេលសិក្សា** |
| ៣ឆ្នាំ<br>ឆ្នាំទី១៖ ចាប់ពីខែសីហា ដល់ ខែកក្កដា<br>កម្មសិក្សា៖ រយៈពេល២ខែ (កក្កដា ដល់ សីហា)<br>ឆ្នាំទី២៖ ចាប់ពីខែតុលា ដល់ ខែកក្កដា<br>កម្មសិក្សា៖ រយៈពេល៣ខែ (កក្កដា ដល់ កញ្ញា)<br>ឆ្នាំទី៣៖ ចាប់ពីខែកុម្ភៈ ដល់ ខែកក្កដា<br>កម្មសិក្សា៖ រយៈពេល៦ខែ (សីហា ដល់ មករា) |

| **កម្មវិធីសិក្សា** |
|---|
| • ការគ្រប់គ្រងក្រុមហ៊ុន<br>• គណនេយ្យទូទៅ<br>• មីក្រូសេដ្ឋកិច្ច<br>• ភាសាអង់គ្លេស<br>• ភាសាបារាំង<br>• កំព្យូទ័រ<br>• ក្រមសីលធម៌<br>• កីឡា<br>• ភាសាខ្មែរ<br>• គណិតវិទ្យា |
| **សមត្ថភាព កម្មសិក្សា និងការងារ** |
| - ចេះជំនាញអង្គភាព<br>- ផ្នែកលក់ និងសេវាកម្មទីផ្សារ<br>- ភាសាអង់គ្លេស និងបារាំង |
| • អង្គការក្រៅរដ្ឋាភិបាល<br>• ខាងរដ្ឋបាល |

**២.២.៤.៤ សាលាបច្ចេកទេស**

សាលានេះត្រូវបានបែងចែកជា៣ផ្នែក ដែលមានទាំងសិស្សប្រុស និងស្រីរួមបញ្ចូលគ្នា។ ផ្នែកម៉ាស៊ីន និងផ្នែកសំណង់មិនត្រូវបានដាក់លក្ខខណ្ឌក្នុងការចូលរៀនទេ គឺកុមារដែលរៀនត្រឹមថ្នាក់អនុវិទ្យាល័យក៏មានសិទ្ធទទួលបានការសិក្សានេះផងដែរ។

ការអប់រំគ្រប់ផ្នែករបស់អង្គការ គឺត្រូវបានបង្រៀនដោយយកចិត្តទុកដាក់ ពីសំណាក់សាស្ត្រាចារ្យដែលមានជំនាញក្នុងមុខវិជ្ជានោះ។ តួយ៉ាងអង្គការបានទទួលការសហការពី ក្រុមហ៊ុន Norauto ដែលជាក្រុមហ៊ុនដែលមានប្រវត្តិ និងមានជំនាញខ្ពស់ទាក់ទងនឹងការជុសជុលគ្រឿងរថយន្ត ដែលត្រូវបានបង្កើតឡើងមុនដំបូងបំផុតនៅប្រទេសបារាំងនៅឆ្នាំ១២៨២។ សម្រាប់ផ្នែកប្រព័ន្ធផ្សព្វផ្សាយ ក៏មានការសហការពីលោក Patrice Leconte ដែលជាអ្នកដឹកនាំរឿងដ៏ល្បីនៅ

ប្រទេសបារាំង ហើយការសិក្សាថ្នាក់នេះតម្រូវឲ្យសិស្សានុសិស្សបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា។

**ផ្នែកម៉ាស៊ីន**

- ជំនាញជាងជុសជុលរថយន្ត (ជុសជុល និងថែរក្សារថយន្ត)
- ជំនាញជាងជុសជុលម៉ូតូ (ជុសជុល និងថែរក្សាម៉ូតូ)

**ផ្នែកសំណង់**

- ជំនាញប្រព័ន្ធអគ្គិសនី
- ជំនាញប្រព័ន្ធទឹក និងម៉ាស៊ីនត្រជាក់
- ជំនាញលាបកំបោរ លាបពណ៌ និង តុបតែង



**ផ្នែកប្រព័ន្ធផ្សព្វផ្សាយ**

- ជំនាញការផលិត (Pre-Production)
- ជំនាញថតរូប
- ជំនាញកាត់ត (Editing)
- ជំនាញ Post-Production



| *ផ្នែកជុសជុលម៉ូតូ និងរថយន្ត* |
|---|
| **រយៈពេលសិក្សា** |
| ២ឆ្នាំ<br>ឆ្នាំទី១៖ ចាប់ពីខែកញ្ញា ដល់ ខែកក្កដា<br>កម្មសិក្សា៖ រយៈពេល៦សប្តាហ៍ (កក្កដា ដល់ សីហា)<br>ឆ្នាំទី២៖ ចាប់បីខែកញ្ញា ដល់ ខែកក្កដា<br>កម្មសិក្សា៖ រយៈពេល១៦សប្តាហ៍ (កក្កដា ដល់ តុលា) |

**កម្មវិធីសិក្សា**

**ឆ្នាំទី១៖ សិក្សា ១៧ម៉ោង/សប្តាហ៍**

- ជំនាញវិជ្ជាជីវៈ
- អនាម័យ និងសុវត្ថិភាព
- សមាសភាគ និងផ្នែកនៃរថយន្ត
- គំនូរ និងផែនការមេកានិច
- កាងារធ្វើដោយដៃ Manual Adjustment Work
- ផ្សារដែក
- ការបូមសាំង
- មូលដ្ឋាននៃប្រព័ន្ធអគ្គិសនី
- ការថៃទាំរថយន្ត
- ការជួសជុល និងថៃទាំសំបកកង់រថយន្ត

**ឆ្នាំទី២៖ សិក្សា ២០ម៉ោង/សប្តាហ៍**

- Repairing the Exhaust system
- Reparing the Break system
- Repariign the Cooling system
- Repairing the steering system
- Reparing the suspension system
- Reparing the A/C system
- Reparing the electronic circuit
- Reparing the transmission system
- Revision of the 1$^{st}$ year modules to prepare the final exam

**ការបណ្តុះបណ្តាលទូទៅ**

- ភាសាអង់គ្លេស
- ក្រមសីលធម៌
- ជំនាញកំព្យូទ័រ
- កីឡា

- ភាសាខ្មែរ
- គណិត

**សមត្ថភាព កម្មសិក្សា និងការងារ**

- ជំនាញជួសជុលរថយន្ត ម៉ូតូ ម៉ាស៊ីនត្រជាក់ អគ្គីសនី
- អាចប្រើប្រាស់គ្រឿងម៉ាស៊ីន
- ផ្សារដែក

*ផ្នែកសង់អាគារ*

**រយៈពេលសិក្សា**

២ឆ្នាំ

ឆ្នាំទី១៖ ចាប់ពីខែកញ្ញា ដល់ ខែកក្កដា

ឆ្នាំទី២៖ កម្មសិក្សា៖ រយៈពេល៣ខែ (កញ្ញា ដល់ វិច្ឆិកា)

រៀនក្នុងថ្នាក់ ចាប់ពីខែធ្នូ ដល់ ខែឧសភា

កម្មសិក្សា៖ រយៈពេល៣ខែ (មិថុនា ដល់ សីហា)

**កម្មវិធីសិក្សា**

**ការបណ្តុះបណ្តាលវិជ្ជាជីវៈ ២២ម៉ោង/សប្តាហ៍**

- ភាសាអង់គ្លេស
- ក្រមសីលធម៌
- ជំនាញកំព្យូទ័រ
- កីឡា
- ភាសាខ្មែរ
- គណិតវិទ្យា
- សិក្សាពីវជ្ជាជីវៈ និងបរិស្ថាន

**សមត្ថភាព កម្មសិក្សា និងការងារ**

- ប្រក់គ្រឿង គំនូរ
- បណ្តាញទឹក
- ផ្នែកអគ្គិសនី

## ២.៣ យុទ្ធសាស្ត្រក្នុងការជំរុញការអប់រំប្រកបដោយប្រសិទ្ធភាព

### ២.៣.១. ចំណាប់វិធីក្នុងការជ្រើសរើសកុមារ

ដោយសារកុមារក្រីក្រមានច្រើន ទាំងនៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាលខេត្តនានា ការជ្រើសរើសកុមារត្រូវបានប្រព្រឹត្តឡើងទៅតាម **៤លក្ខខណ្ឌ**។ កុមារគោលដៅរបស់អង្គការ ត្រូវបានកំណត់ដោយស្ថានភាពរស់នៅ ដោយកុមារនោះជាកុមារដែលមានគ្រួសារក្រីក្រខ្លាំង កុមារដែលរស់នៅក្នុងគំនរសំរាម និងកុមារដែលរស់នៅតំបន់ជាយទីរាជធានីភ្នំពេញ។

**លក្ខខណ្ឌទី១** គឺយើងពិនិត្យមើលប្រាក់ចំណូលរបស់គាត់ក្នុងមួយថ្ងៃ ត្រូវមានកម្រិតតិចជាង ១ដុល្លារ ក្នុងសមាជិកគ្រួសារម្នាក់។

**លក្ខខណ្ឌទី២** គឺតម្រូវឲ្យពួកគាត់មានទីលំនៅអចិន្ត្រៃយ៍នៅតំបន់នោះរយៈពេលយ៉ាងហោចណាស់១ឆ្នាំ ដោយយើងធ្វើការសហការជាមួយអាជ្ញាធរក្នុងការសិក្សាតាមដានរឿងនោះ។

**លក្ខខណ្ឌទី៣** គឺពួកគាត់ជាក្មេងពិការ ឬ ក្មេងកំព្រា ឬ ស្ថិតក្នុងគ្រួសារដែលមានកូនច្រើន។

**លក្ខខណ្ឌទី៤** គឺពួកគាត់ទីទ័លក្រ ហើយមកដល់អង្គការសុំស្នាក់អាស្រ័យ និងចូលរៀនជាដើម។

នៅពេលដែលអង្គការពិនិត្យឃើញ កុមារនោះមានចូលលក្ខខណ្ឌណាមួយនៃលក្ខខណ្ឌទាំង៤ខាងលើ អង្គការនឹងចុះទៅមូលដ្ឋានផ្ទាល់ដើម្បីធ្វើការសិក្សា និងតាមដាន ក៏ដូចជាសម្រេចឲ្យពួកគាត់ចូលក្នុងអង្គការ ឬយ៉ាងណា។ រយៈពេលនៃការប្រតិបត្តិការនេះ គឺចាប់ពី១សប្តាហ៍ រហូតដល់ ១ខែ អាស្រ័យតាមស្ថានភាពជាក់ស្តែង ព្រោះមានកុមារគោលដៅច្រើនក្នុងការចុះតាមដាន។

### ២.៣.២ ការពង្រឹងគុណភាពគ្រូបង្រៀន

បុគ្គលិក និងគ្រូបង្រៀន ក៏ជាផ្នែកមួយនៃការបង្កើនគុណភាពនៃការអប់រំផងដែរ។ នៅឆ្នាំ ២០១៦ អង្គការមានបុគ្គលិករួមទាំងអស់ចំនួន៦១៨នាក់ ដែលក្នុងនោះ៩៥ភាគរយ ជាជនជាតិខ្មែរ។

#### ២.៣.២.១ ការជ្រើសរើសបុគ្គលិក

ការជ្រើសរើសបុគ្គលិកត្រូវបានធ្វើឡើងជា ២ដំណាក់កាលៈ

- ✓ ដំណាក់កាល១ៈ ការសម្ភាសន៍
- ✓ ដំណាក់កាល២ៈ ការបង្រៀនសាកល្បង ដោយបេក្ខជនមានរយៈពេល១ម៉ោង ក្នុងការបង្រៀនដែលស្ថិតក្នុងការអង្កេតរបស់គណៈកម្មការផ្នែកគរុកោសល្យ និងសាលា។

#### ២.៣.២.២ ការបណ្តុះបណ្តាលបន្ថែម

ក្រោយពីបេក្ខជនត្រូវបានជាប់ ក្លាយជាគ្រូបង្រៀននៅក្នុងអង្គការហើយ អង្គការនឹងធ្វើការណែនាំពីស្ថានភាព បរិស្ថាន និងអនុញ្ញាតឲ្យចូលសង្កេតមើលការបង្រៀនរបស់គ្រូដទៃ ១ម៉ោង

ដើម្បីឲ្យយល់ពីចំណាង់វិធីបង្រៀនរបស់អង្គការមុននឹងចាប់ផ្ដើម។

ការមានការបណ្ដុះបណ្ដាលផ្សេងៗត្រូវបានអនុវត្តដូចជា៖

- ✓ គ្រូបង្រៀនត្រូវបានរៀបចំជាក្រុមបច្ចេកទេស ដោយមានការប្រជុំ ២ដង/សប្ដាហ៍
- ✓ ទទួលបានការបណ្ដុះបណ្ដាលបច្ចេកទេសលើវិធីសាស្ត្របង្រៀន
- ✓ ទទួលបានការអនុញ្ញាតឲ្យចូលរួមវគ្គបណ្ដុះបណ្ដាលនានាដែលទាក់ទង។

#### ២.៣.២.៣ ការវាយតម្លៃគ្រូបង្រៀន

គ្រូបង្រៀនត្រូវបានវាយតម្លៃលើការងារចំបង៤គឺ៖

១. ការងារគរុកោសល្យ

២. ការងាររដ្ឋបាល

៣.ការងារវាយតម្លៃចំណេះដឹងសិស្ស

៤. អត្តចរិតការងារ។

### ២.៣.៣ យុទ្ធសាស្ត្រក្នុងការអប់រំ

#### ២.៣.៣.១ ការបង្កើតកម្មវិធីសិក្សាសិក្សា

- កម្មវិធីសិក្សាសិក្សាត្រូវបានបង្កើតឡើង និងចងក្រងដោយនាយកដ្ឋានអភិវឌ្ឍន៍គរុកោសល្យផ្អែកលើ កម្មវិធីសិក្សាសិក្សាគោលការណ៍របស់ក្រសួងអប់រំ
- នាយកដ្ឋានគរុកោសល្យ មានតួនាទីតាមដានជាប្រចាំ និងធ្វើរបាយការណ៍វាយតម្លៃកម្មវិធីសិក្សាដែលបានអនុវត្តន៍ នៅរៀងរាល់ចុងឆ្នាំសិក្សាដើម្បីអភិវឌ្ឍន៍ និងកែសម្រួលសម្រាប់ឆ្នាំសិក្សាបន្ទាប់។

#### ២.៣.៣.២ ការគ្រប់គ្រងវិន័យ

ក្រុមប្រឹក្សាវិន័យ ត្រូវបានបែងចែកជា ២ក្រុមគឺ ក្រុមប្រឹក្សាវិន័យសាលា និងក្រុមប្រឹក្សាវិន័យធំ។

- ក្រុមប្រឹក្សាវិន័យសាលា៖ ត្រូវបានរៀបចំឡើងដោយសាលា ដើម្បីដោះស្រាយបញ្ហាសិស្ស។ សិស្សដែលបានឆ្លងកាត់ក្រុមប្រឹក្សាវិន័យសាលា២ដង នឹងត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាវិន័យធំ ក្នុងករណីដែលមានវិន័យជាលើកទី៣។
- ក្រុមប្រឹក្សាវិន័យធំ៖ ត្រូវបានរៀបចំឡើងដោយគណៈកម្មការ PSE (គណៈកម្មការសាលា នាយកដ្ឋានសង្គម ប្រតិភូ) និងសម្រេចចំពោះករណីដូចជា៖
    - អវត្តមានបន្ថែម ២ដងជាប់ៗគ្នា
    - អវត្តមានបន្ថែម ៥ដងដោយឡែកពីគ្នា
    - បំផ្លាញ ឬ លួច

- មិនគោរពវិន័យ និងប្រើពាក្យមិនគប្បីនឹងគ្រូ
- វាយគ្នា ក្នុង ឬក្រៅសាលា
- ការប្រើប្រាស់គ្រឿងញៀន
- មិនគោរពច្បាប់ច្រើនដង ដោយការព្រមានច្រើនលើក

**២.៣.៣.៣ ការអប់រំចំណេះដឹងទូទៅ**

តាមរបាយការណ៍របស់ក្រសួងអប់រំយុវជន និងកីឡានៅឆ្នាំ២០១៦ ខែមីនាគឺមានសិស្សប្រមាណជា២០ភាគរយ ដែលមិនបានបញ្ចប់ការសិក្សាថ្នាក់បឋម ហើយមានតែសិស្សប្រមាណ ៥៧.៦ភាគរយទេ ដែលបានបន្តការសិក្សានៅថ្នាក់អនុវិទ្យាល័យ និងមាន២៥.៥ភាគរយដែលបានរៀនទម្រង់ទី៦។ តាមទិន្នន័យនេះ យើងអាចវាយតម្លៃបានថាការសិក្សារបស់ក្មេងប នៅមានកម្រិតដែលយើងគួរតែមានការផ្លាស់ប្តូរយុទ្ធសាស្ត្រក្នុងការអប់រំ។

តាមការសិក្សារបស់អង្គការ បានសង្កេតឃើញថាក្មេងៗមួយចំនួន បានបាត់បង់ឱកាសក្នុងការសិក្សាចាប់តាំងពីថ្នាក់បឋមសិក្សា បើកុមាររូបនោះរៀនធ្លាក់ ឬក៏បោះបង់ចោលការសិក្សាដោយសារកត្តាណាមួយ។ ដើម្បីឲ្យក្មេងៗអាចវិលត្រឡប់ទទួលយកការសិក្សាក្នុងសាលាវិញបាន អង្គការបានបង្កើតសាលាពន្លឿន ដែលជាថ្នាក់ពិសេស ដោយពួកគាត់អាចបញ្ចប់ថ្នាក់បឋមសិក្សាត្រឹមរយៈពេលតែ៣ឆ្នាំប៉ុណ្ណោះ។ ម្យ៉ាងដើម្បីឲ្យកុមារយកចិត្តទុកដាក់ក្នុងការសិក្សា អង្គការបានឧបត្ថម្ភសម្ភារសិក្សា សំលៀកបំពាក់ មធ្យោបាយធ្វើដំណើរ និងអាហារផងដែរ។ សម្រាប់មធ្យោបាយធ្វើដំណើរ រួមមានឡានក្រុងរបស់អង្គការ និងកង់ជាដើម។ ម្យ៉ាងអង្គការក៏មានដាក់អ្នកឃ្លាំមើលចំពោះវត្តមានក្នុងការទៅសាលា និងលទ្ធផលនៃការសិក្សាដើម្បីធានាថាកុមារទៅសិក្សាជារៀងរាល់ថ្ងៃ និងរាល់ពេល ហើយទទួលបានការសិក្សា ឬលទ្ធផលប្រឡងល្អប្រសើរសម្រាប់ជីវិតខ្លួនទៅថ្ងៃអនាគត។

ទាក់ទិននឹងការពង្រឹងការសិក្សាវិញ ក្រៅពីកុមារទទួលការអប់រំក្នុងសាលាហើយ អង្គការក៏មានរៀបចំកម្មវិធីសិក្សាសិក្សាក្រៅម៉ោង សម្រាប់សិស្សដែលរៀននៅសាលារដ្ឋ និងសាលារបស់អង្គការ ដោយមានក្លឹបសម្រាប់ធ្វើកិច្ចការសាលា និងក្លឹបអានជាដើម។ ថ្នាក់រៀន បរិស្ថានសិក្សាក៏ជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការពង្រឹងគុណភាពក្នុងការសិក្សាផងដែរ ហេតុដូច្នេះអង្គការបានសាងសង់បណ្ណាល័យចំនួន៦ និងបានផ្តល់សៀវភៅជាច្រើនសម្រាប់ដាក់ក្នុងនោះ ក្នុងគោលបំណងដើម្បីជំរុញឲ្យកុមារស្រលាញ់សៀវភៅ និងការអាន។ លើសពីនេះ អង្គការក៏បានដាក់សម្ភារអនាម័យ រួមទាំងបន្ទប់ទឹក កន្លែងលាងដៃ និងទឹកស្អាតសម្រាប់ផឹកទៅកាន់សាលារដ្ឋដែលជាដៃគូសហការផងដែរ។

ម្យ៉ាង ក៏មានកន្លែងទទួលមើលទារកតូចៗដើម្បីបង្កលក្ខណៈឲ្យឪពុកម្តាយ អាចប្រកបការងារ មុខរបរក្នុងការជួយកាត់បន្ថយបន្ទុកគ្រួសារ និងដើម្បីឲ្យក្មេងៗដទៃដែលដល់អាយុសិក្សា មានឱកាសទទួលបានការសិក្សាដោយមិនបាច់ទៅធ្វើការ ឬនៅមើលប្អូន។




**២.៣.៣.៣.១ ការវាយតម្លៃការសិក្សា**

ការវាយតម្លៃសិស្សប្រចាំខែត្រូវបានកំណត់ឡើងដោយ ៤លក្ខខណ្ឌ រួមមាន៖

១. ពិន្ទុប្រឡងប្រចាំខែ ៧០%

២. ពិន្ទុវត្តមាន ១០%

៣. ពិន្ទុកិច្ចការផ្ទះ ១០%

៤. ពិន្ទុទៅលើជំនាញ ១០%

លើសពីនេះការវាយតម្លៃត្រូវបានប្រព្រឹត្តឡើងជា ៣ទម្រង់៖

| ទម្រង់នៃការវាយតម្លៃ | គោលបំណងនៃការវាយតម្លៃ | រូបភាពនៃការវាយតម្លៃ |
|---|---|---|
| ការវាយតម្លៃជាប្រចាំ | ត្រួតពិនិត្យលើចំណេះដឹងរបស់សិស្សានុសិស្ស ទៅលើការបង្រៀនជាប្រចាំ | វាយតម្លៃតាមរយៈការដាក់សំណួរសរសេរ ទៅតាមមេរៀននីមួយៗ ដែលកំពុងរៀន ឬការប្រតិបត្តិជាក់ស្តែង |
| ការវាយតម្លៃតាមដំណាក់ | ត្រួតពិនិត្យចំណេះដឹ ងក្រោយសិស្សរៀនចប់មេរៀននិងជំពូកនីមួយៗ | វាយតម្លៃតាមដំណាក់កាលតូចៗ នៅពេលបញ្ចប់មេរៀន ឬជំពូក ដែលមានដូចជា សំណួរផ្ទាល់មាត់ សរសេរ និងការប្រតិបត្តិជាក់ស្តែង |
| ការប្រឡងប្រចាំត្រីមាស | វាយតម្លៃលើលទ្ធផលសិក្សារបស់សិស្សដោយផ្អែកលើកម្មវិធីសិក្សាជាគោល | ការប្រឡងប្រចាំត្រីមាស |

#### ២.៣.៣.៤ ការអប់រំអាកប្បកិរិយា និងផ្លូវចិត្ត

ក្រៅពីការផ្តល់ការអប់រំ យ៉ាងយកចិត្តទុកដាក់ចំពោះផ្នែកចំណេះដឹងទូទៅហើយ អង្គការក៏ផ្តល់ការយកចិត្តទុកដាក់ទៅលើអាកប្បកិរិយា និងផ្លូវចិត្តរបស់កុមារផងដែរ។ ព្រោះសុខភាពផ្លូវចិត្តក៏ជាផ្នែកមួយយ៉ាងសំខាន់ សម្រាប់ជំរុញដល់ការទទួលយកចំណេះដឹងឲ្យបានប្រសើរ។

អង្គការ បានផ្តល់ការពិគ្រោះយោបល់សម្រាប់ក្មេង ដោយមានអ្នកបច្ចេកទេសនៅនឹងអង្គការ ហើយក្មេងៗទាំងអស់គឺសុទ្ធតែមានគ្រូ ឬ អ្នកពិគោះយោបល់ផ្ទាល់ខ្លួនទាំងអស់។ ជារៀងរាល់សប្តាហ៍ អង្គការមានគ្រូសម្រាប់តាមដាន និងពិនិត្យអំពីបញ្ហារបស់ពួកគេ និងប្រើប្រាស់វិធីផ្សេងៗជាច្រើនក្នុងការដោះស្រាយបញ្ហា និងអប់រំអាកប្បកិរិយារបស់ពួកគេ។ លើសពីនេះ អង្គការក៏បានអញ្ជើញវាគ្មិនផ្សេងៗ និងព្រះសង្ឃដើម្បីធ្វើសិក្ខាសាលា ឬទេសនាជូនកុមារ និងយុវជនទាំងអស់ស្តាប់ ដើម្បីជាចំណីផ្លូវចិត្តមួយក្នុងការជំរុញឲ្យមានអាកប្បកិរិយាល្អ យល់ដឹងខុសត្រូវ សខ្មៅក្នុងសង្គម។

### ២.៣.៤ យុទ្ធសាស្ត្រក្នុងការតម្រង់ទិសដៅជ្រើសរើសជំនាញ

ការជ្រើសរើសជំនាញ គឺជាផ្នែកមួយសំខាន់ក្នុងការសម្រេចគោលដៅទៅថ្ងៃអនាគត។ មិនថាការជ្រើសរើសជំនាញនៅក្នុងអង្គការ ឬ នៅតាមសកលវិទ្យាល័យក៏ដោយ។ ការជ្រើសរើសជំនាញខុស ធ្វើឲ្យយើងខាតទាំងពេលវេលា ខាតថវិកាផងដែរ។ មុននឹងសិស្សានុសិស្សនៅក្នុងសាលាឈានដល់ការជ្រើសរើសជំនាញ អង្គការតម្រូវឲ្យមានការចូលរៀនថ្នាក់ស្ពានចម្លង ឬថ្នាក់ត្រៀមដើម្បីបន្ថែមចំណេះដឹងបន្ថែមទាក់ទងនឹងសង្គម និងជំនាញទូទៅមួយចំនួនក្នុងការធ្វើការងារ។ ម្យ៉ាង ការសិក្សានៅថ្នាក់នេះ ក៏មានបញ្ចូលបន្ថែមនូវការពន្យល់ពីជំនាញនីមួយៗ ដើម្បីឲ្យសិស្សានុសិស្ស ធ្វើការសម្រេចចិត្តមុននឹងចូលដល់ថ្នាក់សិក្សាជំនាញ។ មួយវិញទៀត អង្គការក៏មានការប្រឡងធ្វើតេស្តសាកល្បង មើលពិន្ទុរបស់គាត់ តើអាចចូលជំនាញនោះបានដែរឬទេ។ ក្នុងករណីដែលពិន្ទុគាត់នៅមានកម្រិត យើងតម្រូវឲ្យគាត់ធ្វើការជ្រើសរើសជំនាញមួយផ្សេងទៀត នឹងធ្វើការប្រឡងម្តងទៀត។ ចំណាំវិធីនេះ គឺត្រូវបានផ្តល់ជូនសិស្សនិស្សិតចំនួន៣ដង មុនពេលដែលអង្គការជាអ្នកសម្រេចជ្រើសរើសមុខជំនាញជូនពួកគាត់។ នេះមានន័យថា ក្នុងករណីសិស្សធ្វើការប្រឡងជ្រើសរើសជំនាញ ៣ដង ប៉ុន្តែនៅតែបរាជ័យ នោះអង្គការនឹងមើលទៅលើសមត្ថភាពគាត់រួចធ្វើការតម្រង់ទិសទៅតាមកម្រិតដែលគាត់មាន។

ក្នុងប្រការខ្លះ ជាពិសេសសម្រាប់សាលាប្រព័ន្ធផ្សព្វផ្សាយ គឺយើងផ្តល់ឱកាសច្រើនចំពោះអ្នកដែលមានចំណង់ចំណូលចិត្ត បូកផ្សំនឹងចំណេះដឹងទូទៅដែលគាត់មាន។ ព្រោះមុខវិជ្ជានេះ ជាមុខវិជ្ជាមួយដែលតម្រូវឲ្យមានចិត្តព្យាយាម អត់ធ្មត់ និងការស្រលាញ់ជាមួយផង។

## ២.៣.៥ សេវាសុខភាព និងសកម្មភាពផ្សេងៗ

### ២.៣.៥.១ សេវាសុខភាព

មិនត្រឹមតែក្មេងៗនៅក្នុងអង្គការប៉ុណ្ណោះ ទេដែលទទួលបានសេវាសុខភាព ប៉ុន្តែរួមទាំងកុមារនៅតាមសាលានៅតំបន់ក្រីក្រ និងឪពុកម្តាយរបស់ពួកគេផងដែរ។ នៅក្នុងអង្គការមានអ្នកជំនាញជាង៣០នាក់ ដែលមានដូចជា វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា គ្រូពេទ្យព្យាបាលដោយចលនា ទន្តពេទ្យ ពេទ្យចិត្តវិទ្យា និងបុគ្គលិកមើលថែទាំ ម្តាយនិងកុមារ រួមទាំងបុគ្គលិកស្ម័គ្រចិត្តមកពីបរទេស ដែលធ្វើការជារៀងរាល់ថ្ងៃផងដែរ។

### ២.៣.៥.២ សកម្មភាពកីឡា និងកម្សាន្ត

កីឡា និងសកម្មភាពកម្សាន្តផ្សេងៗ ក៏ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញការទទួលយកចំណេះដឹង និងចៀសឆ្ងាយពីបញ្ហាមិនល្អទាំងឡាយដែរ។ អង្គការបានរៀបចំ ថ្នាក់កីឡា ថ្នាក់តន្ត្រី ថ្នាក់របាំជាដើម។ សិស្សដែលកំពុងសិក្សានៅសាលា មានប្រមាណជា៤៥០នាក់ កំពុងចូលរៀនក្នុងថ្នាក់ទាំងនោះ។ ក្រៅពីចំណេះដឹងដែលទទួលបានពីសាលា កុមារទាំងអស់មានឱកាសក្នុងការសិក្សា និងស្វែងយល់ពីប្រពៃណី និងវប្បធម៌របស់ខ្លួនទៀតផង។

ថ្នាក់នេះគឺមានជារៀងរាល់ថ្ងៃពេលល្ងាច បន្ទាប់ពីបញ្ចប់ការសិក្សានៅសាលា និងថ្ងៃចុងសប្តាហ៍ផងដែរ។ សម្រាប់សកម្មភាពកីឡា និងកម្សាន្តនេះអង្គការបានបែងចែកចេញជា ១០ថ្នាក់ និងប្រភេទសម្រាប់ឲ្យសិស្សជ្រើសរើស មានដូចជា៖

- ថ្នាក់កីឡាផ្នែកបាល់ (បាល់បោះ បាល់ទាត់)
- ថ្នាក់ Hockey
- ថ្នាក់ស្គីក្តារ
- ថ្នាក់ដៃក្វាន់ដូ
- ថ្នាក់របាំបុរាណ
- ថ្នាក់ល្ខោន



សកម្មភាពកីឡា និង កម្សាន្ត
របស់សិស្ស





អង្គការក៏មានរៀបចំការប្រកួតលក្ខណៈមិត្តភាព ជាមួយអង្គការដទៃជាច្រើននៅក្នុងស្រុក និងក្រៅស្រុកផងដែរ ដើម្បីឲ្យកុមារកាន់តែមានចំណាប់អារម្មណ៍ក្នុងការរៀន ក៏ដូចជាបង្កើនសមត្ថភាព។ នៅឆ្នាំ២០១៦ អង្គការក៏បានសហការជាមួយក្រុមកីឡាបាល់ទាត់ដ៏ល្បី Real Madrid Foundation ក្នុងគោលបំណងលើកទឹកចិត្តកុមារ និងបង្កើនគុណភាពក្នុងវិស័យកីឡាផងដែរ។

ក្រៅពីសកម្មភាពកម្សាន្តប្រចាំថ្ងៃ ក៏មានសកម្មភាពកម្សាន្តប្រចាំឆ្នាំ។ ជារៀងរាល់ឆ្នាំមានសិស្សប្រមាណ ៣២០០នាក់ ចូលរួមបោះជំរុំប្រចាំឆ្នាំ ដែលប្រព្រឹត្តនៅកំឡុងខែសីហា នៅតាមសហគមន៍របស់កុមាររស់នៅផ្ទាល់ និងនៅអង្គការនៅទីស្នាក់ការកណ្តាល។ អង្គការបង្កើតកម្មវិធីសិក្សានេះឡើង ក្នុងគោលបំណង ឲ្យកុមារទទួលបានបទពិសោធន៍ ការកម្សាន្តហើយក៏មានបង្កើតសកម្មភាពមួយចំនួនសម្រាប់បង្រៀនកុមារនៅពេលនោះដែរ។

## ២.៤ សមិទ្ធផល

### ២.៤.១ សមិទ្ធផលក្នុងការបណ្តុះបណ្តាលអប់រំ

- បានពង្រីកកម្មវិធីសិក្សាថ្នាក់ពន្លឿន ទៅកាន់រាជធានីខេត្តចំនួន៥ ដែលមានដូចជារាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហានុ ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ។ ក្នុងនោះផងដែរ មានថ្នាក់ចំនួន ១២៥ នៅ១២៥បឋមសិក្សា។
- គ្រូបង្រៀនដែលស្ថិតនៅក្នុងក្រមខណ្ឌក្រសួងអប់រំទទួលបានការបណ្តុះបណ្តាលបន្ថែមអំពីកម្មវិធីសិក្សាសិក្សាថ្នាក់ពន្លឿន ដែលធ្វើការបណ្តុះបណ្តាលដោយក្រុមរបស់អង្គការផ្ទាល់។
- សហការជួយអង្គការ STEP ដោយផ្ទាល់ការអប់រំដល់កុមារដែលស្ថិតនៅក្នុងសមាគមន៍ភូមិនៃស្នាមញញឹម មានទីតាំងនៅម្តុំព្រៃសរ ខណ្ឌដង្កោ (Smile Village Community) ដែលត្រូវបានសាងសង់សម្រាប់គ្រួសារដែលខ្វះខាតទីជម្រក។
- បង្កើតបណ្ណាល័យ និងបន្ថែមសៀវភៅនៅតាមសាលារដ្ឋក្នុងគោលបំណង ជំរុញការសិក្សារបស់ក្មេងៗនៅតាមសាលារដ្ឋ។
- សាងសង់បង្គន់អនាម័យ សម្ភារអនាម័យ និងទឹកស្អាតសម្រាប់ក្មេងៗនៅសាលារដ្ឋ។
- សាងសង់អគារសិក្សាចំនួន៦ខ្នង និងទីលានកីឡាចំនួន៤។

### ២.៤.២ អត្រាទទួលបានការងារ ប្រាក់បៀវត្សរ៍ និងការពេញចិត្ត

នៅត្រឹមឆ្នាំ២០១៦ ខែមីនា មានក្រុមហ៊ុនចំនួន៧៣ បានសហការជាមួយអង្គការ និងបានផ្តល់ការងារដល់សិស្សានុសិស្សរបស់អង្គការ។ តាមរយៈការសម្ភាស៍ផ្ទាល់ យើងទទួលបានការពេញចិត្ត ៩០ភាគរយ ពីខាងក្រុមហ៊ុនទាំងនោះ។ តែក៏នៅមានចំណុចខ្វះខាតមួយចំនួន ដោយបណ្តាក្រុមហ៊ុនទាំងនោះ ស្នើសុំឲ្យមានការអភិវឌ្ឍបន្ថែមផ្នែកភាសាបរទេស ជាពិសេសភាសាអង់គ្លេស ជំនាញក្នុងការធ្វើការងារ និងអាកប្បកិរិយាជាដើម។

សិស្សដែលទទួលបានការងារធ្វើ គឺស្ទើរតែគ្រប់គ្នាទាំងអស់ពេញចិត្តនឹងការងារ ដែលត្រូវនឹងជំនាញរបស់ខ្លួន ជាមួយនឹងប្រាក់បៀវត្សរ៍ស្របតាមស្តង់ដារទីផ្សារកម្ពុជា ចន្លោះពី ១២០ដុល្លារ

រហូតដល់ ៣០០ដុល្លារ។ គិតជាមធ្យមគឺ ១៧៥ដុល្លារនៅឆ្នាំ២០១៣។

### ២.៤.៣ មតិរបស់សិស្សដែលបានបញ្ចប់ការសិក្សា

ស្របពេលដែលមានការអះអាងយ៉ាងមុតមាំ ក្នុងការធានាគុណភាពនៃការអប់រំរបស់កុមារ និងយុវជន ក្រុមនាងខ្ញុំក៏បានសម្ភាសន៍និស្សិតមួយចំនួន ដែលបានបញ្ចប់ការសិក្សា និងទទួលបានការងារធ្វើផងដែរ។ នៅក្នុងនោះមានមតិខ្លះបានលើកឡើងថា ការសិក្សានៅទីនោះគឺមានភាពតឹងរ៉ឹង ជាពិសេសគឺមានកិច្ចការផ្ទះច្រើន និងមតិខ្លះទៀតបានលើកឡើងថា មានការលំបាកដោយមិនទទួលបានប្រាក់ចាយវាយគ្រប់គ្រាន់ ម្យ៉ាងមេរៀនជាភាសាបរទេស ដែលមានការលំបាកខ្លះសម្រាប់អ្នកដែលមិនសូវចេះភាសាអង់គ្លេស។ ទោះជាយ៉ាងណាក៏ដោយ ឆ្លងផុតពេលវេលាលំបាកកន្លងមក សិស្សម្នាក់ៗមានការពេញចិត្តនឹងប្រព័ន្ធអប់រំរបស់អង្គការ ក៏ដូចជាការងារដែលខ្លួនកំពុងទទួលបានតាមរយៈការទទួលការអប់រំយ៉ាងតឹងរឹងនេះផងដែរ។ ខាងក្រោមគឺជាការសម្ភាសន៍ផ្ទាល់ចំពោះសិស្ស ៥រូបៈ

❖ ផ្នែកគណនេយ្យ និងធនធានមនុស្ស

- កញ្ញា រឿន កញ្ញា អាយុ២៧ឆ្នាំ បុគ្គលិកគណនេយ្យនៅកោះសន្តិភាព ៖

*"ខ្ញុំបានទទួលការផ្គត់ផ្គង់ពីអង្គការនៅឆ្នាំ២០១២ តាមរយៈការណែនាំរបស់មិត្តភក្តិខ្ញុំដែលកំពុងតែសិក្សានៅអង្គការផ្នែកទេសចរណ៍ និងសណ្ឋាគារ។ មុនពេលចូលអង្គការ នាងខ្ញុំមានជីវភាពលំបាកណាស់ ដោយគ្មានប្រាក់ក្នុងការបន្តការសិក្សា ហើយក៏សម្រេចចិត្តទៅធ្វើការជាកម្មការនីរោងចក្រ។ ក្រោយបានទទួលការអប់រំផ្សេងៗពីខាងសាលា ដែលទាក់ទងនឹងផ្នែករដ្ឋបាល និងគណនេយ្យ មានដូចជាជំនាញភាសាអង់គ្លេស ជំនាញកុំព្យូទ័រ ច្បាប់ការងារ ការងាររដ្ឋបាល (Administration Tasks) ការងារផ្នែកគណនេយ្យ (Accountant Tasks) ការងារគ្រប់គ្រងធនធានមនុស្ស(Human Resource Tasks) ការគ្រប់គ្រងស្តុក(Stock Management Tasks)។ល។ ក្រៅពីការអប់រំជំនាញ នាងខ្ញុំក៏ទទួលបានការអប់រំចិត្តគំនិត ការតាំងចិត្តឲ្យស្ងប់ វិន័យ និងអាកប្បកិរិយាការងារ(Professional Life Training)ផងដែរ។ នាងខ្ញុំមានការពេញចិត្តនឹងការអប់រំរបស់អង្គការខ្លាំងព្រោះនាពេលនេះ នាងខ្ញុំមានទទួលការងារមួយដែលសមប្រកប និងអាចយកអ្វីដែលបានសិក្សាកន្លងមកអនុវត្តជាពិសេសការគោរពវិន័យ និងការគោរពពេលវេលា។"*

- កញ្ញា ញឹម បុប្ផា អាយុ២៣ឆ្នាំ ផ្នែកធនធានមនុស្ស និងគណនេយ្យ ៖

*"ដោយទឹកចិត្តស្រលាញ់របស់ម្តាយមីង នាងខ្ញុំការបានទទួលការអនុញ្ញាតឲ្យបន្តការសិក្សានៅអង្គការដើម្បីភាពញញឹមនៃកុមារ។ កាលពីឆ្នាំ២០០០ ដោយគ្រួសារមានជីវភាពខ្វះខាតខ្លាំង ម្តាយ*

*មីងរបស់នាងខ្ញុំ ក៏បានទៅសុំអង្គការដើម្បីឲ្យនាងខ្ញុំទទួលបានឱកាសសិក្សាម្តងទៀត។ បន្ទាប់ពីអង្គការបានចុះទៅត្រួតពិនិត្យមើលស្ថានភាពគ្រួសាររបស់នាងខ្ញុំ គាត់ក៏អនុញ្ញាតព្រមទទួលផ្តត់ផ្គង់ខ្ញុំ។ ពេលនោះ ខ្ញុំមានការសប្បាយត្រេកអរយ៉ាងខ្លាំង។ នាងខ្ញុំបានទទួលការអប់រំទាំងផ្លូវកាយ និងចិត្ត ចំណេះជំនាញ និងចំណេះដឹងក្នុងសមាគមន៍។ នាងខ្ញុំស្រលាញ់ប្រព័ន្ធអប់រំនៅអង្គការនេះខ្លាំង ដោយសារយើងអាចរៀនបានទាំងទ្រឹស្តី និងអនុវត្តន៍ផ្ទាល់នៅអង្គការ ដែលនេះខ្ញុំគិតថាជាចំណុចពិសេសដែលធ្វើឲ្យសិស្សនៅអង្គការនេះមានគុណភាព។ ក្រោយបញ្ចប់ការសិក្សា ខ្ញុំទទួលបានការងារដែលប្រសើរ និងអាចជួយឲ្យជីវភាពគ្រួសារខ្ញុំបានធូរធារជាងមុនច្រើនណាស់។ ម្យ៉ាងខ្ញុំក៏តែងទទួលបានការសរសើរពីចាហ្វាយនាយ អំពីសមត្ថភាព ក៏ដូចជាចំណេះដឹង និងអាកប្បកិរិយារបស់នាងខ្ញុំផងដែរ។"*

❖ ផ្នែកប្រព័ន្ធផ្សព្វផ្សាយ

- លោក សុខា អាយុ២៦ឆ្នាំ ផ្នែកគ្រប់គ្រងសំឡេង ៖

*"ដោយស្ថានភាពគ្រួសារមិនល្អ ខ្ញុំក៏បានទៅស្នាក់អាស្រ័យនៅ ក្នុងវត្តដើម្បីទទួលបានឱកាសរៀនសូត្រ។ នៅឆ្នាំ២០០៦ អ្នកដែលស្នាក់នៅក្នុងវត្តជាមួយគ្នាក៏បានណែនាំខ្ញុំឲ្យស្គាល់ពីអង្គការនេះ។ ការអប់រំនៅទីនោះគឺល្អខ្លាំង ដោយយើងអាចទទួលបានទាំងចំណេះដឹងទូទៅ និងជំនាញពិតប្រាកដ។ ទោះបីជាមេរៀនមានការពិបាកយល់ និងត្រូវការភាពអត់ធ្មត់ខ្លាំងក្តី លទ្ធផលដែលទទួលបានគឺអស្ចារ្យខ្លាំងមែនទែន។"*

- លោក ឡេង សុភ័ក្ត អាយុ២៥ឆ្នាំ ផ្នែកថតកុន ៖

*"ខ្ញុំបានចូលក្នុងអង្គការ PSE នៅឆ្នាំ២០១១ នៅផ្នែកពាណិជ្ជកម្ម ប៉ុន្តែក៏បានប្រឡងចូលសាលាកុននៅឆ្នាំទី២ វិញ។ បន្ទាប់ពីសិក្សារយៈពេល ៣ឆ្នាំ ខ្ញុំពិតជាពេញចិត្តខ្លាំងណាស់នូវលទ្ធផលមួយនេះ ដោយវាអាចជួយសំរួលជីវភាព និងទទួលបានប្រាក់បៀវត្សន៍ខ្ពស់ជាងអ្នកដទៃៗទៀត។ PSE មានប្រព័ន្ធអប់រំល្អ ព្រោះអង្គការបានគិតដល់អ្វីដែលជាតម្រូវការរបស់មនុស្ស ដោយមិនមែនត្រឹមតែផ្តត់ផ្គង់នូវចំណេះដឹងប៉ុណ្ណោះទេ គឺថែមទាំងមានសកម្មភាពកម្សាន្ត ដូចជាថ្នាក់កីឡា ថ្នាក់របាំសិល្បៈ ដើម្បីបញ្ចៀសក្មេងៗពីការប្រព្រឹត្តអំពើមិនល្អ។ លើសពីនេះ សាលាក៏មានថ្នាក់តម្រង់ទិស និងសីលធម៌ ការផ្តល់របបអាហារសមរម្យ និងវិន័យតឹងរឹង ដែលជាកត្តាជំរុញឲ្យអង្គការមានកេរ្តិ៍ឈ្មោះ ហើយក៏មានបណ្តាក្រុមហ៊ុនជាច្រើន ដែលតែងចង់បានសិស្សPSE ទៅចូលរួមការងារផងដែរ។"*

### ២.៤.៤ ចំនួនកុមារដែលត្រូវបានផ្តល់ការការពារ

ក្រៅពីផ្តល់ការអប់រំ អង្គការក៏មានការផ្តល់ការការពារ លំនៅឋានស្នាក់អាស្រ័យផងដែរ ជាពិសេសសម្រាប់ក្មេងៗដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ដូចជាក្នុងគ្រួសារដែលមានអំពើហិង្សាជាដើម។ ហើយក៏មានក្មេងខ្លះ ត្រូវបានឪពុកម្តាយបោះបង់ចោល ក៏ត្រូវបានអង្គការទទួលយកមកចិញ្ចឹមបីបាច់ និងផ្តល់ការអប់រំផងដែរ។ កុមារទាំង ៦១២នាក់ ត្រូវបានបែងចែកទៅតាមកន្លែង និងផ្នែកផ្សេងៗ។

- កុមារចំនួន ១៩៤នាក់ ត្រូវបានឪពុកម្តាយធម៌យកទៅចិញ្ចឹម និងខ្លះនៅតាមកន្លែងមើលថែកុមារ។
- កុមារចំនួន ១៦៨នាក់ កំពុងស្នាក់នៅក្នុងអង្គការ ស្ថិតនៅចន្លោះអាយុ ៧ ដល់ ១៥ឆ្នាំ ដែលជាវ័យគ្រោះថ្នាក់។
- កុមារចំនួន ២៥១នាក់ បានផ្លាស់ចូលមករស់នៅក្នុងអង្គការផងដែរ ដោយមូលហេតុដើម្បីបន្តការសិក្សា ព្រោះគ្រួសារត្រូវចំណាកចេញពីភ្នំពេញដោយសម្ពាធនៃថ្លៃឈ្នួលផ្ទះ និងការចំណាយផ្សេងៗ។ ៩៨.៧ ភាគរយនៃកុមារ ដែលបានផ្លាស់ចូលមករស់នៅបានសម្រេចការសិក្សាយ៉ាងជោគជ័យផងដែរ។
- យុវវ័យប្រមាណជាង ២៩នាក់ កំពុងស្នាក់នៅផ្ទះរបស់អង្គការដែលមាននៅខេត្តសៀមរាប និងខេត្តព្រះសីហនុ ដែលស្ថិតក្នុងកំឡុងពេលហ្វឹកហាត់ការងារនៅតាមបណ្តាខេត្ត២នេះ។
- កុមារពិការចំនួន២០នាក់ ក៏កំពុងស្នាក់នៅ និងទទួលបានការអប់រំពីអង្គការផងដែរ។

### ២.៤.៥ ទិន្នន័យសិស្សានុសិស្ស និងនិស្សិត

#### ២.៤.៥.១ ចំនួនសិស្សសិក្សានៅផ្នែកអប់រំចំណេះដឹងទូទៅ

ខាងក្រោមនេះ ជាចំនួនសិស្សដែលបានសិក្សានៅឆ្នាំកន្លងមកដែលអង្គការបានឧបត្ថម្ភសម្រាប់ការសិក្សាទាំងនៅក្នុងសាលារដ្ឋ និងក្នុងអង្គការ។

**តារាងទិន្នន័យនៃចំនួនចំនួនសិស្សពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៦**

| សាលាបង្រៀន | **ឆ្នាំសិក្សា ២០១៣-២០១៤** | **ឆ្នាំសិក្សា ២០១៤-២០១៥** | **ឆ្នាំសិក្សា ២០១៥-២០១៦** |
|---|---|---|---|
| ថ្នាក់ពន្លឿន | ១២៧១ | ១៣០០ | ១១១៩ |
| ថ្នាក់សិក្សាតាមសាលារដ្ឋ | ៣៤១៩ | ៣២០០ | ៣៣០៨ |
| **ចំនួនសិស្សសរុប** | **៤៦៩០** | **៤៥០០** | **៤៤២៧** |

ក្រាបដែលបង្ហាញពីចំនួនសិស្សផ្នែកចំណេះដឹងទូទៅ




តាមក្រាបបានបង្ហាញថា ចំនួនសិស្សដែលបានចូលសិក្សារៀនសូត្រ ក្នុងអង្គការបានថយចុះ ដោយសារតែ គ្រួសាររបស់កុមារទាំងនោះមានជីវភាពធូរធារជាងមុន ពីព្រោះសមាជិកក្នុងគ្រួសារចាប់ផ្តើមមានការងារធ្វើ ដែលសមប្រកបក្រោយបញ្ចប់ការសិក្សា ខ្លះបង្កើតមុខរបរផ្ទាល់ខ្លួន និងខ្លះទៀតផ្លាស់ទីលំនៅ។

**២.៤.៥.២ ចំនួនសិស្សដែលសិក្សានៅផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ**

តារាងនៃចំនួនសិស្សដែលសិក្សាពីឆ្នាំ ២០១៣ ដល់ ២០១៦

| **ប្រភេទនៃសាលា** | **ឆ្នាំសិក្សា ២០១៣-២០១៤** | **ឆ្នាំសិក្សា ២០១៤-២០១៥** | **ឆ្នាំសិក្សា ២០១៥-២០១៦** |
|---|---|---|---|
| ថ្នាក់ស្ពានចម្លង ឬ ថ្នាក់ត្រៀម | ៤៦៣ | ៣១៣ | ៣៩៥ |
| ថ្នាក់បរិញ្ញាបត្រ | ១៦៤ | ១៩៩ | ៧៤ |
| សណ្ឋាគារ និងទេសចរណ៍ | ៣៨៨ | ៤៤១ | ៤២៩ |
| បច្ចេកទេស | ១៩៦ | ២៣៥ | ២២៨ |
| ពាណិជ្ជកម្ម | ២៨២ | ៣៦៥ | ៣៥២ |
| **ចំនួនសិស្សសរុប** | **១៤៩៣** | **១៥៥៣** | **១៤៧៨** |

តារាងនៃចំនួនសិស្សដែលសិក្សាពីឆ្នាំ ២០១៣ ដល់ ២០១៦




### ២.៤.៥.៣ ចំនួនសិស្សបញ្ចប់ការសិក្សានៃឆ្នាំ២០១៣ - ២០១៦

| ជំនាញ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ | ៣៣ | ៣២ | ២៤ |
| សណ្ឋាគារ និងទេសចរណ៍ | ២១៥ | ២១១ | ១៦៥ |
| បច្ចេកទេស | ៤២ | ៩៤ | ៧១ |
| ពាណិជ្ជកម្ម | ១១០ | ១០៦ | ៦៧ |
| **ចំនួនសិស្សសរុប** | **៤០០** | **៤៤៣** | **៣២៧** |

ក្នុងឆ្នាំសិក្សា ២០១៤ និង២០១៥ បានបញ្ចប់ការសិក្សា និងទទួលបានការងារធ្វើព្រមទាំងប្រាក់ជាមធ្យម ៖

- សិស្សដែលបានបញ្ចប់ការសិក្សាពីសាលាសណ្ឋាគារ និងទេសចរណ៍ មានចំនួន ២១១នាក់។ ក្នុងនោះគឺ១០០%ដែលទទួលបានការងារធ្វើ និងទទួលបានប្រាក់បៀវត្សរ៍ជាមធ្យមចំនួន ២២០ដុល្លារ ក្នុងមួយខែ។
- សិស្សដែលបានបញ្ចប់ការសិក្សាពីសាលាពាណិជ្ជកម្ម មានចំនួន១០៦នាក់។ ក្នុងនោះ ៩៨% ដែលទទួលបានការងារធ្វើ និងទទួលបានប្រាក់បៀវត្សរ៍ជាមធ្យមចំនួនពី២៣៨ ដល់២៧២ដុល្លារ

ក្នុងមួយខែ។

- ○ សិស្សដែលបានបញ្ចប់ការសិក្សាពីសាលាបច្ចេកទេស និងផ្នែកដឹកនាំរឿង មានចំនួន៩៤នាក់។ ក្នុងនោះ ពួកគាត់បានទទួលប្រាក់បៀវត្សរ៍ ជាមធ្យមចំនួន ៣៣៤ដុល្លារ ក្នុងមួយខែ។
- ○ សិស្សានុសិស្សដែលបានបញ្ចប់ការសិក្សាពីថ្នាក់បរិញ្ញាបត្រ ឬថ្នាក់បណ្តុះបណ្តាវិជ្ជាជីវៈដែលមានដៃគូជាមួយអង្គការផ្សេងៗ។[19]

**២.៤.៥.៣ ចំនួនសិស្សដែលបោះបង់ការសិក្សា**

នៅក្នុងឆ្នាំសិក្សា ២០១៥-២០១៦ ចំនួនសិស្សដែលបានបោះបង់ចោលការសិក្សាទាំងបឋមសិក្សា និងមធ្យមសិក្សាមានចំនួន ៩,៥%។ មូលហេតុដែលបណ្តាលដែលបណ្តាលឲ្យសិស្សានុសិស្សបោះបង់ការសិក្សាមានដូចជា៖

- ○ មានការផ្លាស់ទីលំនៅ
- ○ ត្រូវរៀបការ
- ○ បន្តការសិក្សា ឬ មានការងារធ្វើ
- ○ លែងចង់រៀនសូត្រ។

## ២.៥ បញ្ហាប្រឈម និងដំណោះស្រាយ

- មិនទទួលបានការសហការពីខាងឪពុកម្តាយ ឬ អាណាព្យាបាលរបស់កុមារ ដោយមូលហេតុធ្វើឲ្យបាត់បង់ចំណូលមួយផ្នែករបស់ពួកគាត់
- ➢ ដំណោះស្រាយ៖ ការឧបត្ថម្ភជាអង្ករដើម្បីជាការតបស្នង
- មិនគោរពវិន័យសាលា ការឈប់ឥតច្បាប់ ការមិនចូលរៀន
- ➢ ដំណោះស្រាយ៖ បង្កើតក្រុមប្រឹក្សាវិន័យ មន្ត្រីក្រៅអង្គការដើម្បីតាមដានការសិក្សា
- មិនទទួលបានការសហការ និងយកចិត្តទុកដាក់ ពីគ្រូបង្រៀននៅតាមសាលារដ្ឋ ដោយមូលហេតុ កុមារនៅអង្គការមិនបានបង់ប្រាក់បន្ថែមសម្រាប់គ្រូៗ
- ➢ ដំណោះស្រាយ៖ មានមន្ត្រីរបស់អង្គការ នៅអង្គុយនៅតាមថ្នាក់រៀននីមួយៗ ដើម្បីជាជំនួយសម្រាប់ក្មេងៗ
- ការខ្វះខាតជំនួយ ឬ ការឧបត្ថម្ភ ដែលបណ្តាលឲ្យកុមារខ្វះខាតអាហារជាដើម
- ➢ ដំណោះស្រាយ៖ កាត់បន្ថយរបបអាហារ ប្រភេទអង្ករជាដើម

[19] PSE for child´s smile : Activity report September 2014 – August 2015, page 6

## ២.៦ ការចំណាយទៅលើកម្មវិធីផ្សេងក្នុងការអប់រំ

តារាងនៃការចំណាយក្នុងកម្មពិធីផ្សេងៗក្នុងការអប់រំ ពីឆ្នាំ ២០១៤ ដល់ ឆ្នាំ ២០១៦

| ប្រភេទនៃការចំណាយ | ២០១៤-២០១៥ | | ២០១៥-២០១៦ | |
|---|---|---|---|---|
| | គិតជា អឺរ៉ូ | ភាគរយ | គិតជាអឺរ៉ូ | ភាគរយ |
| ការអប់រំផ្នែកចំណេះដឹងទូទៅ | ១៥៩៨ | ២៨ | ១៦០៦ | ២៨ |
| ការអប់រំផ្នែកវិជ្ជាជីវៈ | ២០៩៨ | ៣៧ | ២១១២ | ៣៧ |
| ថ្នាក់ពន្លឿន | ៩៧៧ | ១៧ | ៩៨៤ | ១៧ |
| ការស្នាក់នៅ | ៤២៣ | ៧ | ៤២៦ | ៧ |
| កម្មពិធីពិសេស (Specialised) | ១៩៥ | ៣ | ១៩៧ | ៣ |
| ជម្រុមណ្ឌលទំនាក់ទំនង(Community) | ៤២៥ | ៨ | ៤២៨ | ៨ |




តាមChart ខាងលើបានបង្ហាញថាការចំណាយដែលមានចំនួនច្រើនជាងគេគឺ ការចំណាយចំពោះផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានចំនួនរហូតដល់ទៅ ៣៧% នៃការចំណាយសរុប។ ក្រៅពីនេះ ការចំណាយចំពោះការអប់រំផ្នែកចំណេះដឹងទូទៅមាន ២៧% ការចំណាយចំពោះថ្នាក់ពន្លឿន ១៧% ការចំណាយចំពោះការជម្រុមណ្ឌលទំនាក់ទំនង (Community Centres) ៨% ការចំពោះការស្នាក់នៅ ៧% និងកម្មពិធីពិសេស (Specialised Programmes) ៣%។

ដូច្នេះការចំណាយរបស់អង្គការតាមផ្នែកនីមួយៗ ក្នុងកម្មពិធីអប់រំមានចំនួនសរុបគិតជាអឺរ៉ូគឺ €៥,៧៥៥.០០០ ស្មើនឹង ៦,៣១១,៥០៨.៥ដុល្លារ។

## ២.៧ ការចំណាយទៅលើបុគ្គលិក

តារាងនៃការចំណាយទៅលើបុគ្គលិកនៅក្នុងអង្គការ

| ឆ្នាំសិក្សា | បុគ្គលិក ពេញសិទ្ធ | បុគ្គលិក ស្ម័គ្រចិត្ត | ចំនួន បុគ្គលិកសរុប | ការចំណាយ គិតជាអឺរ៉ូ | ការចំណាយ គិតជាភាគរយ |
|---|---|---|---|---|---|
| **២០១៤-២០១៥** | ៦០២ | ១៧ | **៦១៩** | ២០៩ | ៣៧ |
| **២០១៥-២០១៦** | ៥៨០ | ៣៨ | **៦១៨** | ២៧១ | ៤៧ |

ការចំណាយទៅលើបុគ្គលិកក្នុងអង្គការគិតជាអឺរ៉ូ



ការចំណាយទៅលើបុគ្គលិកក្នុងអង្គការគិតជាភាគរយ




តាមក្រាបបង្ហាញថា ការចំណាយចំពោះបុគ្គលិកក្នុងអង្គការ ទាំងអ្នកស្ម័គ្រចិត្ត និងបុគ្គលិកពេញសិទ្ធមានការកើនឡើងច្រើនជាងពីរឆ្នាំមុន១០%។ ជាក់ស្តែង ចំនួននៃការចំណាយទៅលើបុគ្គលិកនៅក្នុងអង្គការនា ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ កើនពី €២០៩,០០០ ទៅ €២៧១,០០០។

## ២.៨ យុទ្ធសាស្ត្រ និងគម្រោងទៅថ្ងៃអនាគត

ដោយសារតែតម្រូវការទីផ្សារធនធានមនុស្ស ចេះតែមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយបច្ចុប្បន្ន អង្គការពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ នោះនៅថ្ងៃអនាគត អង្គការមានគម្រោងបង្កើត វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈមួយទៀត សម្រាប់សិស្សានុសិស្សដែលមានសមត្ថភាពក្នុងការបង់ថ្លៃសិក្សា។ ហើយនេះក៏ជាវិធីសាស្ត្រមួយ សម្រាប់ក្មេងៗដែលស្ថិតក្រោមជំនួយរបស់អង្គការអាចទទួលឱកាសក្នុងការស្គាល់មនុស្សមកពីប្រភពផ្សេងៗគ្នា និងការទទួលបានបទពិសោធន៍ ក៏ដូចជាការប្រកួតប្រជែងថ្មីៗផងដែរ។

# ជំពូកទី៣
# ការវិភាគសកម្មភាពរបស់
# អង្គការផៀបនឹងទ្រឹស្តី

# ជំពូកទី៣

# ការវិភាគសកម្មភាពរបស់អង្គការឆ្ពោះទៅរកកម្មវិធីទ្រឹស្ដី

## ៣.១ សកម្មភាពរបស់អង្គការ

ក្រោយពីការចុះស្រាវជ្រាវនៅក្នុងអង្គការដោយផ្ទាល់ ក្រុមយើងខ្ញុំបានសង្កេត ព្រមទាំងបានទទួលបាននូវឯកសារមួយចំនួនដែលគាំទ្រប្រធានបទ ព្រមទាំងទ្រឹស្ដីជាក់ស្ដែងពិតប្រាកដមែន។ ទាំងសកម្មភាពក្នុងការអប់រំ និងបណ្ដុះបណ្ដាលរបស់អង្គការ យុទ្ធសាស្ត្រនិងចំណាង់វិធីក្នុងការជំរុញការអប់រំ ក៏ដូចជាការបង្ហាត់បង្រៀន ការអនុវត្តជាក់ស្ដែង ការបង្កើតកម្មវិធីអប់រំផ្សេងៗ ការផ្ដល់នូវ សេវាសុខភាព ការផ្ដល់នូវការអប់រំផ្នែកសីលធម៌ អាកប្បកិរយា និងផ្លូវចិត្ត ការពង្រឹងគុណភាព គ្រូបង្រៀន ចំណាង់វិធីក្នុងការជ្រើសរើសសិស្សក្នុងការចូលរៀនជាដើម។ តួយ៉ាងតាមរយៈការសម្ភាសន៍ សិស្សដែលបាបញ្ចប់ការនៅក្នុងអង្គការផ្នែកគណនេយ្យ បាននិយាយរៀបរាប់ថា៖ ការរៀននៅក្នុងអង្គការបានផ្ដល់នូវការអប់រំ ទាំងផ្នែកទ្រឹស្ដី និងការអនុវត្តន៍ជាក់ស្ដែងក្នុងអំឡុងពេលសិក្សាដោយ សាលាបានធ្វើការសហការជាមួយក្រុមហ៊ុន ឬស្ថាប័នមួយចំនួនសម្រាប់ការចុះអនុវត្តរបស់សិស្ស បន្ទាប់ពីការសិក្សាផ្នែកទ្រឹស្ដី។ ជាងនេះទៅទៀតអង្គការបានផ្ដល់នូវការអប់រំផ្នែកសីលធម៌ទាំងការអប់រំចិត្ត និងផ្នែកអាកប្បកិរិយា ដោយទទួលបានលទ្ធផលល្អប្រសើចំពោះការងារសព្វថ្ងៃ។ ចំពោះសិស្សផ្នែក បណ្ដុះបណ្ដាលវិជ្ជាជីវៈ ខាងជុសជុលរថយន្តបាន សំដែងអារម្មណ៍របស់ខ្លួនថា៖ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយណាស់ចំពោះការសិក្សាទាំងផ្នែកទ្រឹស្ដី និងការអនុវត្តផ្ទាល់។ដោយសាលាមានកន្លែងសម្រាប់ការអនុវត្តដោយផ្ទាល់នូវក្នុងអង្គការ បើនិយាយពីគ្រូបង្ហាត់បង្ហាញគឺមានជំនាញច្បាស់លាស់ និងប្រកបដោយការយកចិត្តទុកដាក់ ព្រមទាំងភាពរួសរាយ។ ទោះបីនៅក្នុងសាលាមានវិន័យតឹងរឹងបន្តិចមែន តែខ្ញុំនូវតែពេញចិត្តក្នុងការសិក្សានៅអង្គការ។ ពីព្រោះតែការដាក់វិន័យតឹងរឹងក៏ដោយ សារតែចង់ឲ្យសិស្សទទួលបាននូវការអប់រំមួយដ៏ល្អដែរ។

### ៣.១.១ ចំណុចខ្លាំងរបស់អង្គការ

- **ផ្ដោតទៅលើកុមារ និងគ្រួសារក្រីក្រខ្លាំង៖** កុមារដែលស្ថិតនៅតំបន់គំនរសំរាម ស្ថិតក្នុងគ្រួសារដែលមានអំពើហិង្សា ជាពិសេសក្មេងពិការ។
- **ផ្ដល់ការអប់រំដែលប្រកបដោយជំនាញពិតប្រាកដទៅដល់និស្សិត៖** តាមរយៈការសម្ភាសន៍សិស្សដែលបញ្ចប់ការសិក្សា ពួកគេមានការរីករាយនឹងជំនាញដែលខ្លួនទទួលបាន ដោយពួកគេអាចយកវាទៅប្រើប្រាសក្នុងការងារដោយភាពរលូន ហើយពួកគេបានទទួលស្គាល់

ថា ពួកគេពិតជាទទួលបានជំនាញពិតប្រាកដ។

- **កម្មវិធីសិក្សាសិក្សា មានការទទួលស្គាល់ដោយក្រសួងអប់រំ និងក្រសួងការងារនៃ រដ្ឋាភិបាលកម្ពុជា៖** ការបង្កើតកម្មវិធីសិក្សាសិក្សាផ្សេងៗ តែងមានការទទួលស្គាល់ពីខាងក្រសួងពាក់ព័ន្ធ ដើម្បីធានាដល់សុវត្ថភាពសិក្សានុសិស្សនាថ្ងៃអនាគតក្នុងទីផ្សារការងារ ដោយទោះជាប្រតិបត្តិការនៃការដាក់ឲ្យមានការទទួលស្គាល់នេះមានភាពលំបាកក៏ដោយ។
- **ការផ្គត់ផ្គង់នូវមុខវិជ្ជាជីវៈជាច្រើនដែលកំពុងជាតម្រូវការទីផ្សារ៖** អង្គការបានសំលឹងមើលយ៉ាងវែងឆ្ងាយពីស្ថានភាពទីផ្សារធនធានមនុស្សនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន និងអនាគត ដើម្បីជាប្រយោជន៍ដល់សិស្សក្រីក្រទាំងនោះក្នុងការទទួលបានចំនេះដឹងដែលអាចប្រើប្រាស់បាន។
- **ផ្គត់ផ្គងតម្រូវការផ្សេងៗដែលមនុស្សជាទូទៅត្រូវការជាចាំបាច់៖** អង្គការបានសិក្សាស្វែងយល់ពីស្ថានភាពកុមារទាំងនោះ និងបានបង្កើតកម្មវិធីសិក្សាផ្សេងៗដូចជា ថ្នាក់របាំ កីឡា សីលធម៌ ទស្សនៈវិទ្យា។ល។ ក្នុងគោលបំណង ឲ្យសិស្សមានភាពរីករាយក្នុងការរស់នៅជាប្រចាំ ក្រៅពីជីវភាពដ៏សែនអាប់អួរនៅលើគំនរសំរាម ដើម្បីជំរុញទឹកចិត្តឲ្យសិស្សរៀនសូត្របានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។
- **ជាកន្លែងផ្គត់ផ្គងធនធានមនុស្សដ៏គួរឲ្យទុកចិត្ត៖** មានការទទួលស្គាល់គុណភាពខ្ពស់ពីខាងបណ្តាក្រុមហ៊ុនទាំងឡាយដែលបានផ្តល់ការសហការ ទោះបីជាសិស្សទាំងនោះនៅមានកង្វះខាតបន្តិចបន្តួចក្តី តាមរយៈការសម្ភាសន៍ផ្ទាល់របស់អង្គការជាមួយនឹងបណ្តាក្រុមហ៊ុន គឺបានទទួលលទ្ធផលវិជ្ជមានរហូតដល់ទៅ៧៥ភាគរយ។
- **មានការវិវត្តន៍ខ្លួនឥតឈប់ឈរដើម្បីត្រៀមខ្លួនក្នុងការកសាងធនធានមនុស្ស៖** ចាប់ផ្តើមពីអគារផ្ទះជួល រហូតដល់បច្ចុប្បន្នអង្គការមានអគារ និងវិទ្យាស្ថានបណ្តុះបណ្តាលផ្ទាល់ខ្លួនយ៉ាងស្កិតស្កេរ ដោយសារតែតម្រូវការនៃការបណ្តុះបណ្តាលសិស្សនិស្សិតពីមួយឆ្នាំទៅមួយឆ្នាំ តម្រូវឲ្យអង្គការមានការវិវិត្តន៍ខ្លួន ដើម្បីកសាងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដែលស្របតាមបេសកកម្មរបស់អង្គការ។

### ៣.១.២ ចំណុចខ្សោយរបស់អង្គការ

- និស្សិតមួយចំនួននៅខ្វះជំនាញចំណេះដឹងមួយចំនួន៖ ជំនាញភាសាបរទេស ជំនាញស្តាប់
- និស្សិតនៅខ្វះជំនាញក្នុងការធ្វើការងារ (Professional Attitude)៖ ដោយការផ្លាស់ប្តូរពីជីវភាពនៅលើគំនរសំរាម មកធ្វើការក្នុងសង្គម ក៏នៅមានសិស្សនិស្សិតមួយផ្នែកតូច

(៥ភាគរយ) មិនទាន់សុាំនឹងបរិយាកាសថ្មីទាំងស្រុង ដែលបណ្តាលឲ្យពួកគាត់នៅមានចំនួនខ្វះខាតទាក់ទងនឹង Professional Attutude ដូចជាមិនសូវរហ័សរហួន និងសកម្មក្នុងការងារជាដើម។

- អង្គការផ្តោតតែលើកុមារដែលនៅជាយរាជធានីភ្នំពេញ៖ កុមារក្រីក្រនៅតាមភ្នំពេញមានច្រើន នឹងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ដោយងាយរងឥទ្ធិពលនៃគ្រឿងញៀន និងអំពើមិនល្អជាច្រើនក្តី ក៏មានកុមារជាច្រើននៅតាមតំបន់ដាច់ស្រយោល ដែលសង្ឃឹមថានឹងទទួលបានឱកាសរៀនសូត្រ និងរួចផុតពីបញ្ហាជីវភាពផងដែរ។

## ៣.២ ទ្រឹស្តីនៃប្រសិទ្ធភាពអប់រំ

ប្រសិទ្ធភាពនៃការអប់រំ គឺមានន័យថាលំនាំនៃដំណើការ ឬជាលំនាំនៃការបណ្តុះបណ្តាល ការបង្រៀន និងការរៀនដោប្រើប្រាស់លើមុខវិជ្ជាផ្សេងៗព្រមទាំងការបណ្តុះបណ្តាលកាយសម្បទា សតិមបញ្ញា និងសីលធម៌ ការហាត់ចិត្ត បង្វឹកចិត្ត កិរិយាមាយាទ តាយរយៈគ្រប់សកម្មភាពអប់រំដែលធ្វើឲ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃឲ្យសម្រេចបានឲ្យពូកែដើម្បីក្លាយខ្លួនជាបុគ្គលដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ សង្គម ប្រទេសជាតិ និងពិភពលោកទាំងមូល។

## ៣.៣ សំយោគទ្រឹស្តី និងសកម្មភាព

តាមរយៈចំណុចដែលបានសិក្សាខាងលើ សកម្មភាពរបស់អង្គការក្នុងការបណ្តុះបណ្តាល និងអប់រំសិស្សពិតជាមានលក្ខណៈស្របទៅនឹងទ្រឹស្តីដែលបានលើកឡើងពិតប្រាកដមែន។ ដោយអង្គការបានផ្តល់នូវការអប់រំ ចម្រុះជាច្រើនមុខវិជ្ជាដែលមានទាំងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែង ដោយយកចិត្តទុកដាក់ផ្នែកសីលធមិ ការថែទាំសុខភាព និងអនាម័យ ការផ្តល់នូវអាហារ ការស្នាក់នូវចំពោះសិស្សដែលបាននឹងកំពុងសិក្សា។

# សេចក្តីសន្និដ្ឋាន
# និង
# អនុសាសន៍

# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

តាមការសិក្សាខាងលើ ក្រុមនាងខ្ញុំយល់ឃើញថា អង្គការមានសកម្មភាព និងការយកចិត្តទុកដាក់ជាច្រើនចំពោះការពង្រឹងគុណភាព និងប្រសិទ្ធភាពរបស់ខ្លួន។ តាមរយៈការបង្កើតកម្មវិធីសិក្សាសិក្សាផ្សេងៗដូចជា ថ្នាក់ពន្លឿនសម្រាប់ក្មេងៗដែលបោះបង់ចោលការសិក្សានៅថ្នាក់តូចៗ ថ្នាក់ស្ពានចម្លងដែលទទួលស្គាល់ជាផ្លូវការដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីជួយសម្រួលដល់កុមារដែលពុំបានទទួលបានការសិក្សា ស្របតាមកម្មវិធីសិក្សាសិក្សាទូទៅរបស់រាជរដ្ឋាភិបាល ឲ្យមានឱកាសអាចចូលរៀនថ្នាក់បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងថ្នាក់ត្រៀមដើម្បីពង្រឹងចំណេះដឹងមុនពេលចូលរៀនថ្នាក់បច្ចេកទេសជាដើម។ លើសពីនេះ អង្គការក៏បានអភិវឌ្ឍន៍កម្មវិធីសិក្សាសិក្សារបស់ខ្លួន ឲ្យមានការទទួលស្គាល់តាមស្តង់ដារអាស៊ាន ដើម្បីសម្រួលដល់ឱកាសការងាររបស់យុវជនផងដែរ។

មកដល់បច្ចុប្បន្នមានសិស្សដែលបានបញ្ចប់ការសិក្សាប្រមាណ៤០០០នាក់ ដែលទទួលបានឱកាសការងារពីក្រុមហ៊ុនធំៗមួយចំនួននៅកម្ពុជា ដែលនេះអាចសបញ្ជាក់ថា គុណភាពសិស្សរបស់អង្គការមានការទទួលស្គាល់ខ្ពស់ ទាំងចំនេះជំនាញ និងអាកប្បកិរិយា។ យើងឃើញថា ចំនួន សិស្សពីមួយឆ្នាំទៅមួយឆ្នាំមានការថយចុះជាលំដាប់ ដោយនេះបានបង្ហាញអំពីការរីកចម្រើននៃផ្នែកសេដ្ឋកិច្ចរបស់យុវជន និងគ្រួសារក្រីក្រទាំងនោះ បន្ទាប់ពីបានទទួលការអប់រំប្រកបដោយគុណភាព ដែលជំរុញឲ្យពួកគេមានឱកាសទទួលបានការងារដែលទទួលបានប្រាក់កម្រៃសមរម្យក្នុងការជួយផ្គត់ផ្គង់ជីវភាពគ្រួសារ និងផ្លាស់ប្ដូរជីវិតខ្លួនឯង និងក្រុមគ្រួសារទាំងមូលផងដែរ។

ការចំនាយទៅលើប្រព័ន្ធអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈមានទំហំធំ ដោយអង្គការផ្ដោតសំខាន់ទៅលើការសិក្សារបស់កុមារ និងយុវជនក្នុងគោលបំណង ជំរុញឲ្យពួកគេមានសមត្ថភាពក្នុងការផ្លាស់ប្ដូរខ្លួនគេដោយខ្លួនឯង និងតាមរយៈការទទួលបានការងារធ្វើ ដែលនេះស្របទៅតាមបេសកកម្មចំបងរបស់អង្គការដែលបានតាក់តែងឡើងតាំងពីដំណាក់កាលដំបូងរហូតមកដល់បច្ចុប្បន្ន និងកំពុងបន្តអនុវត្តដើម្បីទទួលបានជោគជ័យនាពេលអនាគតផងដែរ។

## ២.អនុសាសន៍

អង្គការដើម្បីភាពញញឹមនៃកុមារបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមសង្គមកម្ពុជាក្នុងការលុបបំបាត់ភាពក្រីក្រ បង្កើនលទ្ធភាពក្នុងការចូលរៀន និងលុបបំបាត់អំពើអស្តេរភាពទាំងឡាយដែលតែងកើតមានឡើងតាមរយៈការផ្តល់ការអប់រំ។

បន្ទប់ពីធ្វើការសិក្សាស្រាវជ្រាវរួច ក្រុមនាងខ្ញុំសង្ឃឹមថា៖

- អង្គការនឹងបន្តខិតខំបង្កើតកម្មវិធីសិក្សាសិក្សាផ្សេងៗក្នុងការជួយសម្រួលដល់កុមារដែលគ្មានលទ្ធភាពសិក្សាបន្ថែម ស្វែងរកមុខវិជ្ជា ឬ ជំនាញដទៃៗផ្សេងៗទៀតដែលកំពុងត្រូវការជាចំបាច់ក្នុងការអភិវឌ្ឍសង្គមកម្ពុជានាពេលខាងមុខសម្រាប់សិស្សានុសិស្សសិក្សា។
- អង្គការគួរពង្រីកសកម្មភាព និងតំបន់គោលដៅរបស់ខ្លួនទៅតាមបណ្តាលខេត្ត និងតំបន់ដាច់ស្រយាលមួយចំនួនទៀត ដោយពួកគេកំពុងត្រូវការជំនួយយ៉ាងខ្លាំង។
- កុមារ និងយុវជនទាំងអស់គួរយកចិត្តទុកដាក់ក្នុងការសិក្សា គោរពវិន័យឲ្យបានខ្ជាប់ខ្ជួនដើម្បីក្លាចទៅជាធនធានដ៏ប្រពៃសម្រាប់សង្គមនិងគ្រួសារ។

# ឯកសារយោង

# ឯកសារយោង


- វចនានុក្រមខ្មែរភាគទី១, ទំព័រទី ៩១៨ និង៥១១, ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧
- ច្បាប់ស្តីពីការអប់រំ រាជកិច្ច ទំព័រ ៩៨០២
- ដងស្រង់ចេញពីវចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ ព.ស ២៥១១, គ.ស ១៩៦៧
- ប្រវត្តិសាស្ត្រកម្ពុជា ពីបុព្វសម័យដល់សតវត្សទី៨ បណ្ឌិត ម៉ុន ត្រាណេ
- ប្រវត្តិនៃការអប់រំនៅកម្ពុជា របស់លោក យ៉ង ធី ១៩៩៧
- ដងស្រង់ពីទស្សនាវដ្តីខេមយានកម្ម លេខ៧ ឆ្នាំទី១
- ប្រវត្តិសាស្ត្រនៃព្រះរាជាណាក្រកម្ពុជា របស់លោកបណ្ឌិត ឥន្ទ ឱមសាម៉េង
- ប្រវត្តសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ដើមសតវត្សទី១ រហូតដល់ចុងសតវត្សទី២០ របស់បណ្ឌិត ឈុន ពហុ និងអនុបណ្ឌិត ងួន ហេង បោះពុម្ពលើទី១ ឆ្នា ២០១៥
- សេដ្ឋកិច្ចកម្ពុជា មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត របស់បណ្ឌិត ហង់ ជួនណារ៉ុង ២០១៥
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤ - ២០១៨, ក្រសួងអប់រំយុវជន និងកីឡា
- សារណាបញ្ចប់ការសិក្សាស្តីពី ការអប់រំកុមារក្រីក្រនៅអង្គការដើម្បីភាពញញឹមនៃកុមារឆ្នាំ ២០១៦, សាកលវិទ្យាល័យភូមិន្ទចំណាង់សាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- Activity Report and Accounts (2013-2016) / http://www.pse.ngo/en
- Account for the Fiscal Year ( 2014-2016 )
- http://www.pse.ong/en/our-mission ( ០៨/ ០៧/ ២០១៧)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## គម្រូវសំណួរសម្ភាសន៍គ្រូ

១. លក្ខខណ្ឌ និងចំណង់វិធីក្នុងការជ្រើសរើសកុមារឲ្យចូលក្នុងគម្រោងរបស់អង្គការ

២. កុមារ និងតំបន់ គោលដៅ របស់អង្គការ

៣. តើកម្មវិធីសិក្សាសិក្សាចំបងនៅអង្គការដើម្បីស្នាមញញឹមកុមារត្រូវបានបែងចែកជាប៉ុន្មាន?

៤. តើកុមារត្រូវបានបែងចែកឲ្យទៅសិក្សានៅតាមកន្លែង ឬ សាលាណាខ្លះ?

៥. តើអង្គការមានសកម្មភាពយ៉ាងណាក្នុងការតាមដានការសិក្សារបស់ក្មេងៗថ្នាក់បឋមសិក្សា និងមធ្យមសិក្សា?

៦. តើកុមារទទួលបានការឧបត្ថម្ភអ្វីខ្លះក្នុងការសិក្សាថ្នាក់ចំណេះដឹងទូទៅនេះ?

៧. តើកម្មវិធីសិក្សាថ្នាក់ពន្លឿនជាអ្វី? តើកម្មវិធីសិក្សានេះមានប្រព័ន្ធសិក្សារបៀបណា?

៨. តើកម្មវិធីសិក្សាសិក្សាថ្នាក់ត្រៀម និងថ្នាក់ស្ពានចម្លងជាអ្វី?

៩. តើកម្មវិធីសិក្សាសម្រាប់បណ្ដុះបណ្ដាលវិជ្ជាជីវៈត្រូវបានបែងចែកជាប៉ុន្មានជំនាញ?

១០. តើសិស្សានុសិស្សជ្រើសរើសមុខជំនាញសម្រាប់សិក្សាតាមរបៀបណា?

១១. តើអង្គការមានផ្ដល់ការគាំទ្រអ្វីផ្សេងទៀតទេ ក្រៅពីការអប់រំចំណេះដឹង?

១២. បញ្ហាប្រឈមផ្សេងៗ និងការដោះស្រាយរបស់អង្គការ

១៣. ដំណាក់កាលនៃការជ្រើសរើសគ្រូបង្រៀន

១៤. តើអង្គការមានការអប់រំផ្នែកអនាម័យ និងកម្មវិធីសិក្សាអប់រំផ្សេងៗយ៉ាងណា?

១៥. តើអង្គការបានសហការជាមួយដៃគូណាខ្លះ?

## សំណួរសម្ភាសន៍និស្សិតបញ្ចប់ការសិក្សា

១. ចូរប្រាប់ពី ឈ្មោះ អាយុ និងការងារបច្ចុប្បន្នរបស់អ្នក

២. តើអ្នកបានចូលអង្គការតាមរយៈអ្វី? នៅឆ្នាំណា?

៣. តើអ្នកស្ថិតក្នុងស្ថានភាពបែបណា មុនពេលចូលអង្គការ?

៤. តើអ្នកបានទទួលការអប់រំ និងអត្ថប្រយោជន៍អ្វីខ្លះពីអង្គការ?

៥. តើអ្នកគិតបែបណាចំពោះប្រព័ន្ធអប់រំ និងចំណុចពិសេសដែលអ្នកទទួលបានកន្លងមក?

៦. តើអ្នកបានទទួលបញ្ហាលំបាកកំឡុងពេលសិក្សា?

៧. តើអ្នកពេញចិត្តនឹងលទ្ធផលដែលអ្នកទទួលបានពីអង្គការដែរឬទេ? ដល់កម្រិតណា?

៨. ចូររៀបរាប់ពី សម្មទ្ធិផលនៃការងារ និងការពេញចិត្តរបស់ថ្នាក់លើទាក់ទងនឹងអង្គការដើម្បីភាពញញឹមនៃកុមារ?

# ឧបសម្ព័ន្ធទី២

## កំរងរូបថតបង្ហាញពីសកម្មភាព

រូបទី១៖ ការចុះទៅដល់តំបន់គោលដៅក្នុងការជ្រើសរើសក្មេងៗ




រូបទី២៖ ការចែកចាយអង្ករដល់គ្រួសារកុមារ ដើម្បីជាសំណងនៃការអនុញ្ញាតឲ្យកូនមកសិក្សា



រូបទី៣៖ កម្មវិធីសិក្សាប្រឡងសមត្ថភាពបម្រើសេវាកម្ម



រូបទី៤៖ សកម្មភាពក្នុងពេលប្រឡង



រូបទី៥៖ គម្រោង FLIP បណ្តុះបណ្តាលស្ត្រីមេម៉ាយទាក់ទងនឹងការកាត់ដេរ




រូបទី៦៖ ស្ថាបនិកអង្គការដើម្បីភាពញញឹមនៃកុមារ និងសិស្ស



# ឧបសម្ព័ន្ធទី៣



The genocide by Khmer Rouge regime left the country totally destroyed with a fragmented society, with no moral values or solidarity system...

The first victims are the children: scavengers or street-vendors, children are often the target of mistreatment and human trafficking, malnourished, without healthcare and no access to education...

Today, Cambodia is developping but many children and families are still left behind.

**Our Programs**

Since 1995, PSE - Pour un Sourire d'Enfant (For a Child's Smile), has operated in Cambodia to pull children out of extreme poverty. Recognised by the Cambodian Authorities, PSE has developed programs designed to meet children's basic needs.

**NUTRITION**
8,500 meals per day
Milk program for children in day care centers.

**HEALTHCARE**
2,400 consultations per week
Medical doctors, nurses, psychologists, pediatric nurses and dentists.

**SHELTER**
Boarding school, foster families
For at risk children, or those who are living too far from our Center and need protection.

**GENERAL EDUCATION**
3,100 children in state schools
1,200 children in remedial classes
700 children in other educational programs.

**VOCATIONAL TRAINING**
1,500 youth in vocational training
20 job training offered. Supported curriculum by renowned European references.

**FAMILY SUPPORT**
Rice Compensation for the loss of their children's earns (rice:7T/week)
Daycare, rehousing, temporary employment, emergency support, training

**Our Objective**

*from destitution... to a vocation!*

PSE INSTITUTE: 3 VOCATIONAL TRAINING SCHOOLS

- **School of Hospitality and Tourism**
  Food production, food and beverage service, beauty and spa, tour guide, front office, within others.
- **School of Business**
  Administration and accounting, Sales and marketing.
- **School of Technology**
  Mechanics, construction, media communication.

**Their stories**

«Before PSE, I used to wake up at 4 to reach the dumpsite by 6 am. Attending school at PSE changed my life. Now, I can support my family and like my work as a Primary Teacher!»
Reaksmey, Teacher

«When I was young, I was helping my mother selling snacks or scavenging to find bits of plastic to sell afterwards. I was scared of people. Now, I gained confidence through my education. Today, I run a travel Agency in Siem Reap.»
Sothea, Travel Agent

ALMOST 100% OF OUR STUDENTS FIND A JOB AS SOON AS THEY GRADUATE

## Our branches in France




## Our overseas branches



**PSE Por la Sonrisa de un Niño**
MADRID



**PSE For a Child's Smile UK**
LONDON



**KinderlaechelnDeutschlandPSE**
DUDWEILER



**PSE Hong-Kong**
HAPPY VALLEY, HONK-KONG



**Aktie België - Action Belgique Pour un Sourire d'Enfant (AB Pse)**
BRUSSELS



**PSE USA - For a Child's Smile USA**
SAN FRANCISCO



**PSE Luxembourg asbl**
LUXEMBOURG



**PSE Suisse**
BELMONT SUR LAUSANNE

# THANK YOU TO OUR PARTNERS & CORPORATE SPONSORS

Aide et Action – Changing the world through Education
Fondation Albatros – Une action philanthropique suisse
AADD
Fondation Amanjaya
fondation AnBer
AMGEN
Amundi Asset Management
fondation Blancmesnil – Institut de France
bibelo
BTP CFA Loire-Atlantique
CCOSC The Cambodian Consortium for out of School Children
Centre d'Excellence Management et Société
ESSEC Business School
Devoteam Fondation
DOD Decor Ouest Distribution – Apporteur de solutions
Educate a Child
effet passementeries
FONDATION FRANZ MARTIN
FONDS DE DOTATION HAGURO
GOTO Solidaire
Kampuchea Balopp
Kéa Partners for transformation
le Hameau du Père Noël
Louis Lumière école nationale supérieure
MONIN
Mobivia Groupe
Norauto
Fondation Obelisque
Papiers de l'Espoir
PICTET Fondation de bienfaisance du groupe Pictet
Pistorio Foundation
Poids Plume Asie
Fundación Realmadrid
Région Midi-Pyrénées
Solutions to End Poverty
Serge Comtesse Coiffeurs Conseils Visagistes
Small Steps Project
Thales Fondation
WeWorld

and our partners in Peintres du sourire

Henkel
ROMUS
ROULOR Professionnel
TOUPRET Relevons tous les défis
UGD
Le Club ONIP


Beneficiaries 2015 -16
Total : 6,529
Nurseries
505
Specialised
Programmes
119
Vocational
Training and
Preparation
classes
1,478
Schooling
4,427


Staff in Cambodia
as at end August 2016
total: 618
Volunteers
with local
contracts;
28
VSI and
expatriate
volunteers;
3
Expats with
local
contracts;
7
Staff with
local
contracts;
580
Plus state school staff
paid fees:76




## ចំណាប់អារម្មណ៍កុមារនៅថ្នាក់ពន្លឿន



"For me, what this project has changed, is that I can read and write [...], we can save time by covering two years in one. That encourages us to learn without having to be embarrassed."

Sopheab, 10 years old

Filming
‘Les Pépites’
(Little Gems)





Inauguration of
Smile Village
26 September 2015



Parents Meeting
5 October 2015





‘Open day’
at the PSE Institute
for Vocational
Training
18 Dec 2015 and 1 Jul 2016

National
examinations, in
the Centre, for
pupils attending
the Institute

24-25 Feb 2016
25-26 Aug 2016



PSE POUR UN SOURIRE D'ENFANT

*de la misère... à un métier !*

**Breakdown of Revenue for Operations & Investments by Source**

**Total: €7,401k**




**Breakdown of Expenditure by Function**

**Total: €6,335k**






Association loi 1901 Reconnue de Bienfaisance / Lauréate du Prix des Droits de l'Homme

Siège Social : 49 rue Lamartine 78000 Versailles • 33 (0)1 30 24 20 20 • contact-fr@pse.ong • Siret : 394 044 127 000 30 • Code APE 8899B
Cambodge: BP 2107- Phnom Penh 3- CAMBODIA • 00 855 23 995 660 • pse@pse.ong
www.pse.ong

## Breakdown of Overheads & Fundraising

**Total: €580k**




## Cost of the programmes in Cambodia

**Total: €5,755k**






Association loi 1901 Reconnue de Bienfaisance / Lauréate du Prix des Droits de l'Homme

Siège Social : 49 rue Lamartine 78000 Versailles • 33 (0)1 30 24 20 20 • contact-fr@pse.ong • Siret : 394 044 127 000 30 • Code APE 8899B
Cambodge: BP 2107- Phnom Penh 3- CAMBODIA • 00 855 23 995 660 • pse@pse.ong
www.pse.ong